សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale De Droit et des Sciences Economiques

Royal University of law and Economics


## សារណាបញ្ចប់ការសិក្សា

# លំហូរនីតិវិធីក្នុងរឿងក្ដីព្រហ្មទណ្ឌ

ស្រាវជ្រាវពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ ថ្ងៃទី ១០ ខែសីហា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **លោក គន់ ដារ៉ាក់**

**លោក ឈួន មុន្នីរិទ្ធិ**

ណែនាំដោយ

លោក **តា សុទ្ធា**



ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៤

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំទាំងពីរឈ្មោះ **គន់ ដារ៉ាក់** និង **ឈួន មុន្នីរិទ្ធិ** ជានិស្សិតបរិញ្ញាបត្រផ្នែកនីតិសាស្ត្រជំនាន់ទី ២៤ នៃ**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**។

យើងខ្ញុំទាំងពីរសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ លោកឪពុក អ្នកម្តាយ យើងទាំងពីរ ដែលលោកបានផ្តល់កំណើតព្រមទាំងចិញ្ចឹមបីបាច់មើលថែរក្សាថ្នាក់ថ្នមយើងខ្ញុំតាំងពីពេលចាប់កំណើតមក រហូតមកដល់សព្វថ្ងៃនេះដោយក្តីសណ្តោសប្រណី និងព្រហ្មវិហារធម៌ ជាពិសេសគឺជាអ្នកដែលបានដែលបាន ផ្តល់នូវការអប់រំទូន្មានមុនដំបូងគេបង្អស់ ដល់យើងខ្ញុំទាំងពីរអ្នក លើសពីនេះទៅទៀត លោកអ្នកគុណតែងតែ ទំនុកបម្រុងជ្រោមជ្រែងគ្រប់សព្វបែបយ៉ាងសម្រាប់ផ្គត់ផ្គង់ដល់ការរៀនសូត្ររបស់យើងខ្ញុំតាំងពីថ្នាក់មតិយ្យ រហូតដល់បញ្ចប់ថ្នាក់ឧត្តមសិក្សាបរិញ្ញាបត្រនីតិសាស្ត្រនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រ សេដ្ឋកិច្ចនេះ ដោយពុំដែលត្អូញត្អែរពីភាពនឿយហត់បន្តិចណាសោះឡើយដែលទាំងនេះគឺជាកម្លាំងជំរុញដ៏ធំ អស្ចារ្យបំផុតមួយនៅពីក្រោយភាពជោគជ័យរបស់យើងខ្ញុំទាំងពីររូបក្នុងពេលបច្ចុប្បន្ននេះ។

យើងខ្ញុំសូមថ្លែងអំណរគុណដល់ **ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស និងលោក លោកស្រី សាស្ត្រាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ទាំងអស់ដែលបានខិតខំអស់ពីកម្លាំងកាយ កម្លាំងចិត្ត ក្នុងការដឹកនាំ អប់រំ ជ្រុមជ្រែង និងចែករំលែកចំណេះដឹងជូននិស្សិតកន្លងមក។

សូមថ្លែងអំណរគុណដល់ **លោក តា សុទ្ធា** ដែលលោកបានព្រមទទួលយកនូវការដឹកនាំក្នុងការ សរសេរសាណាបញ្ចប់ការសិក្សារបស់យើងខ្ញុំ ដោយលោកបានចំណាយនូវពេលវេលាដ៏មានតម្លៃទាំងកម្លាំង កាយ និងកម្លាំងចិត្ត ដើម្បីបណ្តុះបណ្តាល ពន្យល់ណែនាំផ្តល់ជាគតិគំនិតដើម្បីបំភ្លឺយើងខ្ញុំក្នុងរយៈពេលកន្លង មកនេះ រហូតយើងខ្ញុំបានចងក្រងនូវ សារណាបញ្ចប់ថ្នាក់បរិញ្ញាប័ត្រមួយនេះឡើងដោយភាពជោគជ័យ។

ជាទីបញ្ចប់យើងខ្ញុំទាំងពីរនាក់សង្ឃឹមថា សៀវភៅសារណាមួយក្បាលនេះ និងជួយដល់មិត្តៗនិស្សិត ដែលមានបំណងចង់ពង្រឹងចំណេះដឹងបន្ថែម។ សូមសម្តែងសេចក្តីគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះអ្នកមានគុណដែលបានជួយជ្រោមជ្រែងដល់យើងខ្ញុំទាំងពីរជាពិសេសសូមប្រសិទ្ធពរជ័យ សិរីសួស្តី វិបុល សុខ បវរមហាប្រសើរដល់លោកអ្នកមានគុណទាំងអស់មានសុខភាពមាំមួន ទទួលបានជោគជ័យគ្រប់ភារកិច្ច និងមានពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

## **អារម្ភកថា**

ក្រោយពីបានធ្វើការសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ជំនាន់ទី២៤ នៃ**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**ក្នុងឆ្នាំសិក្សា២០២០-២០២៤ អស់រយៈពេល៤ឆ្នាំកន្លងមក ដោយមានការជ្រោមជ្រែងពីលោកគ្រូអ្នកគ្រូ សាស្ត្រាចារ្យព្រមទាំងការខិតខំប្រឹងប្រែងសិក្សារៀនសូត្រ និងការស្តាប់ដំបូន្មានល្អៗពីសំណាក់សិស្សច្បងលោកគ្រូអ្នកគ្រូ សាស្ត្រាចារ្យ នៅក្នុងសាកលវិទ្យាល័យបានធ្វើឲ្យយើងខ្ញុំទាំងពីររូប ទទួលបានការអនុញ្ញាតពីសាកលវិទ្យាល័យ ក្នុងការសរសេរសារណាបញ្ចប់ការសិក្សាក្រោមប្រធានបទ **លំហូរនីតិវិធីក្នុងរឿងក្តីព្រហ្មទណ្ឌ** ។

យើងខ្ញុំទាំងពីរពិតជាមានសេចក្តីសោមនស្សរីករាយណាស់ ដែលបានសរសេរ និងរៀបរៀង សារណារបញ្ចប់ការសិក្សាក្រោមប្រធានបទ **លំហូរនីតិវិធីក្នុងរឿងក្តីព្រហ្មទណ្ឌ** ក្រោមការណែនាំពីលោកគ្រូ **តា សុទ្ធា** ដែលលោកសាស្ត្រាចារ្យបានចំណាយពេលវេលាដ៏មានតម្លៃ ក្នុងការចែករំលែកនូវចំនេះដឹង បទពិសោធន៍ និងដំបូន្មានល្អៗសម្រាប់ជាពុទ្ធិគតិដល់ក្រុមយើងខ្ញុំ ។ សារណាមួយនេះផងដែលគឺជាការស្រាវជ្រាវប្រមូលផ្តុំឯកសារ វិធានច្បាប់ និងនីតិវិធីព្រហ្មទណ្ឌតាមលំដាប់ ពីមន្ត្រីនគរបាលយុត្តិធម៌រហូតដល់ដំណាក់កាលចៅក្រមជម្រះក្តី។

ជាការពិតណាស់នីតិវិធីព្រហ្មទណ្ឌពិតជាមានសារៈសំខាន់ចំពោះអ្នកអនុវត្តច្បាប់ព្រោះវាជាផ្លូវ ជាក្បួនច្បាប់អោយអ្នកអនុវត្តដើរតាម ធ្វើការអនុវត្តត្រឹមត្រូវមានអានុភាព តម្លាភាពនឹងយុត្តិធម៌ ចំពោះជនល្មើស និងជនរងគ្រោះស្មើៗគ្នា។ ការធ្វើសារណាមួយនេះ គឺក្នុងគោលបំណងជួយផ្សព្វផ្សាយពីលំដាប់លំដោយ លំហូរនីតិវិធីក្នុងការងារវិស័យច្បាប់នៅកម្ពុជា និងអាចផ្តល់ជាជំនួយស្មារតីដល់ប្អូនៗ និស្សិតជំនាន់ក្រោយៗទៀត ដើម្បីបង្កើននូវចំណេះដឹងក្នុងការយល់ដឹងអំពីច្បាប់អោយកាន់តែទូលំទូលាយជាងនេះទៅទៀត ។

ជាចុងក្រោយយើងខ្ញុំសង្ឃឹមថា ការខិតខំស្រាវជ្រាវធ្វើសារណាមួយនេះនឹងជួយផ្តល់នូវផលប្រយោជន៍ជាច្រើនដល់ប្អូនៗ និស្សិតជំនាន់ក្រោយៗទៀត ក្នុងការធ្វើការសិក្សាស្រាវជ្រាវទាក់ទងទៅនឹងនីតិវិធីច្បាប់។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ............................................................ ១

## ជំពូកទី១

## ដំណាក់កាលស៊ើបអង្កេត

**ផ្នែកទី១ ដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌** ............................................................ ៦

**១.១. សមាសភាពរបស់មន្ត្រីនគរបាលយុត្តិធម៌** ............................................................ ៧

១.១.១. មន្ត្រីនគរបាលយុត្តិធម៌ ............................................................ ៧

១.១.២. ភ្នាក់ងារនគរបាលយុត្តិធម៌ ............................................................ ៨

១.១.៣. ភ្នាក់ងារសាធារណៈដែលមាននីតិសម្បទា ............................................................ ៩

**១.២. ការស៊ើបអង្កេតបទល្មើសជាក់ស្តែង** ............................................................ ១០

១.២.១. លក្ខខណ្ឌដើម្បីបើកការស៊ើបអង្កេតបទល្មើសជាក់ស្តែង ............................................................ ១០

១.២.២. ដំណើរការស៊ើបអង្កេត ............................................................ ១០

១.២.៣. វិធានការនៃការស្រាវជ្រាវរបស់មន្ត្រីនគរបាលយុត្តិធម៌ ............................................................ ១២

១.២.៤. វិធានក្នុងការឃាត់ខ្លួន ............................................................ ១៤

**១.៣. ការស៊ើបអង្កេតបឋម** ............................................................ ១៧

១.៣.១.វិធាននៃការស្រាវជ្រាវរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងករណីបទល្មើសមិនជាក់ស្តែង ......... ១៧

១.៣.២. វិធានក្នុងការឃាត់ខ្លួន និងបញ្ជូនជនដែលត្រូវបានឃាត់ខ្លួន ............................................................ ១៩

១.៣.៣. វិធានពិសេសក្នុងការស៊ើបអង្កេតករណីបឋម ............................................................ ១៩

**ផ្នែកទី២ ដំណាក់កាលអយ្យការ** ............................................................ ១៩

**២.១. អង្គការអយ្យការ** ............................................................ ២០

២.១.១. អំណាចរបស់អង្គការអយ្យការ ............................................................ ២០

២.១.២. ឋានុក្រមនៃចៅក្រមអយ្យការ ..........២០
២.១.៣. គោលការណ៍នីត្យានុកូភាពនៃការចោទប្រកាន់..........២២
២.១.៤. ការអនុវត្តន៍គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ ..........២២
**២.២. ការធ្វើបណ្តឹងអាជ្ញា**..........២៤
២.២.១. ជម្រើសការចោទប្រកាន់ ..........២៤
២.២.២. ការបើការស៊ើបសួរ ..........២៤
២.២.៣. នីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនផ្ទាល់ ..........២៧
២.២.៥. ការតម្កល់រឿងទុកឥតចាត់ការ ..........២៨

## ជំពូកទី២

## ដំណាក់កាលស៊ើបសួរ

**ផ្នែកទី១ យុត្តាធិការស៊ើបសួរ** ..........៣៣
**១.១ចៅក្រមស៊ើបសួរ**..........៣៣
១.១.១. សមត្ថកិច្ចដែនដី..........៣៣
១.១.២.សមត្ថកិច្ចតាមសាច់រឿង ..........៣៤
**១.២. សភាស៊ើបសួរ** ..........៣៥
**១.៣.ការបើកការស៊ើបសួរ និងការប្តឹងទៅចៅក្រមស៊ើបសួរ**..........៣៦
១.៣.១.ប្រភេទនៃបណ្តឹង..........៣៦
១.៣.២.វិសាលភាពនៃបណ្តឹង ..........៣៦
**១.៤.ការបញ្ចប់ការស៊ើបសួររបស់ចៅក្រមស៊ើបសួរ** ..........៣៧
១.៤.១.ការជូនដំណឹងអំពីកិច្ចបញ្ចប់ការស៊ើបសួរ..........៣៧
១.៤.២.ការបញ្ចប់ការស៊ើបសួរតាមបណ្តឹងសុំរបស់ភាគី ..........៣៧
១.៤.៣.ដីកាដំណោះស្រាយ ..........៣៨

១.៤.៤.អានុភាពនៃដីកាដំណោះស្រាយ ...................................................................................៣៨

**ផ្នែកទី២ សិទ្ធិអំណាចចៅក្រមស៊ើបសួរ**...............................................................................៣៩

**២.១.អំណាចបង្ខំរបស់ចៅក្រម** ............................................................................................៣៩

២.១.១. ការចេញដីកា ...............................................................................................................៣៩

២.១.២. ការដាក់ឲ្យស្ថិតក្រោមការពិនិត្យ.....................................................................................៤២

២.១.៣.ការរក្សារជនត្រូវចោទឲ្យស្ថិតក្រោមការចាត់ចែងរបស់តុលាការ ......................................... ៤៤

**២.២.អំណាចក្នុងការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ** ............................................................ ៤៦

២.២.១. អំណាចរបស់ចៅក្រមស៊ើបសួរ....................................................................................... ៥១

២.២.២.មោឃភាពនៃការស៊ើបសួរ.............................................................................................៥៧

## ជំពូកទី៣

## ដំណាក់កាលជំនុំជម្រះ

**ផ្នែកទី១ យុត្តាធិការជម្រះ** ................................................................................................ ៦០

**១.១.សមត្ថកិច្ច និងការប្តឹងទៅតុលាការ** ................................................................................. ៦០

**១.២.ការរៀបចំសវនាការ** ......................................................................................................... ៦១

១.២.១.ការចាត់តាំងចៅក្រមជំនុំជម្រះ និងកំណត់ពេលសវនាការ ............................................... ៦១

១.២.២.ការកោះហៅចូលសវនាការ ............................................................................................ ៦១

**១.៣. ការពិភាក្សាដេញដោល**...................................................................................................... ៦៤

១.៣.១.សន្តិសុខ និងសណ្តាប់ធ្នាប់................................................................................................ ៦៤

១.៣.២.ដំណើរនៃកិច្ចពិភាក្សាដេញដោល ................................................................................... ៦៥

១.៣.៣.ការដាក់ភស្តុតាងជូនតុលាការពិនិត្យ................................................................................ ៦៦

**១.៤. ការប្រកាសសាលក្រម**..........................................................................................................៦៧

១.៤.១. ការប្រកាសពិរុទ្ធភាព ......................................................................................................៦៨

១.៤.២. ការសម្រេចអំពីផលប្រយោជន៍ផ្នែករដ្ឋប្បវេណី........................................................................... ៦៩
១.៤.៣ ការសម្រេចអំពីវត្ថុចាប់យក ........................................................................................................... ៦៩
**ផ្នែកទី២ អំពីសាលក្រម**.......................................................................................................................... ៦៩
**២.១.ប្រភេទនៃសាលក្រម** .......................................................................................................................... ៧០
**២.២.និទ្ទេសដែលត្រូវចុះជាភាគព្វកិច្ចក្នុងសាលក្រម**.................................................................................. ៧២
**២.៣.ការជូនដំណឹងអំពីសាលក្រម**.............................................................................................................. ៧៣
**ផ្នែទី៣ ប្តឹងតវ៉ា** .......................................................................................................................................... ៧៣
**៣.១ បណ្តឹងតវ៉ាសាមញ្ញ** ............................................................................................................................ ៧៣
៣.១.១. បណ្តឹងទាស់.............................................................................................................................. ៧៣
៣.១.២. បណ្តឹងឧទ្ធរណ៍ .......................................................................................................................... ៧៤
**៣.២ បណ្តឹងតវ៉ាវិសាមញ្ញ** .......................................................................................................................... ៧៦
៣.២.១.បណ្តឹងសាទុក្ខ .............................................................................................................................. ៧៦
៣.២.២.បណ្តឹងសើរើ................................................................................................................................. ៧៧
**សេចក្តីសន្និដ្ឋាន** ....................................................................................................................................... ៧៩
**អនុសាសន៍** ................................................................................................................................................ ៨១
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

នៅប្រទេសយើងសព្វថ្ងៃប្រជាជនគ្រប់រូបទាំងអស់គួរតែយល់ដឹងពីច្បាប់ឲ្យកាន់តែច្បាស់ ដើម្បីធានានៅប្រសិទ្ធភាពនៅក្នុងការអនុវត្ត។ ព្រោះថាគ្រប់ប្រជាជននៅក្នុងសម័យទំនើបទាំងអស់ សុទ្ធតែត្រូវប្រឈមមុខនឹងការយល់ដឹង ការផ្សព្វផ្សាយច្បាប់ ដើម្បីឲ្យការគ្រប់គ្រង និងធានាឲ្យមានសន្តិភាពក្នុងសង្គម។ ជាក់ស្តែងនៅក្នុងឆ្នាំ ២០០៧ រាជរដ្ឋាភិបាលបានបង្កើតឲ្យមាននូវក្រមនីតិវិធីព្រហ្មទណ្ឌ ដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាតាមរយៈព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែ សីហា ឆ្នាំ ២០០៧ ដែលបានអនុម័តដោយរដ្ឋសភានៅថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០៧ ។ នីតិវិធីព្រហ្មទណ្ឌសំដៅលើ ដំណើរការនៃការប្រព្រឹត្តទៅនៅក្នុងការដោះស្រាយរឿងក្តីព្រហ្មទណ្ឌ ហើយវានឹងបង្ហាញដល់អ្នកសិក្សាឲ្យយល់ដឹងពីការអនុវត្តនីតិវិធី និងវិធានទាំងឡាយដែលបានបកស្រាយដោយភាគីដែលបានចូលរួមនៅក្នុងដំណើរការនៃកិច្ចរបស់តុលាការ។ នីតិវិធី និងវិធានទាំងនោះមានប្រភពពីច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់អន្តរជាតិដែលរួមមានសន្ធិសញ្ញា អនុសញ្ញា និងពិធីសារផ្សេងៗទៀត។ ក្រៅពីនោះមានច្បាប់ លិខិតបទដ្ឋានគតិយុត្តដទៃទៀត ដែល សភា និងស្ថាប័ននានារបស់កម្ពុជាបានអនុម័ត។

នៅក្នុងនីតិវិធីព្រហ្មទណ្ឌមានកំណត់យ៉ាងច្បាស់លាស់អំពីទម្រង់នៃបណ្តឹងនិងបែបបទនៃការធ្វើបណ្តឹងដែលមានលក្ខណៈត្រឹមត្រូវតាមផ្លូវច្បាប់ និងការអនុវត្តជាក់ស្តែងនៅក្នុងប្រព័ន្ធយុត្តាធិការនៅប្រទេសកម្ពុជា ។ លំហូរនីតិវិធីនៃរឿងក្តីព្រហ្មទណ្ឌ គឺជាកិច្ចស្រាវជ្រាវដែលបានបង្ហាញអំពីនីតិវិធីនៃរឿងក្តីព្រហ្មទណ្ឌ ដែលរៀបរាប់ចាប់ពី ដំណាក់កាលស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ និងមុខងារនៃអង្គការអយ្យការ ចៅក្រមស៊ើបសួរ រហូតដល់ចៅក្រមជំនុំជម្រះ ចេញសេចក្តីសម្រេច ដែលមានច្រើនដំណាក់កាលទម្រាំនឹងដល់នូវកិច្ចបញ្ចប់ចុងក្រោយ និងដែលរៀបរាប់ អំពីលំហូរនៃនីតិវិធីជំនុំជម្រះនៅសាលាដំបូង(តុលាការជាន់ទាប) ព្រមទាំងការប្តឹងតវ៉ាទៅកាន់សាលាឧទ្ធរណ៍ដែលជាតុលាការជាន់ខ្ពស់។ដំណាក់កាលទាំងអស់នេះមាន លក្ខណៈស្មុគស្មាញ ដោយត្រូវឆ្លងកាត់នូវច្រើននីតិវិធី ហេតុនេះហើយទើបប្រធានបទនេះតម្រូវអោយមានការវែកញែកនៃនីតិវិធីនីមួយៗឲ្យបានច្បាស់លាស់ និងដាច់ដោយឡែកពីគ្នាដើម្បីមានភាពងាយស្រួលនៅក្នុងការសិក្សាស្វែងយល់នូវនីតិវិធីនីមួយៗខាងលើនេះ។

ដូចដែលបញ្ជាក់ខាងលើនេះហើយទើបយើងខ្ញុំធ្វើការបកស្រាយឲ្យបានច្បាស់លាស់បន្ថែមចំពោះចំណុចនីមួយៗ អំពីកិច្ចការសារណានេះទៅតាមកម្រិតថ្នាក់បរិញ្ញាបត្រសម្រាប់និស្សិត អ្នកសិក្សាស្រាវជ្រាវទាំងអស់ដើម្បី

ជាការចែករំលែកជាចំណេះដឹងជូនដល់មិត្តអ្នកសិក្សាស្រាវជ្រាវទាំងឡាយណាដែលមានគោលបំណងចង់សិក្សាស្រាវជ្រាវស្វែងយល់ពីលំហូរនីតិវិធីនៃដោះស្រាយរឿងក្តីព្រហ្មទណ្ឌនេះ ដើម្បីជាចំណេះដឹង និងជាពិសេសសម្រាប់អ្នកដែលចង់ក្លាយខ្លួនជាអ្នកអនុវត្តច្បាប់ផ្នែកយុត្តាធិការជាដើម។

## ២. ចំណោទបញ្ហា

ដើម្បីជាការយល់ដឹងឲ្យបានកាន់តែច្បាស់លាស់ស៊ីជម្រៅនូវលំហូរនីតិវិធីក្នុងការដោះស្រាយរឿងក្តីនៃបណ្តឹងព្រហ្មទណ្ឌ យើងត្រូវដឹងនូវការចំណុចសំខាន់ៗមួយចំនួនដែលជាគោលការណ៍ពាក់ព័ន្ធនឹងដំណើរការនៃនីតិវិធីតួនាទី និងតួអង្គដែលសំខាន់ៗក្នុងដំណើរការនៃនីតិវិធីខាងលើដូចជា៖

- តើដំណើរការរឿងក្តីព្រហ្មទណ្ឌជាអ្វី?
- តើដំណើរការរឿងក្តីព្រហ្មទណ្ឌមានតួអង្គសំខាន់ណាខ្លះ?
- តើតួអង្គសំខាន់ក្នុងដំណើរការរឿងក្តីនោះមានតួនាទីក្នុងការអនុវត្តនីតិវិធីដូចម្តេចខ្លះ?
- តើគេអាចប្តឹងតវ៉ានឹងសេចក្តីសម្រេចបានដែរឬទេ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវមួយនេះមានគោលបំណងក្នុងការចែករំលែកនូវពុទ្ធិចំណេះដឹងខ្លះៗក្នុងការដោះស្រាយរឿងក្តីព្រហ្មទណ្ឌដែលជា នីតិវិធីរបស់តុលាការដែលមានសារៈប្រយោជន៍យ៉ាងសំខាន់ណាស់ក្នុងប្រព័ន្ធយុត្តាធិការនៃព្រះរាជាណាចក្រកម្ពុជា។ កិច្ចការស្រាវជ្រាវមួយនេះ គឺជាស្នាដៃមួយដែលបានតាក់តែងឡើង ដើម្បីទុកជាជំនួយដល់និស្សិតមិត្តអ្នកសិក្សាស្រាវជ្រាវ ដែលចង់ស្វែងយល់ពីដំណើរការរឿងក្តីព្រហ្មទណ្ឌដែលជានីតិវិធីនៃតុលាការរបស់ព្រះរាជាណាចក្រកម្ពុជា។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

កិច្ចការសិក្សាស្រាវជ្រាវនៃសារណាបញ្ចប់ឆ្នាំសិក្សាមួយនេះ ផ្តោតសំខាន់ទៅលើដំណើរការដោះស្រាយរឿងក្តីព្រហ្មទណ្ឌរបស់តុលាការនៃព្រះរាជាណាចក្រកម្ពុជាទៅតាមដំណាក់កាល ចាប់ផ្តើមតាំងពីដំណាក់កាលដំបូង ពោលគឺការដាក់ពាក្យបណ្តឹងរហូតដល់មានការជំនុំជម្រះ ហើយបានចេញនូវសេចក្តីសម្រេចរបស់តុលាការ។ កិច្ចការស្រាវជ្រាវនេះក៏នឹងបង្ហាញអំពីតួនាទី និងភារកិច្ចរបស់តួអង្គនីមួយៗ នៅក្នុងសាលាជម្រះក្តីនៅពេលដែល

ខ្លួនបានទទួលនូវពាក្យបណ្តឹងហើយនឹងមានចំណាត់ការស្របទៅតាមក្រមនីតិវិធីព្រហ្មទណ្ឌ និងវិជ្ជាជីវៈរបស់ខ្លួនទៅតាមមុខងារផ្សេងៗគ្នា។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីទទួលបានឯកសារ និងព័ត៌មានទាំងអស់ដើម្បីយកមកចងក្រងឯកសារ គឺបានឆ្លងកាត់ការស្រាវជ្រាវដោយប្រើប្រាស់ឯកសារជាចម្បងមួយចំនួនដូចជាច្បាប់រដ្ឋធម្មនុញ្ញ ក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩ និងក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧ ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ សៀវភៅមេរៀនដែលសាស្ត្រាចារ្យផ្នែកច្បាប់បានចងក្រង ច្បាប់ពាក់ព័ន្ធផ្សេងៗទៀត និងតាមប្រព័ន្ធអ៊ីនធើណេត ក៏ដូចជាការសាកសួរពិគ្រោះសុំយោបល់ពីសំណាក់លោកសាស្ត្រាចារ្យណែនាំនិងសាស្ត្រាចារ្យច្បាប់នៅសាកលវិទ្យាល័យផ្ទាល់នូវព័ត៌មានដែលពាក់ព័ន្ធទៅនឹងការស្រាវជ្រាវរបស់ប្រធានបទយើងខ្ញុំ។ បន្ទាប់ពីទទួលបានឯកសារ និងព័ត៌មានទាំងអស់នេះហើយគឺត្រូវបានយកមកពិនិត្យមុននឹងជ្រើសរើសមកចងក្រងជាខ្លឹមសារសម្រាប់អត្ថបទមួយនេះ។

## ៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ខ្លឹមសារនៃប្រធានបទនេះ ត្រូវបានបែងចែកដូចខាងក្រោម៖

- **ជំពូកទី១ ដំណាក់កាលស៊ើបអង្កេត**
- **ជំពូកទី២ ដំណាក់កាលនៃការស៊ើបសួរ**
- **ជំពូកទី៣ ដំណាក់កាលជំនុំជម្រះ**

# ជំពូកទី១

# ដំណាក់កាលស៊ើបអង្កេត

# ជំពូកទី១
# ដំណាក់កាលស៊ើបអង្កេត

## ផ្នែកទី១ ដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌

នគរបាលយុត្តិធម៌ ជាជំនួយរបស់អំណាចតុលាការ[1] នគរបាលយុត្តិធម៌ មានភារកិច្ចធ្វើការត្រួតពិនិត្យបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ កំណត់អត្តសញ្ញាណ ចាប់ជនល្មើស ព្រមទាំងប្រមូលភស្តុតាង។

ព្រះរាជអាជ្ញាដឹកនាំនឹងសម្របសម្រួលសកម្មភាពរបស់នគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌នៅក្នុងដែនសមត្ថភាពរបស់ខ្លួន។ ប៉ុន្តែនៅក្នុងការអនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួសមន្ត្រីនគរបាលយុត្តិធម៌ត្រូវស្ថិតក្រោមអំណាចចៅក្រមស៊ើបសួរ[2] ជាងនេះទៅទៀត ក្រមនីតិវិធីព្រហ្មទណ្ឌ បានដាក់នគរបាលយុត្តិធម៌ស្ថិតក្រោមការឃ្លាំមើល និងការត្រួតពិនិត្យរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដែលជាអ្នកអនុវត្តអំណាចខាងវិន័យទៅលើនគរបាលយុត្តិធម៌។[3]

### ១.១. សមាសភាពរបស់មន្ត្រីនគរបាលយុត្តិធម៌

ដោយអនុលោមតាមមាត្រា ៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានកំណត់ពីសមាសភាពរបស់នគរបាលយុត្តិធម៌ ដូចខាងក្រោម៖

- មន្ត្រីនគរបាលយុត្តិធម៌
- ភ្នាក់ងារនគរបាលយុត្តិធម៌
- មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតដែលច្បាប់ដោយឡែកបានប្រគល់អំណាចឲ្យធ្វើការត្រួតពិនិត្យបទល្មើសខ្លះៗ ក្នុងរង្វង់សមត្ថកិច្ចរបស់ខ្លួន ។

ព្រះរាជអាជ្ញា ដឹកនាំ និងសម្របសម្រួលសកម្មភាពការងាររបស់មន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន ហើយមានអំណាចលើមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតកាលណាមន្ត្រីនេះបំពេញមុខងាររបស់ខ្លួនជា នគរបាលយុត្តិធម៌ ។

ក្រៅពីនេះ នគរបាលយុត្តិធម៌ ក៏ស្ថិតនៅក្រោមការឃ្លាំមើល និងការត្រួតពិនិត្យរបស់អង្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ផងដែរ ដោយអង្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍មានសិទ្ធិអនុវត្តអំណាចខាងវិន័យទៅលើនគរបាលយុត្តិធម៌បាន បន្ទាប់ពីមានការរាយការណ៍ពីព្រះរាជអាជ្ញា ឬពីចៅក្រមស៊ើបសួរ ដោយអង្គព្រះរាជ

[1] មាត្រា ៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[2] មាត្រា ៥៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[3] មាត្រា ៥៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

អាជ្ញា ប្រកាស់ជូនដំណឹងដល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬរដ្ឋមន្ត្រីក្រសួងការពារជាតិ ដើម្បីផ្ដើមដំណើរការនីតិវិធីវិន័យ។ ក្រៅពីនេះ អង្គព្រះរាជអាជ្ញា ក៏អាចចេញវិធានការវិន័យដោយផ្ទាល់ទៅលើមន្ត្រីនគរបាលយុត្តិធម៌ដែរ ក្នុងករណីមានកំហុសធ្ងន់ធ្ងរ ក្រោយការកោះហៅមន្ត្រីនគរបាលយុត្តិធម៌នោះមកផ្ដល់សេចក្ដីអង្កេតរួចមក។

### ១.១.១. មន្ត្រីនគរបាលយុត្តិធម៌

សមាសភាពរបស់មន្ត្រីនគរបាលយុត្តិធម៌មានកំណត់នៅ មាត្រា ៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ តាមអត្ថន័យនៃមាត្រានេះ គុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌អាចទទួលបានតាមរបៀប ២ (ពីរ) យ៉ាងគឺ ៖

- តាមការប្រឡងយកសញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌ ។
- តាមមុខងារដែល និង ឋានន្តរស័ក្ដិរបស់មន្ត្រីនគរបាលយុត្តិធម៌ ។

តាមមាត្រា ៦៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ មន្ត្រីនគរបាលយុត្តិធម៌ម្នាក់ៗត្រូវ ស្បថ នៅមុខសាលាឧទ្ធរណ៍ ។

### ១.១.២. ភ្នាក់ងារនគរបាលយុត្តិធម៌

ភ្នាក់ងារនគរបាលយុត្តិធម៌ គឺជានាយនគរបាល ស្នងការ និងអធិការនៃនគរបាលជាតិដែលពុំមានសញ្ញាប័ត្រជាន់ខ្ពស់ខាងផ្នែកនគរបាលយុត្តិធម៌ ភ្នាក់ងារដទៃទៀតរបស់នគរបាលជាតិ នាយកងរាជអាវុធហត្ថដែលពុំមានសញ្ញាប័ត្រជាន់ខ្ពស់ខាងផ្នែកនគរបាលយុត្តិធម៌ និងទាហានដទៃទៀតរបស់កងរាជអាវុធហត្ថ។ ភ្នាក់ងារនីមួយៗត្រូវធ្វើសម្បថនៅចំពោះមុខសាលាដំបូងរាជធានី ខេត្ត តាមប្រកាសចាត់តាំងដោយក្រសួងយុត្តិធម៌ និងក្រសួងពាក់ព័ន្ធ ហើយត្រូវធ្វើសម្បថថាខ្លួននឹងបំពេញមុខងាររបស់ខ្លួនដោយស្មោះត្រង់ ។

ភ្នាក់ងារនគរបាលយុត្តិធម៌មានអំណាចពិនិត្យបទល្មើស។អត្ថបទច្បាប់បានបញ្ជាក់ថាភ្នាក់ងារនគរបាលយុត្តិធម៌មានអំណាចពិនិត្យបទល្មើសលហុជាដើម ។ ភ្នាក់ងារមន្ត្រីនគរបាលយុត្តិធម៌ ជូនដល់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការបំពេញតួនាទីរបស់ខ្លួន ។ កំណត់ហេតុ ឬរបាយការណ៍របស់ភ្នាក់ងារនគរបាលយុត្តិធម៌មានតម្លៃត្រឹមជាព័ត៌មានធម្មតាតែប៉ុណ្ណោះ ។

### ១.១.៣. ភ្នាក់ងារសាធារណៈដែលមាននីតិសម្បទា

ក្នុងចំណោមបេសកកម្មដែល ទទួលបានភ្នាក់ងារសាធារណៈ ជាច្រើនមានបេសកកម្មបង្ការទប់ស្កាត់ការប្រព្រឹត្តអំពើល្មើសទៅលើច្បាប់ដែលគ្រប់គ្រងវិស័យរបស់ខ្លួន ដូចជាពិនិត្យកត់ត្រាការប្រព្រឹត្ត ទាំងនេះជាដើម។ ភ្នាក់ងារនេះក៏ស្ថិតនៅក្រោមអំណាចរបស់ព្រះរាជអាជ្ញា នៅពេលដែលខ្លួនបំពេញតួនាទីជានគរបាលយុត្តិធម៌។ មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈទាំងនេះត្រូវធ្វើសម្បថថានឹងបំពេញតួនាទីដោយស្មោះត្រង់ចំពោះមុខសាលាដំបូង ។

ចំពោះបែបបទ និងនីតិវិធីនៃការផ្តល់នូវនីតិសម្បទាជាភ្នាក់ងារនគរបាលយុត្តិធម៌ ត្រូវបានកំណត់ដោយប្រកាសរួមរបស់ក្រសួងពាក់ព័ន្ធ និងក្រសួងយុត្តិធម៌ ។ ដូចគ្នាទៅនឹងផងដែរ មន្ត្រីរាជការនិងភ្នាក់ងារសាធារណៈក្នុងការបំពេញមុខងាររបស់ខ្លួន របាយការណ៍គឺមានតម្លៃត្រឹមតែជាព័ត៌មានធម្មតាតែប៉ុណ្ណោះ[4] ។

- **កំហុសមន្ត្រីនគរបាលយុត្តិធម៌**

រាល់ការប្រព្រឹត្តកំហុសទាំងឡាយដែលប្រព្រឹត្តដោយមន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត នៅក្នុងពេលបំពេញមុខងាររបស់ខ្លួន ត្រូវតែឲ្យដំណឹងដោយព្រះរាជអាជ្ញា ឬ ដោយចៅក្រមស៊ើបសួរ ជូនចំពោះអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។ អគ្គព្រះរាជអាជ្ញា ប្រកាសប្រាប់ដំណឹងដល់រដ្ឋមន្ត្រី (រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬ រដ្ឋមន្ត្រីក្រសួងការពារជាតិ ចំពោះមន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌) ឬភ្នាក់ងារនោះនៅក្រោមវាទ ដើម្បីចាប់ផ្តើមនីតិវិធីខាងវិន័យ ។ អគ្គព្រះរាជអាជ្ញាត្រូវបានផ្តល់ដំណឹងអំពីចំណាត់ការបន្តនៃនីតិវិធីវិន័យ ។ ទណ្ឌកម្មខាងវិន័យមិនមែនឧបសគ្គដល់ការធ្វើបណ្តឹងអាជ្ញាទេ ប្រសិនបើមានបទល្មើស ត្រូវបានប្រព្រឹត្ត[5] ។

ចំពោះមន្ត្រីនគរបាលយុត្តិធម៌ដែលមានកំហុសទណ្ឌកម្មខាងវិន័យ ដែលត្រូវប្រកាសដោយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ មានសិទ្ធិប្រកាសចេញវិធានការដូចខាងក្រោមនេះ៖

- ហាមឃាត់មិនឲ្យបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ជាស្ថាពរ ។
- ហាមឃាត់មិនឲ្យបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ជាបណ្តោះអាសន្នសម្រាប់រយៈ ពេល ០៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើនបំផុត ។

មុខនឹងចេញសេចក្តីសម្រេចខាងវិន័យខាងលើនេះអង្គព្រះរាជអាជ្ញា ត្រូវកោះហៅមន្ត្រីនគរបាលយុត្តិធម៌ និងកត់ត្រាទុកសេចក្តីសង្ខេបរបស់មន្ត្រីនោះ ។ សាមីខ្លួនអាចរកជំនួយពីមេធាវី ឬពីទីប្រឹក្សាម្នាក់តាមជម្រើសរើសរបស់ខ្លួន ។

ចំពោះសេចក្តីសម្រេចនេះត្រូវមានសំអាងហេតុច្បាស់លាស់ និងត្រូវជូនដំណឹងដល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬរដ្ឋមន្ត្រីក្រសួងការពារជាតិ ។ ចំពោះសេចក្តីសម្រេចប្រកាសវិន័យខាងលើនេះអាចធ្វើបណ្តឹងតវ៉ាទៅកាន់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលរដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចប្រកាសបដិសេធន៍សេចក្តីសម្រេចរបស់អង្គព្រះរាជអាជ្ញា ឬបន្ថយរយៈនៃសេចក្តីសម្រេចនោះ ។

[4] មាត្រា ៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[5] មាត្រា ៦៤ មាត្រា ៧៩ និងមាត្រា ៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

## ១.២. ការស៊ើបអង្កេតបទល្មើសជាក់ស្តែង

មូលដ្ឋានគ្រឹះរបស់ការស៊ើបអង្កេតគឺជាភាពបន្ទាន់ដែលតម្រូវឲ្យមានការប្រមូលនូវភស្តុតាងនៃបទល្មើសដែលនៅមាននៅឡើយ ដែលវាទើបត្រូវបានប្រព្រឹត្តថ្មីៗ ។

ការស៊ើបអង្កេតបទល្មើសជាក់ស្តែង គឺជាដំណាក់កាលដែលពុំអាចឲ្យពេលវេលាណាមួយត្រូវបានបាត់បង់ឡើយ ។ ការយឺតយ៉ាវតែបន្តិចបន្តួចអាចជាមូលហេតុនៃការបាត់នូវតម្រុយនៃពិរុទ្ធភាព ឬ ពិរុទ្ធជន និងស្លាកស្នាមនៃបទល្មើសបាន។ ហេតុនេះហើយទើបក្រមនីតិវិធីព្រហ្មទណ្ឌ បានផ្តល់ឲ្យកម្លាំងសាធារណៈដែលត្រូវប្រឈមនឹងបទល្មើសដែលទើបតែកើតឡើងភ្លាមៗ នូវមធ្យោបាយដ៏មានប្រសិទ្ធិភាពមួយដើម្បីឆ្លើយតបនឹងល្បឿននៃការបាត់បង់នូវតម្រុយភស្តុតាង និងការរត់គេចខ្លួនរបស់ជនប្រព្រឹត្តបទល្មើស ឬអ្នកចូលរួមប្រព្រឹត្តបទល្មើស ។

### ១.២.១. លក្ខខណ្ឌដើម្បីបើកការស៊ើបអង្កេតបទល្មើសជាក់ស្តែង

យោងតាមបទញ្ញត្តិមាត្រា ៨៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងថាៈ ក្នុងករណីមានបទល្មើសឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌ ត្រូវតែគោរពតាមបទប្បញ្ញត្តិនៃមាតិកានេះ ។

មានន័យថានៅចំពោះមុខស្ថានភាពជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌ ត្រូវតែគោរពនូវលក្ខខណ្ឌ នៃការស៊ើបអង្កេតជាក់ស្តែង ក្នុងករណីដែលបទល្មើសប្រព្រឹត្តជាប្រភេទបទល្មើសឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង ។

បទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងគឺជាបទល្មើសដែលកំពុងប្រព្រឹត្តបទល្មើសដែលទើបប្រព្រឹត្តិរួចភ្លាម ។ ក្នុងនោះដែលក្រមនីតិវិធីព្រហ្មទណ្ឌ បានកំណត់និយមន័យបទល្មើដែលត្រូវចាត់ទុកថាបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែងដែលកាលណានៅក្រោយពេលមានបទល្មើសរួចបន្តិចមកជនដែលគេសង្ស័យត្រូវបានសាធារណៈជនស្រែកដេញប្រដាប់ចាប់ប្រកឹងបុគ្គលដែលត្រូវបានគេរកឃើញមានវត្ថុ ឬមានស្លាកស្នាម ឬតម្រុយច្បាស់លាស់ ហើយស៊ីសង្វាក់ផ្សេងទៀត ដែលនាំឲ្យគេសន្និដ្ឋានបានថាបុគ្គលនោះបានប្រព្រឹត្ត ឬបានចូលរួមប្រព្រឹត្តបទល្មើស ។

ត្រូវបានចាត់ទុកដូចជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងដែរ កាលណាបទល្មើសដែលត្រូវបានប្រព្រឹត្តនោះនៅក្នុងទីកន្លែងដែលអ្នកកាន់កាប់នៅទីនេះ សុំឲ្យព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ចូលមកពិនិត្យ ឬភ្នាក់ងារនគរបាលយុត្តិធម៌ ក្នុងករណីដែលគ្មានមន្ត្រីនគរបាលយុត្តិធម៌នៅទីកន្លែងនោះ ។ ហើយភ្នាក់ងារ

នគរបាលយុត្តិធម៌ ត្រូវរាយការណ៍ជាបន្ទាន់ជូនដល់មន្ត្រីនគរបាលយុត្តិធម៌ [6] ។ ក្នុងករណីដែលមានបទល្មើសឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងកើតឡើង គ្រប់បុគ្គលទាំងអស់អាចចាប់ខ្លួនជនល្មើស ហើយនាំខ្លួនជននោះទៅប្រគល់ជូនមន្ត្រីនគរបាលយុត្តិធម៌ដែលនៅជិតបំផុត ។

### ១.២.២. ដំណើរការស៊ើបអង្កេត

ក្នុងករណីដែលមានបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងកើតឡើង មន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ជាបន្ទាន់ដល់ព្រះរាជអាជ្ញា ។ ថេរវេលានៃការស៊ើបអង្កេតបទល្មើសជាក់ស្តែងមិនអាចលើសពី ៧ (ប្រាំពីរ) ថ្ងៃ គិតពីថ្ងៃប្រព្រឹត្តបទល្មើស ។ ក្នុងករណីដែលបទល្មើសត្រូវចាត់ទុក ឬប្រដូចបទល្មើសឧក្រិដ្ឋ ឬមជ្ឈិមជាក់ស្តែង ថេរវេលានៃកាស៊ើបអង្កេតនេះ មិនរាប់បញ្ចូលរយៈពេលចន្លោះរវាងការប្រព្រឹត្តបទល្មើស និងការប្តឹងទៅមន្ត្រីនគរបាលយុត្តិធម៌ ឬព្រះរាជអាជ្ញានោះទេ ។ ថេរវេលានៃការស៊ើបអង្កេតបទល្មើសជាក់ស្តែង ត្រូវគិតពី ថ្ងៃដែលមានការពិនិត្យកត់ត្រាបទល្មើស មិនមែនពីថ្ងៃដែលបទល្មើសប្រព្រឹត្តនោះទេ ។

**ឧទាហរណ៍:** មានករណីយលួចគាស់ផ្ទះមួយយកម៉ូតូបានកើតឡើងនៅថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០១ ដែលម្ចាស់ផ្ទះមិននៅ រហូតដល់ថ្ងៃបន្ទាប់គឺនៅថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០០១ វេលាម៉ោង ១៥ ទើបម្ចាស់ផ្ទះ

ត្រឡប់មកផ្ទះវិញ ទើបដឹងថាមានចោរលួចគាស់ផ្ទះយកម៉ូតូ ។ ម្ចាស់ផ្ទះបានដាក់ពាក្យបណ្តឹង ហើយសមត្ថកិច្ចបានចុះមកពិនិត្យកន្លែងកើតហេតុនៅថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០០១ នៅវេលា ម៉ោង ១៦ និង ០០ នាទី ។ ដូចនេះថិរវេលានៃការស៊ើបអង្កេតត្រូវបានគិតចាប់ពីថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០០១ ។

ដើម្បីឲ្យការស៊ើបអង្កេតនេះអាចធ្វើឡើងក្នុងថិរវេលាកំណត់នេះ ក្រមនីតិវិធីព្រហ្មទណ្ឌចែងអំពីលក្ខខណ្ឌទាមទារបន្ថែម ។ ដូចនេះការស៊ើបអង្កេតត្រូវធ្វើឡើងបន្តបន្ទាប់ក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ បើពុំនោះទេនាំឲ្យមានមោឃភាពនៃនីតិវិធី ។

បទប្បញ្ញត្តិនៃមាត្រា ១០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ជាផ្នែកមួយនៃវិធាន និងទម្រង់ការដែលបានចែង និងនាំឲ្យមានមោឃភាពក្នុងករណីមិនគោរព[7] ។

នៅពេលដែលថេរវេលានេះត្រូវបានបញ្ចប់ ប៉ុន្តែមន្ត្រីនគរបាលយុត្តិធម៌មិនទាន់បញ្ចប់ការស៊ើបអង្កេត មន្ត្រីនេះត្រូវរាយការណ៍ទៅព្រះរាជអាជ្ញា ដែលពិនិត្យពិចារណាវាយតំលៃអំពីភាពចាំបាច់ក្នុងការបន្តការស៊ើបអង្កេតក្នុងក្របខណ្ឌការស៊ើបអង្កេតបឋម ឬការស៊ើបសួរ ឬតម្កល់រឿងទុកមិនចាត់ការ ឬបញ្ជូនរឿងទៅសាលា

[6] មាត្រា ៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[7] មាត្រា ១០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

ជំនុំជម្រះក្តីដោយផ្ទាល់ ។ បើការស៊ើបអង្កេតត្រូវបានបញ្ចប់ កំណត់ហេតុ និងភស្តុតាងត្រូវបញ្ជូនទៅព្រះរាជអាជ្ញា បើពុំនោះទេ នាំឲ្យមានមោឃភាពនៃនីតិវិធី[8] ។ ក្នុងអំឡុងពេលស៊ើបអង្កេត គ្រប់កិច្ចទាំងអស់ត្រូវតក់ត្រានៅនឹងកន្លែងកើតហេតុ ដោយមន្ត្រីនគរបាលយុត្តិធម៌ ដែលដឹកនាំការស៊ើបអង្កេតនេះ ។

ឧទាហរណ៍ៈ កំណត់ហេតុឃាត់ខ្លួនជនសង្ស័យដោយមន្ត្រីនគរបាលយុត្តិធម៌ កំណត់ហេតុស្តីពីការចាប់យកវត្ថុតាំង កំណត់ហេតុស្តីពីការឆែកឆេរ កំណត់ហេតុស្តីពីការពិនិត្យកន្លែងកើតហេតុជាដើម ។

### ១.២.៣. វិធានការនៃការស្រាវជ្រាវរបស់មន្ត្រីនគរបាលយុត្តិធម៌

តាមបញ្ញត្តិមាត្រា ៨៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែងថាៈ ក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌ ត្រូវរាយការណ៍ភ្លាមជូនព្រះរាជអាជ្ញា។ មន្ត្រីនគរបាលយុត្តិធម៌ចុះទៅកាន់ទីកន្លែងកើតហេតុ ដើម្បីធ្វើការពិនិត្យបទល្មើស។ មន្ត្រីនគរបាលយុត្តិធម៌ធានាការពាររក្សាទុកនូវតម្រុយនៃភស្តុតាងទាំងឡាយដែលអាចបាត់បង់។ មន្ត្រីនគរបាលយុត្តិធម៌អាចហាមឃាត់បុគ្គលគ្រប់រូប កុំឲ្យទៅទីណាឆ្ងាយពីកន្លែងបទល្មើស រហូតដល់ពេលបញ្ចប់កិច្ចប្រតិបត្តិការរបស់ខ្លួន ។

ប្រសិនបើយល់ឃើញថាមានប្រយោជន៍ព្រះរាជអាជ្ញាចុះទៅកាន់កន្លែងកើតហេតុ និងដឹកនាំការស៊ើបអង្កេត ។

ប្រសិនបើមានការបន្ទាន់ ព្រះរាជអាជ្ញាអាចអនុញ្ញាតឲ្យមន្ត្រីនគរបាលយុត្តិធម៌ណាម្នាក់ធ្វើប្រតិបត្តិការលើវិសាលភាពទាំងមូលនៃដែនដីជាតិ ដោយគោរពតាមលក្ខខណ្ឌទាំងឡាយដែលមានចែងក្នុងមាត្រា ៦៨ (ការពន្លាតសមត្ថកិច្ចដែនដី) នៃក្រមនេះ ។

មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរបាន ដោយមានបានទទួលការអនុញ្ញាតជាបឋមពី ព្រះរាជអាជ្ញា ទោះបីការអនុញ្ញាតនេះធ្វើឡើងដោយផ្ទាល់មាត់ ឬដោយលាយល័ក្ខណ៍អក្សរក្តី ។ វិធានក្នុងការឆែកឆេរនេះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើឡើងចំពោះមុខអ្នកកាន់កាប់ទីកន្លែង បើគ្មានអ្នកកាន់កាប់ទីកន្លែងទេនោះ ត្រូវធ្វើឡើងចំពោះមុខសាក្សីពីរនាក់ ដែលត្រូវបានចាត់តាំងដោយមន្ត្រីនគរបាលយុត្តិធម៌។ សាក្សីពុំអាចយកនគរបាល ឬកងរាជអាវុធហត្ថ ដែលជាកម្លាំងរួមប្រតិបត្តិការក្នុងការឆែកឆេរនោះបានឡើយ ។

មន្ត្រីនគរបាលយុត្តិធម៌មិនផ្តើមការឆែកឆេរនៅមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ១៨ (ដប់ប្រាំបី) ល្ងាចឡើយ ។ តែចំពោះករណីយដែលមានបទ ល្មើសឧក្រិដ្ឋ ឬមជ្ឈិមជាក់ស្តែង ឬក្នុងករណីដែលចាត់ទុកថាជាបទឧក្រិដ្ឋ ឬបទល្មើសមជ្ឈិមជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរបានដោយពុំចាំបាច់

[8] មាត្រា ១០៧ នៃនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

អនុលោមតាមលក្ខខ័ណ្ឌខាងលើនេះទេ ។ ក្រៅពីនេះក្នុងករណីយដែលមានសម្រែកស្រែកឲ្យគេជួយពីក្នុងកន្លែង ក្នុងករណីដែលពេលម៉ោងដែលបើកចំហរដល់សាធារណជន ក្នុងករណីដែលកន្លែងនោះជាកន្លែងដែលផលិត រក្សាទុក ជួញដូរ ចែកចាយ និងប្រើប្រាស់គ្រឿងញៀន មន្ត្រីនគរបាលអាចធ្វើការឆែកឆេរដោយពុំចាំបាច់គោរព ពេលខាងលើនេះឡើយ[9] ។

មន្ត្រីនគរបាលយុត្តិធម៌ មិនអាចធ្វើការឆែកឆេរនៅក្នុងការិយាល័យមេធាវីបាននោះទេ ការឆែកឆេរនេះ អាចត្រូវបានធ្វើឡើងដោយព្រះរាជអាជ្ញា ឬ ចៅក្រមស៊ើបសួរតែប៉ុណ្ណោះ ដោយធ្វើឡើងនៅ ចំពោះមុខប្រធានគ ណៈមេធាវី ឬ ប្រតិភូរបស់ប្រធានគណៈមេធាវី ឬ មេធាវីសាមុី ។

ក្រៅពីការហាមឃាត់ខាងលើនេះ មន្ត្រីនគរបាលយុត្តិធម៌ក៏មិនអាចធ្វើការឆែកឆេរបានផងដែរ នៅក្នុង អគារសារព័ត៌មាន សហគ្រាសនៃសារព័ត៌មានសរសេរ ឬសហគ្រាសព័ត៌មានសោតទស្សន៍ គឺអាចធ្វើទៅបាននៅ ចំពោះមុខនៃព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរតែម្នាក់ប៉ុណ្ណោះ ហើយព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរត្រូវធានា ដល់ការឆែកឆេរមិនត្រូវឲ្យប៉ះពាល់ដល់ការប្រកបមុខរបរដោយសេរីនៃរបបអ្នកសារព័ត៌មានមិនត្រូវធ្វើឲ្យមាន យឺតយ៉ាវដល់ការផ្សព្វផ្សាយព័ត៌មាននេះឡើយ[10] ។

ក្នុងករណីដែលមន្ត្រីនគរបាលធ្វើការចាប់យកវត្ថុតាងនៃបទល្មើស មន្ត្រីនគរបាលយុត្តិធម៌ត្រូវ ធ្វើការបិទ ស្លាកបោះត្រាលើវត្ថុចាប់យក (វត្ថុតាង) នោះ ។ ការចាប់យកវត្ថុតាងនេះត្រូវយកមកបង្ហាញ អ្នកកាន់កាប់ទី កន្លែង ឬសាក្សីពីរនាក់មើលរួច ធ្វើកំណត់ហេតុចាប់យកវត្ថុតាង ព្រមទាំងចុះបញ្ជីសារពើភ័ណ្ឌនៃវត្ថុចាប់យក នោះ ដោយមានការចុះហត្ថលេខា ឬផ្តិតស្រាមដៃដោយអ្នកកាន់កាប់ទីកន្លែង ឬសាក្សីទាំងពីរនាក់នោះ ។

មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើកោះហៅ ឬមកកាន់អង្គភាពរបស់ខ្លួននូវបុគ្គលគ្រប់រូបដែលសង្ស័យថា បានចូលរួមក្នុងបទល្មើស ។ ការស្តាប់ចម្លើយ (សួរយកចម្លើយ) ត្រូវធ្វើឡើងដោយកំណត់ហេតុរបស់មន្ត្រី នគរបាលយុត្តិធម៌ ។ ក្នុងករណីដែលជនត្រូវបានស្តាប់ចម្លើយជាជនបរទេស ជនគ ថ្លង់ អ្នកបកប្រែត្រូវចាត់តាំង ហើយត្រូវធ្វើសម្បថតាមជំនឿ សាសនារបស់ខ្លួន។ អ្នកបកប្រែមិនអាចជ្រើសរើសចេញពីក្នុងចំណោមនគរបាល ឬកងរាជអាវុធហត្ថដែលរួមសហការក្នុងរឿងក្តីនេះឡើយ ។ មន្ត្រីនគរបាលយុត្តិធម៌ក្រោយពីស្តាប់ចម្លើយរួច ហើយ ត្រូវអានដោយសំលេងខ្លាំងៗ នូវខ្លឹមសារនៃកំណត់ហេតុដល់ជនដែលត្រូវបានស្តាប់ចម្លើយ (និងអ្នកបក ប្រែបើមាន) ហើយឲ្យចុះហត្ថលេខា ឬផ្តិតខ្មៅដៃនៅគ្រប់ទំព័រទាំងអស់នៃកំណត់ហេតុស្តាប់ចម្លើយ ក្នុងករណី ដែលបុគ្គលនោះពុំចុះហត្ថលេខា ឬផ្តិតស្រាមដៃទេនោះ មន្ត្រីនគរបាលត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុអំពីហេតុ ការណ៍នេះ ។

[9] មាត្រា ៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[10] មាត្រា ៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

បុគ្គលដែលត្រូវបានមន្ត្រីនគរបាលយុត្តិធម៌ធ្វើការកោះហៅត្រូវចូលមកបង្ហាញខ្លួនតាមកាលបរិច្ឆេទ ហើយករណីដែលបុគ្គលត្រូវបានកោះហៅនោះ រឹងទទឹងនឹងការកោះហៅ មន្ត្រីនគរបាលអាចស្នើសុំទៅ ព្រះរាជអាជ្ញាដើម្បីឲ្យចេញដីកាបញ្ជាឲ្យចូលខ្លួន ដែលដីកានេះអនុញ្ញាតឲ្យមន្ត្រីនគរបាលយុត្តិធម៌ អាចប្រើប្រាស់កម្លាំងសាធារណៈដើម្បីបង្ខំបុគ្គលនោះ ឲ្យចូលបង្ហាញខ្លួនបាន [11]។

ក្នុងករណីដែលមន្ត្រីនគរបាលយុត្តិធម៌ត្រូវការពិនិត្យបច្ចេកទេស ឬវិទ្យាសាស្ត្រដែលមិនអាចបង្អង់បាន មន្ត្រីនគរបាលយុត្តិធម៌អាចពឹងដល់បុគ្គលគ្រប់រូបដែលមានមុខជំនាញដែលមាន នៅក្នុងបញ្ជីថ្នាក់ជាតិនៃអ្នកជំនាញ បើអ្នកជំនាញពុំស្ថិតនៅក្នុងបញ្ជីថ្នាក់ជាតិ អ្នកជំនាញនោះត្រូវធ្វើសម្បថតាមជំនឿសាសនារបស់ខ្លួននឹងជួយដោយភក្ដីភាពដល់តុលាការ ។

### ១.២.៤. វិធានក្នុងការឃាត់ខ្លួន

មន្ត្រីនគរបាលយុត្តិធម៌ មានសិទ្ធិក្នុងការឃាត់ខ្លួននូវបុគ្គលដែលសង្ស័យថាបានចូលរួមប្រព្រឹត្តបទល្មើស ក្រោយពីបុគ្គលដែលសង្ស័យថាបានប្រព្រឹត្តបទល្មើស បុគ្គលដែលអាចផ្ដល់ព័ត៌មានស្ដីពីបទល្មើស ឬដំណើររឿងហេតុ ក្នុងករណីដែលបុគ្គលនោះអាចផ្ដល់ព័ត៌មានបានតែប្រកែកមិនព្រមផ្ដល់ព័ត៌មាន ឬមានការយល់ព្រមអនុញ្ញាតដែលត្រូវបានឡើងជាលាយល័ក្ខណ៍អក្សរឲ្យធ្វើការឃាត់ខ្លួនពីព្រះរាជអាជ្ញា។

រយៈពេលនៃការឃាត់ខ្លួនមានចិរវេលា ៤៨ (សែសិបប្រាំបី) ម៉ោង ដោយគិតចាប់ពីម៉ោងដែលសាមីខ្លួនបានមកដល់អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ។

ក្នុងបទឧក្រិដ្ឋដែលតម្រុយភស្តុតាងបានបង្ហាញឲ្យឃើញថា មានពិរុទ្ធភាពលើបុគ្គលដែលត្រូវបានឃាត់ខ្លួននោះ ហើយវិធានការនៃការឃាត់ខ្លួនជាភាពចាំបាច់ដើម្បីធ្វើការស៊ើបអង្កេតប្រព្រឹត្តទៅបានល្អ ហើយផុតរយៈដូចបានកំណត់ខាងលើនេះ មន្ត្រីនគរបាលយុត្តិធម៌អាចស្នើសុំធ្វើការពន្យាពេល នៃការឃាត់ខ្លួនបុគ្គលនេះបន្ថែម តែមិនឲ្យលើសពី ២៤ ម៉ោងនោះទេ ហើយត្រូវមានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពីព្រះរាជអាជ្ញា ។ លិខិតដែលអនុញ្ញាតនេះត្រូវមានសំអាងហេតុ និងត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿង ។

ការពន្យាពេលនៃការឃាត់ខ្លួននេះ មិនអាចធ្វើការពន្យាពេលបានឡើយ ប្រសិនបុគ្គលដែលត្រូវបានឃាត់ខ្លួនជាអនីតិជន ហើយរយៈពេលនៃការឃាត់ខ្លួនអនីតិជនអាចត្រូវធ្វើទៅបានក្នុងករណីដូចខាងក្រោមនេះ៖

- ចំពោះបទឧក្រិដ្ឋ អនីតិជនដែលមានអាយុចាប់ពី ១៤ ឆ្នាំ ដល់ក្រោម ១៦ ឆ្នាំ មិនអាចត្រូវបានគេឃាត់ខ្លួនហួសរយៈពេល ៣៦ ម៉ោងឡើយ ។

[11] មាត្រា ៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

- ចំពោះបទមជ្ឈិម អនីតិជនដែលមានអាយុចាប់ពី ១៤ ឆ្នាំ ដល់ក្រោម ១៦ ឆ្នាំ មិនអាចត្រូវបានគេឃាត់ខ្លួនហួសរយៈពេល ២៤ ម៉ោងឡើយ ។
- ចំពោះបទឧក្រិដ្ឋ អនីតិជនដែលមានអាយុចាប់ពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ មិនអាចត្រូវបានគេឃាត់ខ្លួនហួសរយៈពេល ៤៨ ម៉ោងឡើយ ។
- ចំពោះបទមជ្ឈិម អនីតិជនដែលមានអាយុចាប់ពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ មិនអាចត្រូវបានគេឃាត់ខ្លួនហួសរយៈពេល ៣៦ ម៉ោងឡើយ ។

ដោយឡែកអនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំ មិនត្រូវបានធ្វើការឃាត់ខ្លួននោះទេ[12] ។

គ្រប់បុគ្គលដែលត្រូវបានឃាត់ខ្លួន មានសិទ្ធិក្នុងការទទួលបានជំនួយពីមេធាវី ដែលមេធាវី ឬ អ្នកដែលបុគ្គលត្រូវបានជ្រើសរើសដោយបុគ្គលដែលគេឃាត់ខ្លួន(បុគ្គលដែលពុំជាប់ពាក់ព័ន្ធនឹងរឿងក្តី)អាចធ្វើការសន្ទនាជាមួយនឹងបុគ្គលដែលត្រូវបានគេឃាត់ខ្លួនរយៈ ៣០ នាទី ក្នុងល័ក្ខខណ្ឌសំងាត់ក្រោយពេលដែលបុគ្គលនេះត្រូវបានគេឃាត់ខ្លួនរយៈ ២៨ ម៉ោងរួចមក [13]។

ចំពោះអនីតិជនដែលត្រូវបានឃាត់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការជូនដំណឹងដល់ឪពុកម្តាយ អ្នកអាណាព្យាបាល ឬអ្នកដែលទទួលភារកិច្ចលើអនីតិជននោះ ។ ការឃាត់ខ្លួនេះមន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុស្តីពីសរុបនៃការឃាត់ខ្លួនដាក់បញ្ចូលទៅក្នុងសំណុំរឿងព្រហ្មទណ្ឌនោះ[14] ។

### ១.២.៥.វិធាននៃការបញ្ជូនជនដែលត្រូវបាននឃាត់ខ្លួនដល់ព្រះរាជអាជ្ញា

ក្រោយពីផុតរយៈពេលនៃការឃាត់ខ្លួន ហើយមន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការបញ្ជូនជនដែលត្រូវបានឃាត់ខ្លួនទៅព្រះរាជអាជ្ញា បើពុំនោះទេត្រូវដោះលែងជនដែលត្រូវបានឃាត់ខ្លួនឲ្យមានសេរីភាពឡើងវិញ ហើយសេចក្តីសម្រេចនៃការដោះលែងជនត្រូវឃាត់ខ្លួន ត្រូវធ្វើឡើងដោយសេចក្តីសម្រេចរបស់ព្រះរាជអាជ្ញា[15]។

ការបញ្ជូនខ្លួនជនដែលត្រូវបានឃាត់ខ្លួនទៅព្រះរាជអាជ្ញា មានន័យថាបុគ្គលនោះត្រូវបានគេនាំយកទៅបង្ហាញខ្លួនភ្លាមនៅចំពោះមុខព្រះរាជអាជ្ញា ។ ហើយករណីដែលការបញ្ជូនខ្លួនបុគ្គលដែលត្រូវបានគេឃាត់ខ្លួនដែលត្រូវធ្វើការបង្ហាញខ្លួននៅចំពោះមុខព្រះរាជអាជ្ញា ពុំអាចធ្វើឡើងក្នុងថ្ងៃតែមួយបាននោះទេ ដោយសារមូល

[12] មាត្រា ៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧
[13] មាត្រា ៤៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧
[14] មាត្រា ១០២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧
[15] មាត្រា ១០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

ហេតុលំបាកនៃការដឹកជញ្ជូន ឬចម្ងាយផ្លូវនៃការដឹកបញ្ជូន នោះរយៈពេលបន្ថែមអាចត្រូវបន្ថែមឲ្យដោយព្រះរាជអាជ្ញាបាន ។ ហើយការបង្ហាញខ្លួននេះត្រូវធ្វើឡើងក្នុងរយៈដ៏ឆាប់រហ័សបំផុតតាមដែលអាចធ្វើទៅបាន[16] ។

### ១.២.៦. វិធានពិសេសក្នុងការស៊ើបអង្កេតករណីជាក់ស្តែង

មន្ត្រីនគរបាលយុត្តិធម៌ពុំមានអំណាចក្នុងការបង្គាប់ឲ្យស្តាប់និងថតសំលេងការសន្ទនាតាមទូរស័ព្ទ ថតការឆ្លើយឆ្លងដែលចេញតាមមធ្យោបាយទូរគមនាគមន៍ (ដូចជាសារតាមទូរសារ ឬតាមអិនធឺណេត) នោះឡើយ ។

ក្រោយពីរយៈពេលនៃការស៊ើបអង្កេតជាក់ស្តែងត្រូវបានបញ្ចប់ ឬ ការបញ្ចប់នៃការស៊ើបអង្កេតជាក់ស្តែងបានបញ្ចប់ហើយនោះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការបញ្ជូនកំណត់ហេតុ រួមនឹងវត្ថុចាប់យកទាំងអស់ទៅព្រះរាជអាជ្ញា ហើយបុគ្គលដែលត្រូវបានបញ្ជូនទៅព្រះរាជអាជ្ញាមន្ត្រីនគរបាលត្រូវធ្វើការបញ្ជូនទាំងមនុស្ស និងកំណត់ហេតុរួមនឹងវត្ថុតាងទៅផងដែរ ។[17]

មន្ត្រីនគរបាលដែលពុំគោរពតាមវិធាន និងទម្រង់នៃការការស៊ើបអង្កេតជាក់ស្តែងខាងលើនេះទេដែលមាន៖

- កំណត់ហេតុលើការស្រាវជ្រាវ និងការពិនិត្យក្នុងការស៊ើបអង្កេតជាក់ស្តែង
- ការឆែកឆេរក្នុងការស៊ើបអង្កេតជាក់ស្តែង
- ការបិទស្លាកបោះត្រាលើវត្ថុតាងក្នុងការស៊ើបអង្កេតជាក់ស្តែង
- កំណត់ហេតុលើស្តាប់ចម្លើយក្នុងការស៊ើបអង្កេតជាក់ស្តែង
- បទបញ្ជាឲ្យចូលខ្លួនក្នុងករណីស៊ើបអង្កេទបទល្មើសជាក់ស្តែង
- ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬ វិទ្យាសាស្ត្រ
- កំណត់ហេតុស្តីពីការឃាត់ខ្លួន
- ជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួន
- ជំនួយរបស់គ្រូពេទ្យនៅក្នុងពេលឃាត់ខ្លួន
- អនីតិជនដែលត្រូវបានឃាត់ខ្លួន
- ការហាមឃាត់មិនឲ្យស្តាប់ដោយឯកឯង
- ថេរវេលានៃការស៊ើបអង្កេតជាក់ស្តែង

[16] មាត្រា ១០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[17] មាត្រា ១០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

និទ្ទេសដែលត្រូវចុះនៅក្នុងកំណត់ហេតុ និងនាំឲ្យកិច្ចស៊ើបអង្កេតត្រូវជាមោឃភាព ឬមោឃភាពនូវនីតិវិធីស៊ើបអង្កេតនេះ[18] ។

## ១.៣. ការស៊ើបអង្កេតបឋម

ក្នុងករណីដែលបានដឹងអំពីអំពើដែលអាចជាបទឧក្រិដ្ឋ ឬជាបទមជ្ឈិម ឬបទលហុ មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការស៊ើបអង្កេតដោយខ្លួនឯងជាបឋម ឬ តាមការស្នើសុំ (បញ្ជា) របស់ព្រះរាជអាជ្ញា។ ចំពោះវិធានដែលទាក់ទងនឹងការស៊ើបអង្កេតនេះ វិធាននៃការស៊ើបអង្កេតបទល្មើសជាក់ស្តែងត្រូវបានយកមកអនុវត្តន៍។

### ១.៣.១.វិធាននៃការស្រាវជ្រាវរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងករណីបទល្មើសមិនជាក់ស្តែង

មន្ត្រីនគរបាលយុត្តិធម៌ក៏អាចធ្វើការឆែកឆេរ និងចាប់យកវត្ថុតាងបានផងដែល ក្នុងករណីនៃវិធានស៊ើបអង្កេតមិនជាក់ស្តែង ឬស៊ើបអង្កេតបឋម ។ មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរបាន ដោយមានការយល់ព្រមដែលធ្វើឡើងដោយលាយលក្ខណ៍អក្សរ និងសរសេរដោយផ្ទាល់ដៃរបស់អ្នកកាន់កាប់ទីកន្លែង ។ ក្នុងករណីដែលអ្នកកាន់កាប់ទីកន្លែងពុំចេះអក្សរនោះត្រូវសរសេរឲ្យបានច្បាស់លាស់ក្នុងកំណត់ហេតុថា អ្នកកាន់កាប់ទីកន្លែងនោះមិនចេះអក្សរ ហើយយល់ព្រមឲ្យឆែកឆេរ ។

ហើយក្នុងករណីដែលអ្នកកាន់កាប់ទីកន្លែងអវត្តមាន ឬបដិសេធន៍មិនឲ្យធ្វើការឆែកឆេរ មន្ត្រីនគរបាលយុត្តិធម៌អាចស្នើសុំទៅព្រះរាជអាជ្ញា ដែលព្រះរាជអាជ្ញាអាចធ្វើសំណើសុំដីកាអនុញ្ញាតឲ្យធ្វើការឆែកឆេរដែលចេញដោយប្រធានសាលាដំបូង ហើយការដឹកនាំនៃវិធានក្នុងការឆែកឆេរនេះ ត្រូវធ្វើឡើងដោយព្រះរាជអាជ្ញា ។ ការឆែកឆេរនេះត្រូវធ្វើឡើងចំពោះមុខអ្នកកាន់កាប់ទីកន្លែង បើគ្មានអ្នកកាន់កាប់ទីកន្លែងទេនោះ ត្រូវធ្វើឡើងចំពោះមុខសាក្សីពីរនាក់ ដែលត្រូវបានចាត់តាំងដោយព្រះរាជអាជ្ញា ។ សាក្សីពុំអាចយកនគរបាល ឬកងរាជអាវុធហត្ថ ដែលជាកម្លាំងរួមប្រតិបត្តិការក្នុងការឆែកឆេរនោះបានឡើយ ។

ចំពោះការឆែកឆេរនេះ មិនអាចផ្តើមការឆែកឆេរនៅមុខម៉ោង ០៦ (ប្រាំមួយ) ព្រឹក និងក្រោយ ម៉ោង ១៨ (ដប់ប្រាំបី) ល្ងាចឡើយ[19] ។

ក្នុងករណីដែលមន្ត្រីនគរបាលធ្វើការចាប់យកវត្ថុតាងនៃបទល្មើស មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការបិទស្លាកបោះត្រាលើវត្ថុចាប់ (វត្ថុតាង) យកនោះ ។ ការចាប់យកវត្ថុតាងនេះត្រូវយកមកបង្ហាញ អ្នកកាន់កាប់ទី

[18] មាត្រា ១០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[19] មាត្រា ១១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

កន្លែង ឬសាក្សីពីរនាក់មើលរួច ធ្វើកំណត់ហេតុចាប់យកវត្ថុតាង ព្រមទាំងចុះបញ្ជីសារពើភ័ណ្ឌនៃវត្ថុចាប់យកនោះ ដោយមានការចុះហត្ថលេខា ឬ ផ្តិតស្រាមដៃដោយអ្នកកាន់កាប់ទីកន្លែង ឬសាក្សីទាំងពីរនាក់នោះ ។

មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការកោះហៅ ឬនាំមកកាន់អង្គភាពរបស់ខ្លួននូវបុគ្គលគ្រប់រូបដែលសង្ស័យថា បានចូលរួមក្នុងបទល្មើស ឬដែលអាចផ្តល់ព័ត៌មានស្តីពីរឿងក្តីនេះបាន។ ការស្តាប់ចម្លើយ (សួរយកចម្លើយ) ត្រូវធ្វើឡើងដោយកំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌ ។ ក្នុងករណីដែលជនត្រូវបាន ស្តាប់ចម្លើយជាជនបរទេស ជនគ ថ្លង់ អ្នកបកប្រែត្រូវចាត់តាំង ហើយត្រូវធ្វើសម្បថតាមជំនឿសាសនារបស់ខ្លួន។ អ្នកបកប្រែមិនអាចជ្រើសរើសចេញពីក្នុងចំណោមនគរបាល ឬកងរាជអាវុធហត្ថដែលរួមសហការក្នុងរឿងក្តីនេះឡើយ ។ មន្ត្រីនគរបាលយុត្តិធម៌ក្រោយពីស្តាប់ចម្លើយរួចហើយ ត្រូវអានដោយសម្លេងខ្លាំងៗ នូវខ្លឹមសារនៃកំណត់ហេតុដល់ជនដែលត្រូវបានស្តាប់ចម្លើយ (និងអ្នកបកប្រែបើមាន) ហើយឲ្យចុះហត្ថលេខា ឬផ្តិចខ្មៅដៃនៅគ្រប់ទំព័រទាំងអស់នៃកំណត់ហេតុស្តាប់ចម្លើយ ក្នុងករណីដែលបុគ្គលនោះពុំចុះហត្ថលេខា ឬផ្តិចម្រាមដៃទេនោះ មន្ត្រីនគរបាលត្រូវចុះនិទ្ទេស នៅក្នុងកំណត់ហេតុអំពីហេតុការណ៍នេះ[20] ។ បុគ្គលដែលត្រូវបានមន្ត្រីនគរបាលយុត្តិធម៌ ធ្វើការកោះហៅត្រូវចូលមកបង្ហាញខ្លួនតាមកាលបរិច្ឆេទ ហើយករណីដែលបុគ្គលត្រូវបានកោះហៅនោះ រឹងទទឹងនឹងការកោះហៅនេះ មន្ត្រីនគរបាល អាចស្នើសុំទៅព្រះរាជអាជ្ញាដើម្បីឲ្យចេញដីកាបញ្ជាឲ្យចូលខ្លួន ដែលដីកានេះអនុញ្ញាតឲ្យមន្ត្រីនគរបាលយុត្តិធម៌ អាចប្រើប្រាស់កម្លាំងសាធារណៈដើម្បីបង្ខំបុគ្គលនោះឲ្យចូលបង្ហាញខ្លួនបាន[21] ។

### ១.៣.២. វិធានក្នុងការឃាត់ខ្លួន និងបញ្ជូនជនដែលត្រូវបានឃាត់ខ្លួន

វិធានពាក់ព័ន្ធនឹងការឃាត់ខ្លួន និងការបញ្ជូនខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួន ក្នុងការស៊ើបអង្កេតជាក់ស្តែង ត្រូវបានយកមកអនុវត្តក្នុងការស៊ើបអង្កេតបឋម ។

### ១.៣.៣. វិធានពិសេសក្នុងការស៊ើបអង្កេតករណីបឋម

មន្ត្រីនគរបាលដែលពុំគោរពតាមវិធាន និងទម្រង់នៃការការស៊ើបអង្កេតបឋមខាងលើនេះទេដែលមាន៖

- ការឃាត់ខ្លួន
- កំណត់ហេតុនៃការឃាត់ខ្លួន
- អនីតិជនដែលត្រូវបានឃាត់ខ្លួន
- ការហាមឃាត់មិនឲ្យស្តាប់ដោយឯកឯង

---

[20] មាត្រា ១១៤ និងមាត្រា ១១៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[21] មាត្រា ១១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

- ការបញ្ជូនកំណត់ហេតុទៅព្រះរាជអាជ្ញា
- ការឆែកឆេរ
- ការបញ្ជាឲ្យចូលខ្លួន

និងនាំឲ្យកិច្ចស៊ើបអង្កេតត្រូវជាមោឃភាព ឬមោឃភាពនូវនីតិវិធីស៊ើបអង្កេតនេះ[22] ។

# ផ្នែកទី២ ដំណាក់កាលអយ្យការ

ចំពោះការចោទប្រកាន់ គឺជាតួនាទីចាំបាច់របស់ស្ថាប័នអយ្យការ ។ ការចោទប្រកាន់ធ្វើឡើងតាមរយៈបណ្តឹងអាជ្ញា ។ ដោយអនុលោមតាម ១៣១ ថ្មីនៃរដ្ឋធម្មនុញ្ញ បានកំណត់ថា មានតែអង្គការអយ្យការទេ ដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា ។ ព្រះរាជអាជ្ញា ដឹកនាំ និងសម្របសម្រួលសកម្មភាពរបស់មន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន។ ដូចនេះព្រះរាជអាជ្ញាអាចចុះទីកាន់ទីកន្លែងស៊ើបអង្កេត និងធ្វើការណែនាំដែលមានប្រយោជន៍ដល់មន្ត្រីភ្នាក់ងារនគរបាលយុត្តិធម៌ ហើយអាចដកសិទ្ធិស៊ើបអង្កេតពីមន្ត្រីភ្នាក់ងារនគរបាលយុត្តិធម៌ និងរៀបចំឲ្យមានអ្នកជំនួស ។ ម្យ៉ាងវិញទៀត ព្រះរាជអាជ្ញា អាចធ្វើអធិការកិច្ច បានគ្រប់ពេលវេលានៅអង្គភាពនគរបាលយុត្តិធម៌អាចចូលរួមស្តាប់ចម្លើយត្រួតពិនិត្យការអនុវត្តវិធានការឃាត់ខ្លួន ។ ក្រៅពីនេះ ព្រះរាជអាជ្ញា ប្រើប្រាស់អំណាចទាំងអស់ដែលក្រមនីតិវិធីព្រហ្មទណ្ឌនេះ បានទទួលស្គាល់ឲ្យដល់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេត។ ព្រះរាជអាជ្ញារងដែលក្រោមអំណាចរបស់ព្រះរាជអាជ្ញា ប្រើអំណាចទាំងអស់ដែលព្រះរាជអាជ្ញាមាន ក្នុងការស្រាវជ្រាវ និងចោទប្រកាន់បទល្មើស ។

ក្រៅពីអំណាចដឹកនាំសម្របសម្រួលសកម្មភាពមន្ត្រីនគរបាលយុត្តិធម៌ អំណាចនៃការបើកការស៊ើបអង្កេត ព្រះរាជអាជ្ញាមានតួនាទីយ៉ាងសំខាន់ក្នុងការធ្វើបណ្តឹងអាជ្ញាឲ្យមានចលនាមានន័យថា ការចោទប្រកាន់ពីបទល្មើសណាមួយ ។

## ២.១. អង្គការអយ្យការ

### ២.១.១. អំណាចរបស់អង្គការអយ្យការ

អង្គការអយ្យការ ឬស្ថាប័នអយ្យការដែលអមតុលាការខេត្ត-រាជធានី មានតួនាទីក្នុងការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងសន្និដ្ឋានឲ្យតុលាការអនុវត្តច្បាប់តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដីកាកោះហៅបញ្ជូនរឿងឲ្យទៅជំនុំជម្រះផ្ទាល់ ឬដីកាកោះហៅឲ្យចូលបង្ហាញខ្លួនភ្លាម ដីកាសន្និដ្ឋានស្ថាពរ និងការធ្វើ

[22] មាត្រា ១១៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

សេចក្តីថ្លែងការប្តឹងសុំដោយផ្ទាល់មាត់នៅដំណាក់កាលជំនុំជម្រះ ។ អង្គការអយ្យការធានារ៉ាប់រងការអនុវត្ត សេចក្តីសម្រេចខាងបទព្រហ្មទណ្ឌ ព្រមទាំងធានាយកចិត្តទុកដាក់លើការផ្សព្វផ្សាយដីកាបង្គាប់ឲ្យចាប់ខ្លួន ។ មានន័យថាស្ថាប័នអយ្យការ មានតួនាទីអនុវត្តនូវសេចក្តីសម្រេចដែលធ្វើឡើងដោយចៅក្រម ។

**ឧទាហរណ៍**: ការអនុវត្តសាលក្រមតុលាការ ការអនុវត្តន៍ការចាប់ខ្លួនតាមដីកាចាប់ខ្លួន ការផ្សព្វផ្សាយដីកាបង្គាប់ឲ្យចាប់ខ្លួនជាដើម[23] ។

ចៅក្រមអយ្យការពេលបំពេញភារកិច្ចរបស់ខ្លួនមានសិទ្ធិអំណាចក្នុងការកេណ្ឌកងកម្លាំងសាធារណៈដោយផ្ទាល់ជាជំនួយរបស់ខ្លួន ។

នៅពេលសវនាការចៅក្រមអយ្យការត្រូវតែមានវត្តមាននៅក្នុងពេលសវនាការរឿងក្តីព្រហ្មទណ្ឌ ការដែលអវត្តមានតំណាងអយ្យការ នាំឲ្យមានមោឃភាពនីតិវិធី ។

### ២.១.២. ឋានុក្រមនៃចៅក្រមអយ្យការ

ចៅក្រមអយ្យការត្រូវបានកំណត់នៅឋានុក្រមដូចខាងក្រោមនេះ[24]៖

- អង្គព្រះរាជអាជ្ញា អង្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូល ។
- អង្គព្រះរាជអាជ្ញា អង្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។
- ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងអមសាលាដំបូង ។

អង្គព្រះរាជអាជ្ញា អង្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូល គឺជាតំណាងនៃស្ថាប័នមហាអយ្យការយ្យការអមតុលាការកំពូល ។ អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល មានតួនាទីក្នុងការចូលរួមក្នុងការស្នើសុំឲ្យមានការគោរពច្បាប់ នៅក្នុងពេលដែលមានបណ្តឹងសារទុក្ខ បណ្តឹងសើរើ និងបណ្តឹងតវ៉ាផ្សេងៗទៀត ដែលដាក់ជូនតុលាការកំពូលពិនិត្យ[25] ។

អង្គព្រះរាជអាជ្ញា អង្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ គឺជាតំណាងស្ថាប័នមហាអយ្យការអមសាលាឧទ្ធរណ៍ ។ អង្គព្រះរាជអាជ្ញា ឃ្លាំមើលការអនុវត្តច្បាប់នៅក្នុងសមត្ថកិច្ចដែនដីនៃសាលាឧទ្ធរណ៍ ។ អង្គព្រះរាជអាជ្ញា អាចធ្វើអធិការកិច្ចនៅអង្គភាពអយ្យការទាំងឡាយដែលស្ថិតនៅក្រោមសមត្ថកិច្ចដែន

[23] មាត្រា ២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[24] មាត្រា ២៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[25] មាត្រា ៣១ និងមាត្រា ៣២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

ដីរបស់ខ្លួន ។ ក្នុងករណីដែលមានបទល្មើសធ្ងន់ធ្ងរកើតឡើង ព្រះរាជអាជ្ញាត្រូវធ្វើការរាយការណ៍ទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌[26] ។ អង្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ធ្វើការឃ្លាំមើល និងការត្រួតពិនិត្យនគរបាលយុត្តិធម៌ ។

អង្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អាចកោះអញ្ជើញអ្នកទទួលខុសត្រូវនៃអង្គភាពនគរបាលយុត្តិធម៌ ដើម្បីពិភាក្សាអំពីបញ្ហាដែលទាក់ទងនឹងការប្រព្រឹត្តិទៅរបស់អង្គភាពនគរបាលទាំងនេះ។ អង្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍អាចប្រគល់ភារកិច្ចដល់មន្ត្រី ឬភ្នាក់ងារនគរបាលគ្រប់គ្រង ឬដំណើរការដ៏ល្អនៃនគរបាលយុត្តិធម៌។

អង្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អាចធ្វើអធិការកិច្ចគ្រប់ពេលវេលានៅអង្គភាពនគរបាលយុត្តិធម៌។ អង្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អាចចូលរួមក្នុងការស្តាប់ចម្លើយ ត្រួតពិនិត្យការអនុវត្តវិធានការឃាត់ខ្លួនជាពិសេសគឺគោរពទម្រង់ច្បាប់ និងការកាន់កាប់គ្រប់គ្រងកន្លែងឃាត់ខ្លួន ។ ប្រធានអង្គភាពនគរបាលយុត្តិធម៌ មន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តិធម៌ត្រូវគោរពតាមអធិបញ្ញារបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍តាមដែនសមត្ថកិច្ចរបស់ខ្លួន[27] ។

ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងអមសាលាដំបូង គឺជាតំណាងរបស់អង្គភាពអយ្យការអមតុលាការ[28] ។ ព្រះរាជអាជ្ញា ដឹកនាំ និងសម្របសម្រួលសកម្មភាពរបស់មន្ត្រីនគរបាលយុត្តិធម៌ទាំងអស់នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន។ ប៉ុន្តែកាលណាអនុវត្តដីកាឲ្យស៊ើបសួរជំនួស មន្ត្រីនគរបាលយុត្តិធម៌ ត្រូវស្ថិតនៅក្រោមអំណាចរបស់ចៅក្រមស៊ើបសួរ។ ព្រះរាជអាជ្ញាប្រើប្រាស់អំណាច ដែលក្រមនីតិវិធីព្រហ្មទណ្ឌបានផ្តល់ឲ្យទៅមន្ត្រីនគរបាលយុត្តិធម៌។ មានន័យថាមន្ត្រីនគរបាលយុត្តិធម៌អនុវត្តអំណាចទាំងអស់ដែលព្រះរាជអាជ្ញាបានផ្តល់ឲ្យ។ ព្រះរាជអាជ្ញាអាចចុះទៅកាន់កន្លែងស៊ើបអង្កេត និងធ្វើការណែនាំដែលមានប្រយោជន៍ដល់មន្ត្រីនិងភ្នាក់ងារនគរបាលយុត្តិធម៌។ ក្នុងករណីចាំបាច់ពិសេស ព្រះរាជអាជ្ញាអាចដកសិទ្ធិស៊ើបអង្កេតរបស់មន្ត្រីនិងភ្នាក់ងារនគរបាលយុត្តិធម៌ហើយរៀបចំជំនួសមន្ត្រីនិងភ្នាក់ងារនេះ ។

ព្រះរាជអាជ្ញាអាចធ្វើអធិការកិច្ចបានគ្រប់ពេលវេលានៅអង្គភាពនគរបាលយុត្តិធម៌ ។ ព្រះរាជអាជ្ញាអាចចូលរួមក្នុងការស្តាប់ចម្លើយ ត្រួតពិនិត្យការអនុវត្តវិធានការឃាត់ខ្លួន ជាពិសេសគឺការពទម្រង់ច្បាប់ និងការកាន់

[26] មាត្រា ៣៣ និងមាត្រា ៣៤ នៃក្រមនីរីធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[27] មាត្រា ៣៥ នៃក្រមនិតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[28] មាត្រា ៣៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

កាប់ទីកន្លែងឃាត់ខ្លួន[29] ។ ព្រះរាជអាជ្ញារងដែលស្ថិតនៅក្រោមអំណាចរបស់ព្រះរាជអាជ្ញា ប្រើប្រាស់អំណាចទាំងអស់ដែលព្រះរាជអាជ្ញាមានក្នុងការស្រាវជ្រាវ និងការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌ ។

នៅពេលមានពាក្យបណ្តឹងបរិហារដែលបានប្តឹងចូលមកស្ថាប័នអយ្យការដោយផ្ទាល់ ឬពាក្យបណ្តឹងដែលទទួលបានដោយមន្ត្រីនគរបាលយុត្តិធម៌បញ្ជូនមក ព្រះរាជអាជ្ញាត្រូវធ្វើការថ្លឹងថ្លែងអំពីចំណាច់ការលើពាក្យបណ្តឹង ដែលនាំឲ្យមានការចោទប្រកាន់ ឬតម្កល់ទុកឥតចាត់ការនូវបទល្មើសព្រហ្មទណ្ឌ ។ ហើយមុននឹងធ្វើចោទប្រកាន់ ឬតម្កល់ទុកឥតចាត់ការ ព្រះរាជអាជ្ញាអាចធ្វើការស៊ើបអង្កេតបឋម ឬបង្គាប់ឲ្យធ្វើការស្រាវជ្រាវបន្ថែម[30] ។

### ២.១.៣. គោលការណ៍នីត្យានុកូលភាពនៃការចោទប្រកាន់

នៅមុនពេលអនុវត្តក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧ ការចោទប្រកាន់របស់អង្គការអយ្យការត្រូវ បានគេជ្រើសរើសតាមគោលការណ៍នីត្យានុកូលភាពនៃការចោទប្រកាន់ ។

គោលការណ៍នេះមានន័យថាកាលណារឿងព្រហ្មទណ្ឌមួយត្រូវបានប្តឹងមកមន្ទីរអយ្យការ ព្រះរាជអាជ្ញាត្រូវតែសម្រេចចាត់ការបណ្តឹងនោះឲ្យតែបទល្មើស ដែលត្រូវបានប្តឹងនោះមានធាតុផ្សំខាងអង្គហេតុ និងអង្គច្បាប់គ្រប់គ្រាន់ដោយព្រះរាជអាជ្ញាមិនត្រូវគិតដល់កាលៈទេសៈអ្វីផ្សេងទៀតទេ។ គោលការណ៍នេះមានប្រភពចេញពីគោលការណ៍ដែលថា គ្មានបទល្មើសដែលគ្មានច្បាប់បង្ក្រាប និងគ្មានទោស ដោយគ្មានទោសបញ្ញត្តិ ។

### ២.១.៤. ការអនុវត្តន៍គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់

ក្រោយពីក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧ ត្រូវបានអនុវត្ត គោលការណ៍នីត្យានុកូលភាពនៃការចោទប្រកាន់មិនត្រូវបានគេលើកយកមកអនុវត្តទៀតនោះទេ ដោយហេតុថាក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧ បានលើកនូវគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់មកអនុវត្តជំនួសវិញ ។

គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ ដែលត្រូវបានបញ្ចូលនៅក្នុងក្រមនីតិវិធីថ្មីនេះ ជាយន្តការទំនើបកម្មនៃនីតិក្នុងបរិបទកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា ។ គោលការណ៍នេះស្របទៅនឹងចរន្តពិភពលោកដែលកំពុងមានការផ្តោតអារម្មណ៍ និងយកចិត្តទុកដាក់ ហើយកំពុងត្រូវបានអនុវត្តនៅតាមបណ្តាប្រទេសជឿនលឿន ។

[29] មាត្រា ៣៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[30] មាត្រា ៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

ការអនុវត្តគោលការណ៍នេះ ត្រូវបានបញ្ញត្តិដោយក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧ ដែលជាគោលការណ៍មួយពុំធ្លាប់ត្រូវបានអនុវត្តនៅកម្ពុជានាពេលកន្លងមកនោះទេ គោលការណ៍ដែលត្រូវបានអនុវត្តនៅប្រទេសកម្ពុជាចាប់តាំងពីពេលដែលមាននីតិព្រហ្មទណ្ឌនាយុគ្គសម័យមុនៗ រហូតមកដល់មុនពេលអនុម័តក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧ គឺប្រទេសកម្ពុជាបានអនុវត្តគោលការណ៍នីត្យានុកូលភាពនៃការចោទប្រកាន់ ដោយតាមរយៈនេះស្ថាប័នទទួលបន្ទុកចោទប្រកាន់នូវរឿងក្តីព្រហ្មទណ្ឌត្រូវបានចាប់បង្ខំដោយនីតិឲ្យធ្វើការចោទប្រកាន់គ្រប់រឿងក្តីទាំងឡាយដែលមានចរិតលក្ខណៈជាបទល្មើសព្រហ្មទណ្ឌដោយមិនគិតអំពីស្ថានភាពនៃបទល្មើស ឬបរិបទសង្គម ឬតាមរបៀបមនុស្សធម៌នោះទេ ។ ផ្ទុយមកវិញ គោលការណ៍ថ្មីខាងលើនេះ ស្ថាប័នចោទប្រកាន់បទល្មើស ត្រូវបានផ្តល់ឲ្យដោយច្បាប់នូវអំណាចនៃជម្រើសក្នុងការចោទប្រកាន់ទោះបីជាអង្គហេតុទាំងនោះមានចរិតលក្ខណៈជាបទល្មើសព្រហ្មទណ្ឌក៏ដោយ ។ ប៉ុន្តែអំណាចដែលផ្តល់ឲ្យដោយច្បាប់នេះពុំមានស្ថានភាពទូលំទូលាយហួសហេតុដែលអាចធ្វើបានតាមទំនើងចិត្តទេត្រូវបានកម្រិតដោយលក្ខខណ្ឌគតិយុត្តមួយចំនួន ។

គោលការណ៍នេះ ត្រូវបានវិស័យនីតិនិពន្ធតាក់តែងឡើងដើម្បីបង្កើតនូវវិធានកណ្តាលនៃការចោទប្រកាន់ដោយប្រគល់ឲ្យស្ថាប័នចោទប្រកាន់ ពោលគឺស្ថាប័នអយ្យការនូវជម្រើសដ៏សំខាន់ក្នុងការធ្វើចំណាត់ការសំណុំរឿងក្តីព្រហ្មទណ្ឌ ។ តាមរយៈគោលការណ៍នេះអនុញ្ញាតឲ្យស្ថាប័នអយ្យការមានជម្រើសមិនធ្វើការចោទប្រកាន់ ទោះបីអំពើដែលបរិហារនោះជាបទល្មើសព្រហ្មទណ្ឌក៏ដោយ ។ ជម្រើសមិនចោទប្រកាន់នេះសម្តែងចេញតាមការរយៈសេចក្តីសម្រេចតម្កល់រឿងទុកមិនចាត់ការ ផ្អែកទៅលើការវាយតម្លៃរបស់ព្រះរាជអាជ្ញាតែមួយគត់ ។ ដូចគ្នាដែរ ក្នុងករណីដែលមានអំពើច្រើនដែលត្រូវ បានប្តឹងមកនោះមានការពាក់ព័ន្ធក្នុងអង្គហេតុមួយ ព្រះរាជអាជ្ញាមានជម្រើសធ្វើការចោទប្រកាន់នៅអំពើណាមួយ ហើយមិនចោទប្រកាន់នូវអំពើផ្សេងទៀត ។ គោលការណ៍នេះ ក៏បានអនុញ្ញាតឲ្យស្ថាប័នអយ្យការនូវសេរីភាព ក្នុងការជ្រើសរើសមធ្យោបាយធ្វើបណ្តឹងអាជ្ញាកាលបើច្បាប់មិនបានចែងថា ការបើកការស៊ើបសួរតាមផ្លូវយុត្តាធិការស៊ើបសួរមានលក្ខណៈដាច់ខាតនោះទេ។

**ឧទាហរណ៍**: មានករណីមួយដែលជនល្មើសជាជនដែលមានជីវភាពក្រីក្រ គាត់បានលួចបេះផ្លែស្វាយរបស់អ្នកភូមិមួយ ដើម្បីចម្អែតក្រពះ ។ តាមរយៈសកម្មភាពរបស់ជនល្មើសបានឆ្លើយតបនឹងនិយមន័យនៃអំពើលួចតាមបញ្ញត្តិមាត្រា ៣៥៣ នៃក្រមព្រហ្មទណ្ឌ ដែលចែងថាៈ អំពើលួច គឺជាអំពើដកហូតដោយទុច្ចរិតនូវទ្រព្យសម្បត្តិ ឬ វត្ថុផ្សេងទៀតរបស់អ្នកដទៃ តាមគ្រប់មធ្យោបាយក្នុងគោលបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន ។ បើយើងអនុវត្តតាមគោលការណ៍នីត្យានុកូលនៃការចោទប្រកាន់ជនល្មើសនេះនឹងត្រូវចោទប្រកាន់ដោយ ស្ថាប័នអយ្យការ ក៏ប៉ុន្តែបើយើងអនុវត្តតាមគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់វិញដោយផ្អែកតាមស្ថានភាពរបស់ជនល្មើស ព្យាសនកម្មនៃអំពើល្មើសវិញនោះ ជនល្មើសនេះអាចត្រូវបានស្ថាប័នអយ្យការតម្កល់រឿងទុកឥតចាត់ការបាន ។

## ២.២. ការធ្វើបណ្តឹងអាជ្ញា

### ២.២.១. ជម្រើសការចោទប្រកាន់

ការអនុវត្តន៍តាមគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ ព្រះរាជអាជ្ញាមានជម្រើសមធ្យោបាយនៃការចោទប្រកាន់អាស្រ័យទៅលើស្ថានភាពនៃសំណុំរឿង នីតិវិធីដែលរួចរាល់ អាចបញ្ជូនទៅតុលាការជំនុំជម្រះ ឬផ្ទុយទៅវិញ តម្រូវឲ្យមានការស៊ើបសួរទូលំទូលាយ ពោល គឺអាចប្តឹងទៅយុត្តាធិការជំនុំជម្រះ ឬប្តឹងទៅយុត្តាធិការស៊ើបសួរ ។ ការចោទប្រកាន់ខាងបទព្រហ្មទណ្ឌអាចធ្វើតាមមធ្យោបាយពីរជាអាទិ៍ ៖

១-ការប្តឹងទៅយុត្តាធិការស៊ើបសួរ គឺការបើកធ្វើការស៊ើបសួរ

២-ការប្តឹងទៅយុត្តាធិការជំនុំជម្រះ ប្តឹងតាមរបៀបពីរ គឺ៖

- ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬ
- តាមនីតិវិធីបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម[31] ។

### ២.២.២. ការបើកការស៊ើបសួរ

ដោយព្រះរាជអាជ្ញាចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ គឺជាដីកាដែលព្រះរាជអាជ្ញាប្តឹងទៅចៅក្រមស៊ើបសួរឱ្យធ្វើការស៊ើបសួរលើអង្គហេតុដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ។ ដីកាបញ្ជូនរឿងឱ្យស៊ើបសួរត្រូវមាននិទ្ទេសដូចកំណត់ហេតុក្នុងមាត្រា ៤៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ពោលគឺ ៖

- សេចក្តីសង្ខេបនៃអង្គហេតុ
- ការកំណត់ឈ្មោះបទល្មើស (ឧទាហរណ៍ ៖ អំពើលួច ឃាតកម្ម ជាដើម)
- ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស និង
ចៅក្រមស៊ើបសួរអាចកែប្រែខ្លឹមសារនៃកាតព្វកិច្ច អាចលុបចោល ឬបញ្ចូលកាតព្វកិច្ចថ្មីបាន គ្រប់ពេលវេលា ហើយក៏អាចបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការផងដែរ ។ សេចក្តីសម្រេចនេះត្រូវជូន ដំណឹងក្នុងរយៈពេលដ៏ខ្លីបំផុតដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ ។

➢ **ការកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការដោយព្រះរាជអាជ្ញា**

នៅគ្រប់ពេលវេលាទាំងអស់ ព្រះរាជអាជ្ញាអាចសុំឲ្យលើកលែង ឬកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការ ហើយចៅក្រមស៊ើបសួរត្រូវតែសម្រេចក្នុងរយៈពេល ៥ ថ្ងៃ ។ បើសិនជារយៈពេល ៥ ថ្ងៃនេះ កន្លងផុតទៅ ចៅក្រមស៊ើបសួរមិនបានសម្រេច ព្រះរាជអាជ្ញាអាចប្តឹងសុំតាមរយៈពាក្យសុំទៅសភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរវិញ ។ ដីកាសម្រេចបដិសេធនឹងពាក្យសុំរបស់ព្រះរាជអាជ្ញា ត្រូវតែមានសំអាងហេតុ និងត្រូវជូនដំណឹង ក្នុងរយៈពេលខ្លីបំផុតដល់ព្រះរាជអាជ្ញា ។

➢ **ការកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការដោយជនត្រូវចោទ**

ជនត្រូវចោទអាចដាក់ពាក្យសុំឲ្យលើកលែង ឬកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលា ចៅក្រមស៊ើបសួរត្រូវបញ្ជូនពាក្យសុំរបស់ជនត្រូវចោទនោះភ្លាម និងសំណុំរឿងទៅព្រះរាជអាជ្ញា ដើម្បីពិនិត្យ និងផ្តល់យោបល់ ។ ចៅក្រមស៊ើបសួរសម្រេចយ៉ាងយូរបំផុតក្នុងរយៈពេល ៥ ថ្ងៃ បន្ទាប់ពីការបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា ។ ដីកានេះត្រូវជូនដំណឹងក្នុងពេលខ្លីបំផុតទៅព្រះរាជអាជ្ញា និងជនត្រូវចោទ ។

កាលណាមានពាក្យសុំឲ្យលើកលែង ឬ ឲ្យកែប្រែការត្រួតពិនិត្យនេះបានធ្វើជាថ្មីមុនពេលចៅក្រមស៊ើបសួរ ឬសភាស៊ើបសួរសម្រេចលើពាក្យសុំលើកមុន នោះរយៈពេល ៥ ថ្ងៃនេះ ត្រូវចាប់ផ្តើមគិតពី ពេលចេញសេចក្តីសម្រេចលើពាក្យសុំពីមុន ។ ដីកាសម្រេចបដិសេធនឹងពាក្យសុំត្រូវតែមានសំអាងហេតុ។

បើសិនជារយៈពេល ៥ ថ្ងៃនេះកន្លងផុតទៅ ចៅក្រមស៊ើបសួរមិនបានសម្រេច ជនត្រូវចោទអាចធ្វើពាក្យប្តឹងផ្ទាល់ទៅសភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរវិញ ។

➢ **ការគេចវេសពីកាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ**

ប្រសិនបើជនត្រូវចោទបានគេចវេសដោយចេតនាពីកាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ ចៅក្រមស៊ើបសួរអាចសម្រេចឃុំខ្លួនបណ្តោះអាសន្នបានទោះក្នុងករណីដែលៈ

- ទោសជាប់ពន្ធនាគារដែលត្រូវរងនោះ មានថិរវេលាប៉ុន្មានក៏ដោយ (មានន័យថាលក្ខខណ្ឌនៃមាត្រា ២០៤ លែងជាឧបសគ្គនៃការឃុំខ្លួនបណ្តោះអាសន្នទៀតហើយ) ។
- ជនត្រូវចោទត្រូវបានឃុំខ្លួនបណ្តោះអាសន្នអស់រយៈពេលអតិបរមានៃថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន តាមមាត្រា ២០៨ ២០៩ ២១០ ២១៣ និង២១៤ ក៏ដោយ ។

កាលណាសម្រេចថានឹងឃុំខ្លួនបណ្តោះអាសន្នដោយមូលហេតុខាងលើនេះ ចៅក្រមស៊ើបសួរ ត្រូវជូនដំណឹងដល់ជនត្រូវចោទ និងទទួលការកត់សម្គាល់របស់ជននេះ ហើយតម្រូវឲ្យមានមេធាវីជូនមធ្យោបាយការពារបើសិនជាមានមេធាវីអមផងនោះ ។

ដីកាសម្រេចត្រូវមានសំអាងហេតុ និងត្រូវជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ ។ ការឃុំខ្លួនបណ្តោះអាសន្នដែលសម្រេចតាមមាត្រា ២៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌនេះ មិនអាចឲ្យលើសពី ៤ ខែ ចំពោះនីតិជន និងមិនអាចលើសពី ២ ខែ ចំពោះអនីតិជនឡើយ ។

ការត្រួតពិនិត្យតាមផ្លូវតុលាការត្រូវបានបញ្ចប់នៅពេលដែលចៅក្រមស៊ើបសួរចេញដីកាដំណោះប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចរក្សាទុកជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការហូតដល់ពេលបង្ហាញខ្លួននៅចំពោះមុខតុលាការនោះទេ[34] ។ ការត្រួតពិនិត្យតាមផ្លូវតុលាការ ក៏ត្រូវបញ្ចប់នៅពេលដែលតុលាការប្រកាសសាលក្រមដែរ[35] ។

## ២.២.អំណាចក្នុងការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ

### ២.២.១. អំណាចរបស់ចៅក្រមស៊ើបសួរ

ដោយអនុលោមតាមបញ្ញត្តិមាត្រា ១២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចែងថាៈ

ចៅក្រមស៊ើបសួរបំពេញកិច្ចស៊ើបសួរទាំងអស់ដែលខ្លួនយល់ឃើញថាមានប្រយោជន៍សម្រាប់បង្ហាញឲ្យឃើញការពិតដោយអនុលោមតាមច្បាប់ ។ ចៅក្រមស៊ើបសួរមានករណីកិច្ចស៊ើបសួរទាំងដាក់បន្ទុក និងដោះបន្ទុក ។

ដូចនេះមានន័យថា ចៅក្រមស៊ើបសួរដឹកនាំដោយសេរី និងឯករាជ្យនូវកិច្ចស៊ើបសួររបស់ខ្លួន និងមិនទទួលអធិបញ្ញាពីភាគី ឬអាជ្ញាធរណាមួយឡើយ ។ កិច្ចស្រាវជ្រាវដែលធ្វើដោយចៅក្រមស៊ើបសួរ មិនមានសភាពខុសប្លែកពីកិច្ចដែលបំពេញដោយនគរបាលយុត្តិធម៌ ។

ដើម្បីអោយការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ ប្រកបដោយភាពរលូនជោគជ័យល្អ ច្បាប់បានកំណត់អំណាចចៅក្រមក្នុងការស្រាវជ្រាវដូចជាៈ ការជូនដំណឹងអំការពីការដាក់អោយស្ថិតនៅក្រោមការពិនិត្យ ការសួរចម្លើយជនត្រូវចោទ ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី សាក្សី ការសួរតទល់ ការចុះទៅដល់កន្លែងកើតហេតុ ការឆែកឆេរ និងការចាប់យកវត្ថុតាង ការធ្វើកោសល្យវិច័យ ការស្តាប់ទូរស័ព្ទ ការចាត់អោយស៊ើបជំនួស ។

[34] មាត្រា ២៨៩ កថាខណ្ឌទី ៤ ៥ និងទី ៦ នៃក្រមនីតិព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[35] មាត្រា ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

- **ការជូនដំណឹងអំពីការដាក់អោយស្ថិតនៅក្រោមការពិនិត្យ**

នៅពេលចូលបង្ហាញខ្លួនលើកដំបូង ចៅក្រមស៊ើបសួរពិនិត្យអត្តសញ្ញាណជនត្រូវចោទ ប្រាប់ជននេះឱ្យបានដឹងរឿងរ៉ាវដែលចោទប្រកាន់ និងប្រាប់អំពីឈ្មោះបទល្មើសដែលកំណត់ដោយច្បាប់ ។ ចៅក្រមស៊ើបសួរប្រាប់ជនត្រូវចោទថាខ្លួនអាចឆ្លើយ ឬមិនឆ្លើយបានដោយសេរី។ និទ្ទេសស្តីពីការប្រាប់នេះត្រូវចុះនៅក្នុងកំណត់ហេតុនៅពេលចូលបង្ហាញខ្លួនលើកដំបូង។

ប្រសិនបើជនត្រូវចោទចង់ឆ្លើយនោះ ចៅក្រមស៊ើបសួរត្រូវទទួលចម្លើយនោះភ្លាម។ ចៅក្រមស៊ើបសួរប្រាប់ជនត្រូវចោទឱ្យបានដឹងអំពីសិទ្ធិរបស់ខ្លួនក្នុងការជ្រើសរើសមេធាវី ឬក្នុងការសុំឱ្យចាត់តាំងមេធាវីឱ្យខ្លួនដោយអនុវត្តតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។ ជនត្រូវចោទជាអនីតិជនត្រូវតែមានមេធាវីអមជានិច្ច។ បើគ្មានការជ្រើសរើសដោយជនត្រូវចោទទេ មេធាវីត្រូវបានចាត់តាំងនៅក្នុងលក្ខខណ្ឌដែលចែងដោយច្បាប់ស្តីអំពីលក្ខន្តិកៈមេធាវី ។ ក្រោយពីការចូលបង្ហាញខ្លួនលើកទីមួយ ជនត្រូវចោទដែលនៅក្រៅឃុំ ត្រូវប្រកាសប្រាប់ដល់ចៅក្រមស៊ើបសួរអំពីអាសយដ្ឋានរបស់ខ្លួន។

- **ការសួរចម្លើយជនត្រូវចោទ**

ជនត្រូវជនដែលត្រូវបានចូលបង្ហាញខ្លួនដំបូងនៅសាលាដំបូងនៃយុត្តាធិការស៊ើបសួរ ជនត្រូវចោទមានសិទ្ធិ ក្នុងជ្រើសតាំងមេធាវីដោយខ្លួនឯង ឬដោយការចាត់តាំងរបស់ប្រធានសាលាដំបូងស្របតាមលក្ខន្តិកៈមេធាវី។

ជនត្រូវចោទដែលមានមេធាវីអម ចៅក្រមស៊ើបសួរទៅធ្វើការកោះហៅមេធាវីយ៉ាងតិចបំផុត ០៥ ថ្ងៃមុនពេលសួរចម្លើយ ។ ក្នុងចិរវេលានេះ មេធាវីអាចពិនិត្យមើលសំណុំរឿងនៃនីតិវិធីបាន ។ ជនត្រូវចោទអាចត្រូវបានចៅក្រមស៊ើបសួរសួរយកចម្លើយបានតែចំពោះមុខមេធាវីការពារសិទ្ធិរបស់ជនត្រូវចោទតែប៉ុណ្ណោះ ។ ប៉ុន្តែបើមេធាវីដែលត្រូវបានកោះហៅយ៉ាងត្រឹមត្រូវហើយមិនបានចូលបង្ហាញខ្លួននៅថ្ងៃ និងម៉ោងកំណត់ទេ ចៅក្រមស៊ើបសួរអាចសួរយកចម្លើយជនត្រូវចោទដោយគ្មានវត្តមានរបស់មេធាវីបាន ។ ក្នុងករណីពិសេស ចៅក្រមស៊ើបសួរក៏អាចសួរយកចម្លើយជនត្រូវចោទបានផងដែរ ប្រសិនបើជនត្រូវចោទបានបោះបង់នូវសិទ្ធិការពារខ្លួន ឬ បោះបង់ចោលយ៉ាងជាក់លាក់នូវវត្តមានរបស់មេធាវីខ្លួននោះ ។ ការបោះបង់ចោលនេះត្រូវចុះក្នុងកំណត់ហេតុមួយផ្សេងពីកំណត់ហេតុសួរចម្លើយ និងត្រូវចុះហត្ថលេខាដោយជនត្រូវចោទ ។ ក្នុងករណីបន្ទាន់ ចៅក្រមស៊ើបសួរក៏អាចធ្វើការសួរចម្លើយដោយមិនបាច់កោះហៅមេធាវីបានផងដែរ ដែលភាពបន្ទាន់បណ្តាលមកពីគ្រោះថ្នាក់ដល់ស្លាប់ ឬបណ្តាលមកពីការភ័យខ្លាចបាត់បង់តម្រុយនៃភស្តុតាង ។ ប្រភេទនៃភាពបន្ទាន់នេះត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុ ។ ជនត្រូវចោទអាចត្រូវអមដោយអ្នកបកប្រែ ឬត្រូវបានប្រធានសាលាដំបូងចាត់តាំងអ្នកបកប្រែឲ្យផងដែរ ។[36]

[36] មាត្រា ១៤៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

ព្រះរាជអាជ្ញាត្រូវបានអញ្ជើញឲ្យចូលរួមក្នុងនីតិវិធីនៃការសួរយកចម្លើយជនត្រូវចោទផងដែរ ។ ក្នុងករណីដែលព្រះរាជអាជ្ញាបានចូលរួមក្នុងនីតិវិធីនៃការសួរយកចម្លើយជនត្រូវចោទ ព្រះរាជអាជ្ញា និង មេធាវីរបស់ជនត្រូវចោទ អាចតាំងសំណួរដោយមានការអនុញ្ញាតពីចៅក្រមស៊ើបសួរ ហើយក្នុងករណីមិនត្រូវបានអនុញ្ញាតដោយចៅក្រមស៊ើបសួរទេ ហេតុនេះត្រូវចុះក្នុងនិទ្ទេសនៃកំណត់ហេតុ ។[37]

- **ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី សាក្សី**

ដើមបណ្តឹងរដ្ឋប្បវេណី គឺជាភាគីនៃការស៊ើបសួរ ។ ដើមបណ្តឹងរដ្ឋប្បវេណី មានសិទ្ធទទួលជំនួយពីមេធាវីក្នុងពេលកំពុងស្តាប់ចម្លើយដោយចៅក្រមស៊ើបសួរ ដូច្នេះមេធាវីត្រូវទទួលការកោះហៅក្នុងចិរវេលា ៥ ថ្ងៃមុនការស្តាប់ចម្លើយមានសិទ្ធិពិនិត្យមើលសំណុំរឿងក្នុងថេរវេលានេះ និងអាចទទួលបាននូវឯកសារចំលង និងលិខិតផ្សេងៗនៃនីតិវិធី ដោយចេញសោហ៊ុយខ្លួនឯងដោយមានការអនុញ្ញាតពីចៅក្រម ។ ការស្តាប់ចម្លើយអាចធ្វើដោយពុំចាំបាច់មានវត្តមានរបស់មេធាវី ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណីបោះបង់ចោលយ៉ាងជាក់លាក់នូវវត្តមានរបស់មេធាវីរបស់ខ្លួន និងពុំចាំបាច់កោះហៅមេធាវីក្នុងករណីបន្ទាន់ (គ្រោះថ្នាក់ដល់អាយុជីវិត ហានិភ័យនៃការបាត់បង់តម្រុយភស្តុតាង) ។

ចំពោះបុគ្គលដែលស្ថិតនៅក្រៅអង្គហេតុដែលជាកម្មវត្ថុនៃការចោទប្រកាន់ និងអាចផ្តល់ព័ត៌មានដែលជាប្រយោជន៍ដល់ការបង្ហាញការពិតទៅចៅក្រមស៊ើបសួរ ចៅក្រមស៊ើបសួរអាចកោះហៅបុគ្គលទាំងនោះមកសាកសួរជាសាក្សី ។

សាក្សីមានកាតព្វកិច្ច ៣ យ៉ាងចូលមកបង្ហាញខ្លួន ធ្វើពាក្យសម្បថ (ត្រូវរួចផុតពីសម្បថបុគ្គលដែលជិតស្និតជាមួយជនត្រូវចោទ ដូចជាបុព្វញាតិ បច្ឆាញាតិ បងប្អូន សហពន្ធ័ និងកូនដែលមានអាយុចាប់ពី ១៦ ឡើងទៅ[38] និងផ្តល់ចម្លើយ ។ សាក្សីបដិសេធមិនបង្ហាញខ្លួន ចៅក្រមស៊ើបសួរ សុំឲ្យកំលាំងសារធារណៈបង្ខំសាក្សីឲ្យចូលមកបង្ហាញខ្លួនដោយចេញបញ្ជាឲ្យចូលបង្ហាញខ្លួនដែលមានចុះពីអត្តសញ្ញាណរបស់សាក្សី កាលបរិច្ឆេទចេញបញ្ជា ហត្ថលេខា និងត្រារបស់ចៅក្រម ។

ក្នុងករណីចាំបាច់ចៅក្រមស៊ើបសួរអាចកោះហៅអ្នកបកប្រែដើម្បីស្តាប់ចម្លើយសាក្សី ។

បើសាក្សីមានជំងឺ ឬ មិនអាចធ្វើដំណើរមកបាន ចៅក្រមស៊ើបសួរ និងក្រឡាបញ្ជីអាចទៅកាន់ផ្ទះរបស់សាក្សី ឬកន្លែងដែលសាក្សីនោះនៅដើម្បីទទួលយកចម្លើយ ។ សាក្សីមិនមែនជាភាគីនៃការស៊ើបសួរគាត់មិន

[37] មាត្រា ១៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[38] មាត្រា ១៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

ទទួលបាននូវសិទ្ធិការពារខ្លួន ដូច្នេះសាក្សីត្រូវបានស្តាប់ចម្លើយតែម្នាក់ឯង ដោយចៅក្រមស៊ើបសួរ ។ ប៉ុន្តែគាត់អាចជាកម្មវត្ថុនៃការសួរតទល់គ្នាជាមួយនឹងភាគីក្នុងសំណុំរឿង ។

➢ **ការសួរតទល់**

ការសួរតទល់គ្នាអាចឲ្យនិយមន័យបានថាជាការសួរចម្លើយ ឬការស្តាប់ចម្លើយបុគ្គលជាច្រើនព្រមគ្នាក្នុងគោលដៅធ្វើឲ្យលេចចេញនូវធាតុនៃការពិតតាមរយៈយោបល់ និងជំហររបស់បុគ្គលម្នាក់ៗ ដែលចៅក្រមដាក់តទល់គ្នានោះ ។ បទបញ្ញត្តិដែលគ្រប់គ្រងការសួរចម្លើយជនត្រូវចោទត្រូវយកមកអនុវត្ត ។

➢ **ការចុះទៅដល់ទីកន្លែងកើតហេតុ**

មាត្រា ១៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងថា កាចុះដល់ទីកន្លែងឆ្លើយតបទៅនឹងគោលដៅតែមួយដូចក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេតរបស់នគរបាលយុត្តិធម៌ដែរ ដូចជាធ្វើការពិនិត្យកត់ត្រា ផ្គុំអង្គហេតុឡើងវិញ ឆែកឆេរ ឬបំពេញគ្រប់កិច្ចស៊ើបសួរផ្សេងទៀតទាំងអស់ ។ ដើម្បីបំពេញគ្រប់កិច្ចស៊ើបសួរ ចៅក្រមអាចចុះដល់ទីកន្លែងជាមួយក្រឡាបញ្ជីនៅលើវិសាលភាពនៃសមត្ថកិច្ចដែនដីរបស់សាលាដំបូងដើម្បីបំពេញកិច្ចស៊ើបសួរដែលខ្លួនយល់ឃើញថាមានប្រយោជន៍ ។ ចៅក្រមស៊ើបសួរត្រូវ ជូនដំណឹងទៅព្រះរាជអាជ្ញាដែលអាចចូលរួមដំណើរជាមួយខ្លួនបាន ។ ក្រឡាបញ្ជីជាជំនួយក្នុងការចុះដល់ទីកន្លែង ចៅក្រមស៊ើបសួរត្រូវធ្វើកំណត់ហេតុស្តីពីការចុះដល់ទីកន្លែងនិងស្តីពីកិច្ចដែលបានបំពេញនៅនឹងកន្លែង ។

ម្យ៉ាងទៀតបើការចាំបាច់នៃការស៊ើបសួរតម្រូវចៅក្រមស៊ើបសួរអាចចុះដល់ទីកន្លែងជាមួយនឹងក្រឡាបញ្ជីនៅលើវិសាលភាពដែនដីជាតិទាំងមូល ដោយជូនដំណឹងជាមុនទៅព្រះរាជអាជ្ញាអមសាលាដំបូង នៅក្នុងដែនដីដែលខ្លួនធ្វើដំណើរទៅកាន់នោះ ។

➢ **ការឆែកឆេរ និងការចាប់យកវត្ថុតាង**

ចៅក្រមស៊ើបសួរត្រូវឆែកឆេរនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬបើគ្មានអ្នកកាន់កាប់ទេ ត្រូវធ្វើនៅចំពោះមុនសាក្សី ២នាក់ ដែលខ្លួនចាត់តាំង ។ សាក្សីមិនអាចជានគរបាល ឬជាកងរាជអាវុធហត្ថ ដែលជាកងកម្លាំងរួមប្រតិបត្តិការក្នុងការឆែកឆេរនោះបានឡើយ ។ ចៅក្រមស៊ើបសួរមិនអាចផ្តើមឆែកឆេរមុនម៉ោង ៦ ព្រឹក និងក្រោយម៉ោង ១៨ ល្ងាចបានទេ លើកលែងតែ ៖

- ក្នុងករណីឆែកឆេរនៅទីកន្លែងដែលបើកចំហដល់សាធារណៈជន

- ក្នុងករណីឆែកឆេរនៅគ្រប់ទីកន្លែងដែលផលិត រក្សាទុក ជួញដូរ ចែកចាយ ឬប្រើដែលកាប្រាស់គ្រឿងញៀន។

ការឆែកឆេរនៅក្នុងការិយាល័យមេធាវី ត្រូវធ្វើនៅចំពោះមុខប្រធានគណៈមេធាវី ឬប្រតិភូរបស់ប្រធានគណៈមេធាវីនោះ។ ចៅក្រមស៊ើបសួរត្រូវធ្វើកំណត់ហេតុ ស្តីពីការឆែកឆេរដោយមានចុះហត្ថលេខារបស់ខ្លួន និងក្រឡាបញ្ជី រួមជាមួយអ្នកកាន់កាប់ទីកន្លែង ឬ សក្សី ២ នាក់។ កំណត់ហេតុត្រូវចុះនិទ្ទេស អំពីអត្តសញ្ញាណរបស់អ្នកកាន់កាប់ទីកន្លែង ឬសាក្សីនីមួយៗ ។ កាលបើការឆែកឆេរប្រព្រឹត្តទៅនៅក្នុងការិយាល័យមេធាវី កំណត់ហេតុត្រូវចុះនិទ្ទេសអំពីវត្តមានរបស់ប្រធានគណៈមេធាវី ឬរបស់ប្រតិភូនៃប្រធានគណៈមេធាវីនោះ។

➢ **ការធ្វើកោសលវិច័យ**

នៅក្នុងករណីមានបញ្ហាបច្ចេកទេសចោទឡើង ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យធ្វើកោសលវិច័យដោយឯកឯង ឬតាមពាក្យសុំរបស់ព្រះរាជអាជ្ញារបស់ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី។ កាលណាចៅក្រមស៊ើបសួរបដិសេធ មិនព្រមធ្វើតាមពាក្យសុំធ្វើកោសលវិច័យទេ ចៅក្រមស៊ើបសួរត្រូវសម្រេចតាមដីកាដោយមានសំអាងហេតុ។ ដីកាត្រូវសម្រេចក្នុងរយៈពេល ៥ ថ្ងៃ ប្រសិនបើពាក្យសុំនោះចេញមកពីព្រះរាជអាជ្ញា និង ១ ខែ ប្រសិនបើពាក្យនោះចេញមកពីជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី ។ ដីកាសម្រេចនេះត្រូវជូនដំណឹងឱ្យដល់អ្នកប្តឹងសុំជាបន្ទាន់ ។

➢ **ការស្តាប់ទូរស័ព្ទ**

តាមតម្រូវការចាំបាច់ដើម្បីសំដែងឱ្យឃើញនូវការពិត ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យស្តាប់ និងថតការសន្ទនាតាមទូរស័ព្ទ។ ចៅក្រមស៊ើបសួរក៏អាចបង្គាប់ឱ្យចាប់ និងថតគ្រប់ការឆ្លើយឆ្លងគ្នាតាមមធ្យោបាយទូរគមនាគមន៍ផងដែរដូចជា សារតាមទូរស័ព្ទ ឬសារតាមអ៊ិនធើណេត។

ចៅក្រមស៊ើបសួរអាចសុំឱ្យគ្រប់អង្គភាពសាធារណៈ ឬគ្រប់មន្ត្រីរាជការជំនាញ តាំងឧបករណ៍បច្ចេកទេស និងធ្វើការថត ។ ចៅក្រមស៊ើបសួរបញ្ជាក់នៅក្នុងដីកាសម្រេចរបស់ខ្លួន អំពីប្រភេទនៃទំនាក់ទំនងដែលត្រូវចាប់ព្រមទាំងអំពីរយៈពេលនៃបេសកកម្ម ។ អង្គភាពសាធារណៈ មន្ត្រីរាជការដែលចាត់តាំង ត្រូវបំពេញតាមពាក្យសុំរបស់ចៅក្រមស៊ើបសួរ ។ នៅក្នុងពេលអនុវត្តបេសកកម្មអង្គភាពសាធារណៈ ឬគ្រប់មន្ត្រីរាជការដែលចាត់តាំង ត្រូវជូនព័ត៌មានដល់ចៅក្រមស៊ើបសួរអំពីការប្រព្រឹត្តិទៅនៃបេសកកម្ម ជាអាទិ៍ អំពីការលំបាកជាយថាហេតុ ។ កាលណាបេសកកម្មត្រូវបានបំពេញរួចហើយ អង្គភាពសាធារណៈ ឬគ្រប់មន្ត្រីរាជការនោះត្រូវចម្លងជាលាយលក្ខណ៍អក្សរនូវសំឡេងដែលថតបាន។ការធ្វើឱ្យទៅជាលាយលក្ខណ៍អក្សរនេះត្រូវ ឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនូវខ្លឹមសារនៃសំឡេងដែលថតបាន ។ សំឡេងដែលថតបាននេះត្រូវប្រគល់ជូនចៅក្រមស៊ើបសួរ និងបិទស្លាក។

គ្រប់ពេលវេលាចៅក្រមស៊ើបសួរអាចចុះទៅកាន់ទីកន្លែងដែលធ្វើការចាប់ និងចតនេះបាន។ ការចូលទៅក្នុងទីកន្លែងទាំងនេះ មិនអាចត្រូវបានហាមឃាត់ដល់ចៅក្រមស៊ើបសួរដោយសំអាងលើមូលហេតុអ្វីបានទេ ទោះបីជាទីកន្លែងយោធាក៏ដោយ។ ចៅក្រមស៊ើបសួរក៏អាចធ្វើកិច្ចការនេះតាមដីកាចាត់ឱ្យស៊ើបសួរជំនួសបានដែរ ។

➢ **ដីកាចាត់ឲ្យស៊ើបសួរជំនួស**

ដីកាចាត់ឲ្យស៊ើបសួរជំនួសអាចឲ្យនិយមន័យបានថា ជាប្រតិភូកម្មនៃអំណាចដែលចៅក្រមស៊ើបសួរប្រគល់ឲ្យទៅ ចៅក្រមផ្សេង ឬមន្ត្រីនគរបាលយុត្តិធម៌ ឬអង្គភាពនគរបាល ដើម្បីអនុវត្តកិច្ចស៊ើបសួរមួយ ឬច្រើនដែលចៅក្រមស៊ើបសួរកំណត់ ។[39]

ដោយមានន័យថាជាប្រតិភូកម្មអំណាច ដីកាចាត់ឲ្យស៊ើបសួរជំនួសអាចចេញតែដើម្បីផ្ទេរអំណាចដែលចៅក្រមមានប៉ុណ្ណោះ ។ ដីកាចាត់ឲ្យសួរសាក្សីក៏ត្រូវគ្រប់គ្រងដោយគោលការណ៍មួយដែលចែងថា ដីកាមិនអាចមានលក្ខណៈទូទៅទេ ។ ព្រោះថាក្នុងករណីនេះ គឺវាដោះបន្ទុកចៅក្រមស៊ើបសួរពីសំណុំរឿងក្តី ។ ចៅក្រមអាចបញ្ឈប់ដីកាចាត់ឲ្យស៊ើបសួរជំនួសបានគ្រប់ពេលវេលា និងមុនពេលដែលការអនុវត្តដីកានេះត្រូវបញ្ចប់ ។

ដីកាចាត់ឲ្យស៊ើបសួរជំនួសដែលត្រូវតែពិសេសជាដាច់ខាត ត្រូវតែបញ្ជាក់ឲ្យច្បាស់លាស់នូវកិច្ចដែលអនុញ្ញាត ព្រមទាំងថិរវេលានៃការកិច្ចទាំងនេះ ។ កិច្ចនេះត្រូវមានទំនាក់ទំនងដោយផ្ទាល់ជាមួយបទល្មើសដែលចោទប្រកាន់ ។ ដីកាត្រូវតែមានចុះកាលបរិច្ឆេទ ហត្ថលេខា និងត្រារបស់ចៅក្រម ។

ការភ្លេចនិទ្ទេសមួយក្នុងចំណោមនិទ្ទេសទាំងអស់នេះ អាចបណ្តាលឲ្យមានមោឃភាពនៃដីកាចាត់ឲ្យស៊ើបសួរជំនួស និងមោឃភាពនៃគ្រប់កិច្ចដែលបានធ្វើបន្តបន្ទាប់ ។

នៅពេលដែលដីកាចាត់ឲ្យស៊ើបសួរជំនួស ត្រូវបានប្រគល់ឲ្យចៅក្រម ចៅក្រមរូបនេះមានគ្រប់អំណាចទាំងអស់របស់ចៅក្រមស៊ើបសួរ ។

ក្នុងចំណោមនគរបាល និងកងរាជអាវុធហត្ថមានតែមន្ត្រីនគរបាលយុត្តិធម៌ប៉ុណ្ណោះ ដែលអាចទទួលបានការផ្ទេរបែបនេះ ។ ចៅក្រមស៊ើបសួរអាចចាត់តាំងមន្ត្រីនគរបាលយុត្តិធម៌ដែលមានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ព្រមទាំងគ្រប់មន្ត្រីនគរបាលយុត្តិធម៌លើដែនដីប្រទេសទាំងមូល ។ មន្ត្រីនគរបាលយុត្តិធម៌នេះស្ថិតនៅក្រោមអំណាចផ្ទាល់របស់ចៅក្រមស៊ើបសួរក្នុងក្របខ័ណ្ឌនៃការអនុវត្តនីកាចាត់ឲ្យស៊ើបសួរជំនួស ។

ប៉ុន្តែចៅក្រមស៊ើបសួរមិនអាចផ្ទេរអំណាចរបស់ខ្លួនបានទេ ។ អំណាចដែលមិនអាចត្រូវបានផ្ទេរទៅឲ្យមន្ត្រីនគរបាលយុត្តិធម៌ គឺជាអំណាចចោទប្រកាន់បុគ្គលណាម្នាក់ អំណាចសួរចម្លើយជនត្រូវចោទ ឬស្តាប់

[39] មាត្រា ១៧៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី[40] អំណាចសួរតទល់បុគ្គលខាងលើជាមួយមនុស្សផ្សេងទៀត ឬអំណាចចេញដីកា ឬធ្វើការឆែកឆេរក្នុងកន្លែងដែលការពារ ។

អំណាចដែលអាចផ្ទេរបានគឺៈ

- ស្តាប់ចម្លើយសាក្សី បើក្នុងពេលស្តាប់ចម្លើយ មានលេចចេញនូវតំរុយពិរុទ្ធភាពប្រឆាំង និងសាក្សី ការស្តាប់ចម្លើយត្រូវបញ្ចប់ដើម្បីឲ្យមន្ត្រីនគរបាលយុត្តិធម៌ផ្តល់ដំណឹងភ្លាមទៅចៅក្រសើុបសួរ ។
- ការឆែកឆេរ និងការចាប់វត្ថុដោយគោរពលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ១៥៩ និង ១៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។
- ការឃាត់ខ្លួន អំណាចត្រួតពិនិត្យដែលធ្វើដោយព្រះរាជអាជ្ញាក្នុងក្របខណ្ឌនៃការស៊ើបអង្កេតតាមផ្លូវតុលាការ ត្រូវធ្វើដោយចៅក្រមស៊ើបសួរនៅពេលឃាត់ខ្លួនក្នុងក្របខ័ណ្ឌនៃការចាត់ឲ្យស៊ើបសួរជំនួស។
- ការស្តាប់ និងការថតការសន្ទនាតាមទូស័ព្ទ និងការចាប់ការឆ្លងឆ្លើយតាមមធ្យោបាយទូរគមនាគមន៍ ។

ការពិតណាស់ត្រូវធ្វើកំណត់ហេតុស្តីអំពីគ្រប់កិច្ចដែលបំពេញដោយអនុវត្តតាមដីកាចាត់ឲ្យស៊ើបសួរជំនួស ដែលត្រូវប្រគល់ឲ្យចៅក្រមស៊ើបសួរដើម្បីបញ្ចូនក្នុងសំណុំរឿងនៅពេលដែលកិច្ចត្រូវបានបំពេញចប់ ។

### ២.២.២.មោឃភាពនៃការស៊ើបសួរ

វិធាន និងច្បាប់ប្បញ្ញត្តិទូទៅនៃនីតិវិធីចៅក្រមស៊ើបសួរដាច់ខាតត្រូវតែគោរព បើពុំដូច្នេះទេនាំឲ្យមានការមោឃភាពនៃការស៊ើបសួរជាក់ជាមិនខាន។ ក្នុងនោះក៏មានអ្នកដែលមានសិទ្ធិក្នុងការប្តឹងសុំមោឃភាពក្នុងកិច្ចនីតិវិធី និងភាពដែលមិនអាចទទួលយកបាននៃពាក្យសុំមោឃកម្ម ផងដែរ។

មានតែសភាស៊ើបសួរប៉ុណ្ណោះ ដែលមានសមត្ថកិច្ចដើម្បីពិនិត្យមោឃភាពនៃលិខិតនៃនីតិវិធី[41] ប៉ុន្តែការធ្វើមោឃកម្មចំពោះកិច្ច ឬនីតិវិធីណាមួយចំពោះនីតិវិធីបង្គាប់ឲ្យបង្ហាញខ្លួនភ្លាម និងនីតិវិធីកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ជាសមត្ថកិច្ចរបស់តុលាការជាន់ដំបូង[42] ។

ការស្នើសុំធ្វើមោឃកម្មចំពោះកិច្ចនីតិវិធីស៊ើបសួរអាចធ្វើបានតែមុនយុត្តាធិការជំនុំជម្រះប៉ុណ្ណោះ។ ដីកាដំណោះស្រាយដែលចូលជាស្ថាពរ លុបលាងមោឃភាពនៃនីតិវិធីមុន ដោយគ្មានមោឃភាពណាមួយនៃនីតិវិធីមុន អាចត្រូវបានលើកឡើងនៅចំពោះមុខតុលាការជំនុំជម្រះបានទៀតឡើយ ។[43]

---

[40] មាត្រា ១៧១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[41] មាត្រា ២៥៣ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[42] មាត្រា ៣៤២ និង៤៩២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[43] មាត្រា ២៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

ដីកាដែលអាចធ្វើបណ្តឹងឧទ្ធរណ៍បានមិនអាចជាកម្មវត្ថុនៃការសុំធ្វើអោយកម្មបានទេ ។ តាមមាត្រា ២៥៣ កថាខណ្ឌទី៦ បានកំណត់ថា "ដីកាដែលអាចត្រូវប្តឹងឧទ្ធរណ៍បាន មិនអាចជាកម្មវត្ថុនៃបណ្តឹងសុំមោឃភាពបានឡើយ" ។

វិធាន និងទម្រង់ការដែលចែងដោយមាត្រាខាងក្រោមនេះ មានលក្ខណៈដាច់ខាតត្រូវតែគោរពតាម បើពុំនោះទេនឹងនាំឲ្យមានមោឃភាពនៃនីតិវិធី៖

១-មាត្រា១២២ (ការបើកការស៊ើបសួរត្រូវតែធ្វើចំពោះបទឧក្រិដ្ឋ)

២-មាត្រា១២៣ (សមត្ថកិច្ចដែនដីចៅក្រមស៊ើបសួរ)

៣-កថាខណ្ឌទី ៣ នៃមាត្រា១២៤ ចៅក្រមស៊ើបសួរមិនអាចបំពេញកិច្ចស៊ើបសួរណាមួយបានដោយគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញាទេ ។

៤-កថាខណ្ឌទី១ និងទី២ នៃមាត្រា១២៥

- ចៅក្រមស៊ើបសួរត្រូវស៊ើបសួរតែអង្គហេតុដែលមានក្នុងឱកាសសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរប៉ុណ្ណោះ
- បើគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទេចៅក្រមស៊ើបសួរគ្មានអំណាចស៊ើបសួរអំពីអង្គហេតុថ្មីដែលលេចឡើងនោះឡើយ ។

៥-មាត្រា១២៨ ៖ ចៅក្រមស៊ើបសួរត្រូវមានក្រឡាបញ្ជីអមជានិច្ច ។ ក្នុងករណីណាក៏ដោយក្រឡាបញ្ជីមិនអាចបំពេញកិច្ចដែលជាសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរបានទេ ។

បន្ថែមលើចំណុចខាងលើនេះ ការដែលនាំឲ្យមានមោឃភាព កាលណាការបំពានវិធាន ឬទម្រង់ការសំខាន់ណាមួយដែលចែងដោយក្រមនេះ ឬបទប្បញ្ញត្តិទាំងឡាយស្តីពីនីតិវិធីព្រហ្មទណ្ឌ ធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ភាគី ដែលទទួលរងការបំពាននេះ ។ វិធាន និងទម្រង់ការដែលមានលក្ខណៈសំខាន់នោះមានជាអាទិ៍ គឺវិធានទម្រង់ការដែលមានបំណងធានាការគោរពសិទ្ធិការពារខ្លួន ។

- **អ្នកដែលមានសិទ្ធិក្នុងការប្តឹងសុំមោឃភាពក្នុងកិច្ចនីតិវិធី**

១-ចៅក្រមស៊ើបសួរ អាចប្តឹងទៅសភាស៊ើបសួរតាមដីកាដែលមានសំអាងហេតុ និងជូនដំណឹងដល់ព្រះរាជអាជ្ញាជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ។

២-ព្រះរាជអាជ្ញា អាចធ្វើពាក្យសុំដោយមានសំអាងហេតុបញ្ជូនទៅសភាស៊ើបសួរ និងជូនដំណឹងទៅចៅក្រមស៊ើបសួរ ។

៣-ជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី អាចធ្វើពាក្យសុំដោយមានសំអាងហេតុ ជូនទៅសភាស៊ើបសួរ និងជូនដំណឹងទៅចៅក្រមស៊ើបសួរ ។ ពាក្យសុំនេះ អាចធ្វើដោយមេធាវីបាន ។

ពាក្យសុំឲ្យធ្វើមោឃកម្ម ត្រូវចុះបញ្ជីនៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ ។ ភ្លាមនោះ ក្រឡាបញ្ជីសុំឲ្យចៅក្រមស៊ើបសួរបញ្ជូនសំណុំរឿងនៃនីតិវិធីមកឲ្យខ្លួនភ្លាម ។[44]

កាលណាមានការលះបង់នូវការបំពាននិវិធាន ឬទម្រង់ការសំខាន់ដែលធ្វើឲ្យប៉ះពាល់ផលប្រយោជន៍របស់ខ្លួននៃភាគីណាមួយ វាមានអានុភាពកែប្រែនិតិវិធីនេះឲ្យមានភាពប្រក្រតីឡើងវិញ ។ ការលះបង់នេះ ត្រូវធ្វើការពិនិត្យដោយចៅក្រមស៊ើបសួរនៅក្នុងកំណត់ហេតុ ។ បើមានមេធាវីត្រូវកោះហៅ មេធាវីយ៉ាងតិច ៥ ថ្ងៃ មុនកាលបរិច្ឆេទនៃការធ្វើកំណត់ហេតុ ។[45]

បណ្ដឹងសុំមោឃភាពកិច្ចនីតិវិធី ពុំមានអនុភាពបង្អាក់ការស៊ើបសួររបស់ចៅក្រមស៊ើបសួរឡើយ លើកលែងតែមានសេចក្ដីមួយរបស់ប្រធានសភាស៊ើបសួរ[46] ។

➢ **ភាពដែលមិនអាចទទួលយកបាននៃពាក្យសុំមោឃកម្ម**

១ -ពាក្យប្ដឹងសុំគ្មានសំអាងហេតុ (ផ្ទុយនឹងមាត្រា២៥៣ កថាខណ្ឌទី២,៣ និងទី៤)

២-ពាក្យប្ដឹងសុំទាក់ទងនឹងដីកាដែលអាចប្ដឹងឧទ្ធរណ៍ (មាត្រា២៥៣ កថាខណ្ឌទី៦)

៣-ពាក្យប្ដឹងសុំគ្មានមូលកភាពយ៉ាងជាក់ស្ដែង

សេចក្ដីសម្រេចប្រកាសមិនទទួលពាក្យសុំរបស់សភាស៊ើបសួរ មិនអាចតវ៉ាបានទេ ។[47]

អានុភាពនៃការធ្វើមោឃកម្មៈ កាលណាបានទទួលបណ្ដឹងមោឃកម្មចំពោះកិច្ច ឬលិខិតណាមួយនៃនីតិវិធីប្រសិនបើសភាស៊ើបសួរយល់ព្រមតាមពាក្យសុំ សភាស៊ើបសួរសម្រេចថា តើមោឃកម្មនេះត្រូវធ្វើទៅលើកិច្ច ឬលិខិតផ្សេងទៀតដែរឬទេ ហើយកិច្ច និងលិខិតដែលត្រូវធ្វើអោយកម្មទាំងនោះត្រូវដកចេញពីសំណុំរឿងដោយត្រូវតម្កល់ទុកនៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ ។[48]

ក្រោយពីបានធ្វើមោឃកម្មរួចហើយសភាស៊ើបសួរអាចៈ

- បង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរវិញ ឬ
- ដកសមត្ថកិច្ចចៅក្រមស៊ើបសួរ ហើយបញ្ជូនសំណុំរឿងទៅចៅក្រមស៊ើបសួរម្នាក់ផ្សេងទៀត ឬ
- បន្តការស៊ើបសួរដោយខ្លួនឯងលើរឿងនោះ ។

[44] មាត្រា ២៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[45] មាត្រា២៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[46] មាត្រា ២៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[47] មាត្រា ២៧៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[48] មាត្រា២៨០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

ក្នុងករណីចុងក្រោយនេះ សភាស៊ើបសួរអាចប្រគល់ភារកិច្ចទៅសមាជិកខ្លួនម្នាក់ ដែលត្រូវប្រើប្រាស់អំណាចជាចៅក្រមស៊ើបសួរ លើកលែងតែការបិទការស៊ើបសួរដែលត្រូវបើកសវនាការ ចេញសាលដីកាដំណោះស្រាយដោយអនុវត្តមាត្រា ២៥៩ (ការពិគ្រោះសំណុំរឿង និងសារណា) និង មាត្រា ២៤៧ (ដីកាដំណោះស្រាយ) ដល់មាត្រា ២៥០ (ការបញ្ជូនដើម្បីបើកសវនាការជំនុំជម្រះ) ។ ក្នុងករណីដែលសភាស៊ើបសួរសម្រេចដោះលែងជនត្រូវចោទដែលជាប់ឃុំ សេចក្តីសម្រេចនោះត្រូវ មានអានុភាពអនុវត្តភ្លាម ឯបទប្បញ្ញត្តិនៃមាត្រា ២៧៦ (ការដោះលែងឲ្យមានសេរីភាព) នៃក្រមនីតិវិធីព្រហ្មទណ្ឌ មិនត្រូវយកមកអនុវត្តនោះទេ ។[49]

បានសេចក្តីថាជនត្រូវចោទត្រូវបានដោះលែងភ្លាមៗដោយមិនចាំបាច់រង់ចាំរហូតទាល់តែផុតរយៈពេលនៃបណ្តឹងរបស់ព្រះរាជអាជ្ញានោះឡើយ ហើយក៏គ្មានបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា ដែលមានអនុភាពផ្អាកការអនុវត្តសេចក្តីសម្រេចនេះដែរ ។

[49] មាត្រា ២៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

# ជំពូកទី៣

# ដំណាក់កាលជន្មជម្រះ

# ជំពូកទី ៣
# ដំណាក់កាលជំនុំជម្រះ

## ផ្នែកទី១ យុត្តាធិការជំនុំជម្រះ

### ១.១.សមត្ថកិច្ច និងការប្តឹងទៅតុលាការ

នៅគ្រប់ខេត្ត និងក្រុងនៃព្រះរាជណាចក្រកម្ពុជាមានតុលាការជាន់ទាបមួយ ដែលមានសមត្ថកិច្ចលាត សន្ធឹងលើដែនដីខេត្ត ឬក្រុងទាំងមូល ដែលគេហៅថាសាលាដំបូង។ សមត្ថកិច្ចរបស់សាលាដំបូង ត្រូវបានបែង ចែកជាទៅតាមសមត្ថកិច្ចតុលាការ និងដែនដី ដើម្បីងាយស្រួលដោះស្រាយសំណុំរឿង និងងាយស្រួលដល់ការ ប្តឹងទៅតុលាការ ផងដែរ។

ចំពោះមុខងារចៅក្រម និងមុខងារព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញារងនោះ គឺមានវិសមិត្តភាពនឹងគ្នាយ៉ាង ដាច់ខាតមិនជំនួសគ្នាបានឡើយ។ ចៅក្រមណាដែលបានបំពេញមុខងារក្នុងឋានៈជាព្រះរាជអាជ្ញា ឬព្រះរាជ អាជ្ញារង ឬជាចៅក្រមស៊ើបសួរលើសំណុំរឿងណាមួយមិនអាចចូលរួមក្នុងការជំនុំជម្រះរឿងនោះបានទេ បើពុំ ដូច្នោះទេ សាលក្រមនឹងត្រូវទុកជាមោឃៈ។

#### ១.១.១.សមត្ថកិច្ចតុលាការជាន់ទាប និងដែនដី

សមត្ថកិច្ចរបស់តុលាការជាន់ទាប គឺជាសាលាជំនុំជម្រះថ្នាក់ដំបូងដែលមានសមត្ថកិច្ចជំនុំជម្រះ បទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ។ នៅតុលាការជាន់ទាបសម្រេចដោយចៅក្រម៣រូប ដែលជាក្រុមប្រឹក្សា ចំពោះបទឧក្រិដ្ឋ ព្រមទាំងបទមជ្ឈិម និងលហុដែលជាប់ទាក់ទង។ ហើយសម្រេចដោយចៅក្រមទោលចំពោះ បទមជ្ឈិម និងលហុ។ ហើយចំពោះតុលាការដែលមានសមត្ថកិច្ចខាងដែនដីគឺ ៖

- តុលាការនាទីកន្លែងបទល្មើស
- តុលាការនាលំនៅឋានរបស់ជនជាប់ចោទ ឬ
- តុលាការនាទីកន្លែងចាប់ខ្លួនជនជាប់ចោទ ។

ក្នុងករណីដែលមានតុលាការពីរ ឬច្រើនដែលស្ថិតនៅក្នុងមណ្ឌលនៃសាលាឧទ្ធរណ៍តែមួយបានទទួល ពាក្យប្តឹងលើរឿងតែមួយដូចគ្នា ប្រធានសាលាឧទ្ធរណ៍ចាត់តាំងតុលាការដែលនឹងត្រូវទទួលបន្ទុកលើសំណុំ រឿង។ វិវាទសមត្ថកិច្ចដែនដីរវាងតុលាការច្រើនដែលមានថ្នាក់ស្មើគ្នា ត្រូវសម្រេចដោយប្រធានតុលាការជាន់

ខ្ពស់។ ការសម្រេចនេះ គឺបិទផ្លូវ តវ៉ា ។ សមត្ថកិច្ចចំពោះជនជាប់ចោទត្រូវពន្លាតរហូតដល់សហចារី អ្នកផ្តើមគំនិត និងអ្នកសមគំនិតទាំងអស់ ។

ប្រសិនបើតុលាការដែលបានទទួលពាក្យប្តឹងយល់ឃើញថាពុំមានសមត្ថកិច្ចតាមដែនដីតុលាការនេះ ទេត្រូវប្រកាសថាពុំមានសមត្ថកិច្ចដោយសាលក្រម និងបង្គាប់ឱ្យបង្វិលសំណុំរឿងជូនព្រះរាជអាជ្ញា ដើម្បីឱ្យព្រះរាជអាជ្ញាបញ្ជូនសំណុំរឿងនេះ ជូនតុលាការដែលមានសមត្ថកិច្ចតាមដែនដី។ ជាយថាហេតុ តុលាការនេះសម្រេចសេចក្តីលើការបន្តដាក់ជនជាប់ចោទឱ្យស្ថិតក្នុងការឃុំខ្លួន ឬការត្រួតពិនិត្យតាមផ្លូវតុលាការ។

#### ១.១.២.ការប្តឹងទៅតុលាការ

ក្នុងរឿងព្រហ្មទណ្ឌជនរងគ្រោះមិនអាចប្តឹងទៅតុលាការព្រហ្មទណ្ឌដោយផ្ទាល់បានទេ តុលាការត្រូវបានទទួលបណ្តឹងដោយ ៖

- ដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬ សាលដីកាបញ្ជូនរបស់សភាស៊ើបសួរ
- ដីកាបញ្ជូនទៅតុលាការជំនុំជម្រះដោយផ្ទាល់របស់ព្រះរាជអាជ្ញា
- កំណត់ហេតុស្តីពីការចូលបង្ហាញខ្លួនភ្លាមដែលធ្វើដោយព្រះរាជអាជ្ញា ។

គ្រប់បុគ្គលដែលត្រូវបានបញ្ជូនទៅចំពោះមុខតុលាការតាមនីតិវិធីណាមួយដូចខាងលើនេះ មានឈ្មោះថាជនជាប់ចោទ។

ជនរងគ្រោះនៃបទល្មើស អាចតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបាននៅចំពោះមុខតុលាការ ប្រសិនបើខ្លួនពុំទាន់បានតាំងខ្លួននៅឡើយនៅមុខចៅក្រមស៊ើបសួរ។ មានឈ្មោះហៅថាអ្នកទទួលខុសត្រូវរដ្ឋប្បវេណី គឺបុគ្គលគ្រប់រូបដោយអនុវត្តតាមច្បាប់ ដែលត្រូវតែជួសជុលព្យសនកម្មដែលបណ្តាលឱ្យមានដល់ជនរងគ្រោះនៃបទល្មើស ។

### ១.២.ការរៀបចំសវនាការ

ប្រធានតុលាការជាអ្នករៀបចំសវនាការដោយចាត់ចៅក្រម ឬក្រុមប្រឹក្សាជំនុំជម្រះតាមប្រភេទបទល្មើស និងកំណត់ពេលសវនាការ ។ ព្រះរាជអាជ្ញាក្រោយពីទទួលបានដំណឹងកាលបរិច្ឆេទ ត្រូវកោះហៅជនពាក់ព័ន្ធចូលសវនាការ ។

#### ១.២.១.ការចាត់តាំងចៅក្រមជំនុំជម្រះ និងកំណត់ពេលសវនាការ

ក្រោយពេលតុលាការទទួលបណ្តឹងដោយការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ដោយដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬសាលដីកាបញ្ជូនរបស់សភាស៊ើបសួរ។ ប្រធានតុលាការត្រូវតែគិតគូរចាត់តាំងចៅក្រម ឬក្រុមប្រឹក្សាជំនុំជម្រះទៅតាមប្រភេទនៃបទល្មើស ឬករណីជនចោទជាអនីតិជន។

ប្រធានតុលាជាអ្នកកំណត់កាលបរិច្ឆេទសវនាការ ហើយជូនដំណឹងដោយផ្ទាល់មាត់ដល់ព្រះរាជអាជ្ញា ដើម្បីកោះហៅជនពាក់ព័ន្ធឲ្យចូលសវាការ។ កាលបរិច្ឆេទសវនាការ ត្រូវតែគិតគូរ និងគោរពថិរវេលានៃការប្រគល់ ដីកាកោះហៅ ដើម្បីឲ្យភាគីពាក់ព័ន្ធបានត្រៀមខ្លួន ជាពិសេសជនជាប់ចោទ លើកលែងតែជនជាប់ចោទកំពុងនៅជាប់ឃុំក្នុងពន្ធនាគារដែលថិរវេលានេះមិនទាមទឲ្យគោរពឡើយ។

### ១.២.២.ការកោះហៅចូលសវនាការ

ព្រះរាជអាជ្ញា ក្រោយពីទទួលដំណឹងអំពីកាលបរិច្ឆេទសវនាការ ត្រូវកោះហៅជនពាក់ព័ន្ធ ទាំងអស់ឲ្យចូលមកសវនាការមានជាអាទិ៍ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី ឬជនរងគ្រោះ(កាលណាមិនទាន់តាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅដំណាក់កាលចៅក្រមស៊ើបសួរ) អ្នកទទួលខុសត្រូវរដ្ឋប្បវេណី (មេធាវីជនទាំងនេះផងបើមាន) សាក្សី អ្នកជំនាញ អ្នកបកប្រែ និងនគរបាលយុត្តិធម៌ ជាដើម។
ក្នុងករណីជនជាប់ចោទ ឬបុគ្គលពាក់ព័ន្ធខាងលើកំពុងជាប់ឃុំក្នុងពន្ធនាគារ ព្រះរាជអាជ្ញាចាត់ចែងឲ្យប្រធានពន្ធនាគារនាំខ្លួនជននោះមកសវនាការ។

ចំពោះសាក្សីដែលព្រះរាជអាជ្ញាមិនបានកោះហៅ ជនជាប់ចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី អាចនាំសាក្សីនោះមកតុលាការដើម្បីសុំឲ្យចៅក្រមស្តាប់ចម្លើយបាន។

- **ជនជាប់ចោទ**

ជនជាប់ចោទត្រូវចូលបង្ហាញខ្លួននៅពេលសវនាការរបស់តុលាការដោយផ្ទាល់។ ជនជាប់ចោទត្រូវបានអមដោយមេធាវីម្នាក់ដែលខ្លួនជ្រើសរើស។ ជនជាប់ចោទក៏អាចសុំឱ្យចាត់តាំងមេធាវីឲ្យខ្លួនបានដែរ នៅក្នុងលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។ បើគ្មានការជ្រើសរើសដោយជនជាប់ចោទទេ មេធាវីត្រូវបានចាត់តាំងតាមគំនិតផ្តើមរបស់ប្រធានតុលាការ នៅក្នុងលក្ខខណ្ឌដែលមានចែងនៅក្នុងច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ។

នៅក្នុងករណីបញ្ជូនទៅជំនុំជម្រះផ្ទាល់ ជនជាប់ចោទចូលទៅបង្ហាញខ្លួនដោយសេរីខ្លួនឯងនៅពេលសវនាការ។

នៅក្នុងករណីនីតិវិធីចូលបង្ហាញខ្លួនភ្លាម ជនជាប់ចោទត្រូវឃុំគ្រងដោយកងការពាររហូតដល់សាមីខ្លួនចូលបង្ហាញខ្លួននៅមុខតុលាការ។ តុលាការអាចសម្រេចឃុំខ្លួនជនជាប់ចោទបណ្តោះអាសន្នបានដូចមានចែងក្នុងមាត្រា ៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ការឃុំខ្លួនបណ្តោះអាសន្នត្រូវបានបញ្ឈប់ដោយលក្ខណៈច្បាប់នៅពេលផុតថិរវេលា ២ សប្តាហ៍ ។

ក្នុងករណីដែលតុលាការទទួលបណ្ដឹងតាមដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬសាលដីកាបញ្ជូនរបស់សភាស៊ើបសួរ ជនជាប់ចោទចូលបង្ហាញខ្លួនដោយសេរី លើកលែងតែចៅក្រមស៊ើបសួរ ឬសភាស៊ើបសួរ បានសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្ន។ ព្រះរាជអាជ្ញាចាត់វិធានការចាំបាច់ ដើម្បីឱ្យជនជាប់ចោទដែលត្រូវបានឃុំខ្លួន ត្រូវបាននាំ ទៅកាន់សវនាការដោយកងកម្លាំងសាធារណៈ។

➢ **ជនរងគ្រោះ ឬដើមបណ្ដឹងរដ្ឋប្បវេណី**

ជនរងគ្រោះអាចតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីបាននៅចំពោះមុខចៅក្រមជំនុំជម្រះបាន បើសិនមិនខ្លួនបានតាំងខ្លួននៅក្នុងដំណាក់កាលស៊ើបសួរទេ។ ប៉ុន្តែការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនេះមិនអាចទទួលបានទេ ក្រោយពេលព្រះរាជអាជ្ញាសន្និដ្ឋាន។ ជនរងគ្រោះ ឬដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវចូលបង្ហាញខ្លួនក្នុងសវនាកា ដោយផ្ទាល់ ឬដោយមានមេធាវីអម។

ជនរងគ្រោះជានីតិជនត្រូវតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដោយខ្លួនឯង លើកលែងតែសាមីខ្លួនបានស្លាប់ត្រូវទាមទារដោយសិទ្ធិវន្តរបស់គាត់។ បើជាអនីតិជន ឬជនដែលស្ថិតក្រោមអំណាចមេបា ត្រូវបានតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដោយឪពុកម្ដាយ ឬអាណាព្យាបាល។ ជនរងគ្រោះ ឬដើមបណ្ដឹងរដ្ឋប្បវេណីក៏អាចត្រូវតំណាងដោយមេធាវី សហព័ទ្ធ ឬញាតិលោហិតផ្ទាល់ផងដែរ។

➢ **អ្នកទទួលខុសត្រូវរដ្ឋប្បវេណី**

អ្នកទទួលខុសត្រូវរដ្ឋប្បវេណីត្រូវចូលបង្ហាញខ្លួនក្នុងសវនាការដោយផ្ទាល់ ឬមានមេធាវីអមជាមួយកាលណាខ្លួនបានពឹងពាក់។ អ្នកទទួលខុសត្រូវរដ្ឋប្បវេណីក៏អាចត្រូវបានតំណាងដោយមេធាវី ដោយសហព័ទ្ធ ឬដោយញាតិលោហិតផ្ទាល់ផងដែរ។ អ្នកតំណាងដែលមិនមែនជាមេធាវី ត្រូវតែមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ។

➢ **សាក្សី**

សាក្សីដែលត្រូវបានកោះហៅ ត្រូវតែបង្ហាញខ្លួនក្នុងសវនាការ។ សាក្សីត្រូវចូលខ្លួនដោយផ្ទាល់ ដោយពុំអាចត្រូវតំណាងដោយអ្នកណាបានឡើយ។ ទោះបីជាមេធាវីក៏មិនអាចតំណាងឲ្យសាក្សីក្នុងសវនាការបានទេ។ ក្នុងករណីមានធុរៈចាំចាច់មិនអាចខានបាន សាក្សីត្រូវសុំមកតុលាការ ដោយបញ្ជាក់មូលហេតុឲ្យបានសមស្រប។ បើមិនដូច្នោះទេ តុលាការអាចបង្អង់សវនាការសិន ហើយបង្គាប់ឲ្យកងកម្លាំងសាធារណៈនាំខ្លួនសាក្សីនោះមកកាន់សវនាការបាន។ ចំពោះសាក្សីដែលសំខាន់ហើយព្រះរាជអាជ្ញាមិនបានកោះហៅនោះជនជាប់ចោទ

ដើមបណ្តឹងរដ្ឋប្បវេណីក្តីអាចនាំសាក្សីមកក្នុងសវនាការហើយស្នើសុំតុលាការឲ្យស្តាប់ចម្លើយបានដោយខ្លួនជាអ្នកចំណាយសោហ៊ុយនានាជូនសាក្សីនោះ។

ក្នុងករណីសាក្សីមិនព្រមចូលមកបង្ហាញខ្លួនតាមដីកាកោះរបស់ចៅក្រម ដោយគ្មានមូលហេតុ ជាបទល្មើសបដិសេធមិនចូលខ្លួន[50]។ ចំពោះសាក្សីដែលចូលមកបង្ហាញខ្លួនតែបដិសេធមិនឆ្លើយជូនតុលាការ ជាបទល្មើសបដិសេធផ្តល់ចម្លើយ[51]។ រីឯសាក្សីដែលចូលបង្ហាញខ្លួន និងព្រមឆ្លើយ ប៉ុន្តែផ្តល់ចម្លើយកុហកដល់តុលាការ ជាបទល្មើសផ្តល់សក្ខីកម្មក្លែងក្លាយ[52] ។ ប្រសិនសាក្សីទទួលសំណូកដោយការទទួលអំណោយជំនូន ការសន្យា ឬអត្ថប្រយោជន៍ពីភាគីណាមួយដើម្បីមិនធ្វើសាក្សី ឬមកឆ្លើយភូតកុហក ជាបទស៊ីសំណូករបស់សាក្សី ។

➢ **អ្នកជំនាញ និងអ្នកបកប្រែ**

តុលាការអាចបង្គាប់ឲ្យកោះហៅអ្នកជំនាញ នគរបាលយុត្តិធម៌ និងអ្នកបកប្រែភាសាគថ្លង់ ភាសាបរទេស ភាសាជនជាតិដើមភាគតិច ដើម្បីមកជួយដោះស្រាយបើចាំបាច់។ បុគ្គលដែលពាក់ព័ន្ធ ដែលត្រូវបានកោះហៅត្រូវចូលបង្ហាញខ្លួនក្នុងសវនាការ។ អ្នកដែលបានកោះហៅត្រូវមានកាតព្វកិច្ចអនុវត្តឲ្យបានត្រឹមត្រូវតាមវិជ្ជាជីវៈរបស់ខ្លួន ដើម្បីជួយតុលាការស្វែងរកការពិតជូនភាគីនានា។ ក្នុងករណីមានការក្លែងបន្លំមិនមែនជាការពិត ត្រូវប្រឈមមុខនូវទណ្ឌកម្មផ្សេងដូចជា ៖

- ចំពោះអ្នកជំនាញដែលទទួលសំណូកដោយការទទួលអំណោយ ជំនូន ការសន្យា ឬអត្ថប្រយោជន៍នានាពីភាគីណាមួយ ដើម្បីក្លែងក្នុងរបាយការណ៍លាយលក្ខណ៍អក្សរ ឬក្នុងសេចក្តីថ្លែងការណ៍ផ្ទាល់មាត់នូវទិន្នន័យ ឬលទ្ធផលកោសលវិច័យ ជាបទស៊ីសំណូករបស់អ្នកជំនាញ[53] ។
- ចំពោះអ្នកបកប្រែដែលបំភ្លៃការពិតដោយចេតនានូវខ្លឹមសារនៃភាសា ឬឯកសារបកប្រែ ជាបទបំភ្លៃដោយអ្នកបកប្រែ[54] ។ អ្នកបកប្រែណាដែលទទួលសំណូកដោយការទទួលអំណោយជំនូន ការសន្យា ឬអត្ថប្រយោជន៍នានាពីភាគីណាមួយដើម្បីក្លែងខ្លឹមសារនៃភាសា ឬឯកសារដែលបកប្រែជាបទស៊ីសំណូករបស់អ្នកបកប្រែ[55] ។

[50] មាត្រា ៥៣៥ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[51] មាត្រា ៥៣៧ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[52] មាត្រា ៥៤៥ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[53] មាត្រា ៥៥៥ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[54] មាត្រា ៥៥០ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[55] មាត្រា ៥៥៣ នៃក្រមព្រហាទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

## ១.៣. ការពិភាក្សាដេញដោល

ជាគោលការណ៍ ការពិភាក្សាដេញដោលត្រូវតែធ្វើជាសាធារណៈ។ លើកលែងតែមានករណីពិសេស ដែលតុលាការសម្រេចជាអសាធារណៈដែលមូលហេតុបង្កគ្រោះថ្នាក់ដល់សន្តិសុខ និងសណ្តាប់ធ្នាប់ ឬទំនៀមទម្លាប់ ក្នុងករណីនេះតុលាការតាមសេចក្តីសម្រេចមានសំអាងហេតុ អាចបង្គាប់ឲ្យការពិភាក្សាចេញដោលទាំងស្រុង ឬមួយផ្នែកជាសម្ងាត់។ ចំពោះការសួរចម្លើយ និងស្តាប់ចម្លើយ ហើយការដាក់ភស្តុតាងជូនតុលាការពិនិត្យក៏ជាសម្ងាត់ផងដែរ។ ក្រោយពេលការបញ្ចប់ការពិភាក្សាដេញដោល តុលាការសម្រេចតាមសាលក្រមដាច់ដោយឡែកពីសាលក្រមអង្គសេចក្តី ឬតាមសេចក្តីសម្រេចពិសេសនៃសាលក្រមលើអង្គសេចក្តី។ សេចក្តីសម្រេចរបស់តុលាការដែលបង្គាប់ឲ្យធ្វើការពិភាក្សាដេញដោលដោយសម្ងាត់ មិនអាចតវ៉ាបានទេ។

### ១.៣.១.សន្តិសុខ និងសណ្តាប់ធ្នាប់

ប្រធានសវនាការជាអ្នកដឹកនាំការពិភាក្សាដេញដោល។ ប្រធានសវនាការត្រូវរ៉ាប់រងឱ្យសិទ្ធិខាងការការពារបានប្រព្រឹត្តទៅដោយសេរី។ ប៉ុន្តែប្រធានអាចបដិសេធចេញពីការពិភាក្សាដេញដោលនូវអ្វីដែលមានគោលបំណងអូសបន្លាយការពិភាក្សាដេញដោលនេះដោយឥតប្រយោជន៍គ្មានរួមវិភាគទានអ្វីដល់ការសំដែងឲ្យឃើញការពិត ។

- ប្រធានសវនាការរ៉ាប់រងឱ្យមានសណ្តាប់ធ្នាប់ល្អនៅពេលសវនាការ ។
- ប្រធានសវនាការអាចហាមឃាត់អនីតិជនខ្លះ ឬ ទាំងអស់មិនឱ្យចូលក្នុងបន្ទប់សវនាការ ។
- ប្រធានសវនាការអាចបង្គាប់ឱ្យបណ្តេញបុគ្គលគ្រប់រូបដែលបង្កឱ្យមានការច្របូកច្របល់ដល់របៀបរៀបរយនៃការពិភាក្សាដេញដោល ។

ក្នុងការបំពេញមុខងាររបស់ខ្លួន ប្រធានសវនាការអាចប្រើប្រាស់កងកម្លាំងសាធារណៈ ។

ប្រសិនបើមានបទល្មើសបានកើតឡើងនៅក្នុងពេលសវនាការ ប្រធានសវនាការធ្វើកំណត់ហេតុពិនិត្យរឿងហេតុនេះ។ ប្រធានសវនាការអាចបង្គាប់ឱ្យចាប់ និងនាំជនល្មើសភ្លាមជូនព្រះរាជអាជ្ញាដើម្បីថ្លឹងថ្លែង ពីវិធានការដែលត្រូវចាត់។ កាលណាបទល្មើសជាបទលហុ ឬបទមជ្ឈិម តុលាការអាចជំនុំជម្រះជនល្មើសភ្លាម ប្រសិនបើ ព្រះរាជអាជ្ញាប្តឹងសុំ និងប្រសិនបើជនល្មើសយល់ព្រម។

### ១.៣.២.ដំណើរនៃកិច្ចពិភាក្សាដេញដោល

កិច្ចពិភាក្សាដេញដោលត្រូវប្រព្រឹត្តទៅដោយក្រឡាបញ្ជីសវនាការពិនិត្យវត្តមានជនទាក់ទិនដែលត្រូវបានកោះហៅ និងពិនិត្យអត្តសញ្ញាណជនទាំងនោះ។ ចំពោះដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ប្រសិនបើចាត់ឲ្យញាតិលោហិត ឬសហព័ទ្ធមកចូលរួមជាតំណាង នោះក្រឡាបញ្ជីពិនិត្យអត្តសញ្ញាណរបស់អ្នក

តំណាងនិងពិនិត្យលិខិតប្រគល់សិទ្ធិ។ បន្ទាប់មកត្រូវណែនាំឲ្យភាគីនីមួយៗ អង្គុយតាមទីកន្លែងដែលបានគ្រោងទុក។ ចំពោះជនជាប់ចោទ មិនត្រូវឲ្យគាត់ទាក់ទងគ្នា ឬជជែកគ្នាឡើយ។

ប៉ុន្តែសាក្សី និងអ្នកជំនាញត្រូវថយទៅរងចាំក្នុងបន្ទប់រងចាំ មិនត្រូវឲ្យស្ថិតនៅក្នុងសាលសវនាការទេ ព្រោះគាត់អាចស្តាប់ឮការពិភាក្សាដេញដោល។ បើគ្មានបន្ទប់រងចាំ គួរអោយគាត់អង្គុយរងចាំនៅកៅអីខាងមុខសវនាការសិន។ ត្រូវឲ្យសាក្សី អង្គុយនៅឆ្ងាយពីគ្នាបន្តិច កុំឲ្យពួកគាត់ពិភាក្សាគ្នាបាន។

ក្រឡាបញ្ជីសវនាការ រាយការណ៍វត្តមានជនទាក់ទិន ជូនចៅក្រមជំនុំជម្រះ ព្រះរាជអាជ្ញា និងអង្គសវនាការជ្រាប។ ចំពោះតំណាងអយ្យការ ធ្វើការកត់សម្គាល់ចំពោះវត្តមាន និងអវត្តមានរបស់ជនទាក់ទិន និងលើកយោបល់ជូនតុលាការ។ ទោះបីមានជនទាក់ទិនខ្លះអវត្តមាន ជាពិសេសជនជាប់ចោទទោះបីអវត្តមាន តុលាការនៅ តែអាចបន្តសវនាការបាន។ ផ្ទុយទៅវិញតុលាការអាចបង្អង់សវនាការសិន ដោយតម្រូវឲ្យកោះហៅបុគ្គលពាក់ព័ន្ធដែលអវត្តមានមកសវនាការ។ ក្នុងករណីនេះ បើតុលាការសម្រេចថាបន្តសវនាការ ចៅក្រម ឬក្រុមប្រឹក្សាប្រកាសសមាសភាពក្រុមប្រឹក្សាជំនុំជម្រះ តំណាងអយ្យការ ក្រឡាបញ្ជីសវនាការ និងមេធាវីការពារសិទ្ធិ។

នៅមុនការសួរដេញដោលជនជាប់ចោទ ភាគីអាចលើកឡើងពីវិវាទកម្មស្តីពីការកោះហៅបាន បើមិនដូច្នេះទេមិនអាចលើកឡើងបានទេ ហើយជនជាប់ចោទ ឬភាគីក៏អាចប្តឹងជិតចិត្តចៅក្រមជំនុំជម្រះ ឬសមាជិកក្រុមប្រឹក្សាណាម្នាក់បាន។ ជនជាប់ចោទ អាចសុំឲ្យស្តាប់ចម្លើយសាក្សីដែលមិនបានកោះហៅ ឬសំណូមពរអ្វីដែលមានប្រយោជន៍ដល់ខ្លួន។ សាក្សីដែលភាគីបាននាំមកនេះ ត្រូវទទួលការអនុញ្ញាតពីតុលាការ និងត្រូវធ្វើសម្បថ ហើយទៅរងចាំក្នុងបន្ទប់រងចាំ។ ការសួរចម្លើយ និងស្តាប់ចម្លើយត្រូវធ្វើតាមលំដាប់លំដោយ។

- **ការសួរចម្លើយជនជាប់ចោទ**

ប្រធានសវនាការប្រាប់ដល់ជនជាប់ចោទឱ្យបានដឹងអំពីអំពើដែលគេចោទប្រកាន់លើខ្លួន និងធ្វើការសួរចម្លើយជនជាប់ចោទនេះ។ ប្រធានសវនាការសួរគ្រប់សំណួរដែលខ្លួនយល់ឃើញថាមានប្រយោជន៍ដល់ការសំដែងឱ្យឃើញការពិត។ ប្រធានសវនាការមានករណីយកិច្ចសួរចម្លើយជនជាប់ចោទទាំងខាងផ្នែកដាក់បន្ទុកទាំងខាងផ្នែកដោះបន្ទុក។

ក្រោយពីប្រធានសវនាការសួរចម្លើយរួចហើយ ព្រះរាជអាជ្ញា មេធាវី និងភាគី អាចត្រូវបានអនុញ្ញាតឱ្យលើកសំណួរសួរដល់ជនជាប់ចោទ។ គ្រប់ការលើកសំណួរទាំងអស់ត្រូវតែបានការអនុញ្ញាតពីប្រធានសវនាការ ក្រៅពីសំណួររបស់តំណាងអយ្យការ និងមេធាវី សំណួរផ្សេងៗ ទៀតត្រូវសួរតាមរយៈប្រធានសវនាការ។ ក្នុងករណីមានការតវ៉ា ប្រធានសវនាការសម្រេច ដោយឥស្សរចិត្តថា តើសំណួរនេះត្រូវតែសួរឬទេ។

➢ **ការស្តាប់ចម្លើយភាគី**

ប្រធានសវនាការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី និងអ្នកជំនាញ តាមលំដាប់លំដោយដែលខ្លួនយល់ឃើញថាមានប្រយោជន៍រួចមក ។ ប្រធានសវនាការអាចស្តាប់នូវចម្លើយមន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ ដែលបានចូលរួមក្នុងការស៊ើបអង្កេតក្នុងឋានៈជាសាក្សីបាន។ ព្រះរាជអាជ្ញា មេធាវី និង ភាគី អាចត្រូវបានអនុញ្ញាតឱ្យលើកសំណួរសួរបាន។ គ្រប់ការលើកសំណួរទាំងអស់ត្រូវតែបានការអនុញ្ញាតពីប្រធានសវនាការជាមុនសិន។ ក្រៅពីសំណួររបស់តំណាងអយ្យការ និងមេធាវី សំណួរផ្សេងៗទៀតត្រូវសួរតាមរយៈប្រធានសវនាការ។

**១.៣.៣.ការដាក់ភស្តុតាងជូនតុលាការពិនិត្យ**

ភស្តុតាងក្នុងរឿងព្រហ្មទណ្ឌ អាចដាក់ជូនតុលាការដោយសេរី ។ ភាគីអាចដាក់ជូនតុលាការនៅមុនពេលសវនាការក៏បានដោយការដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរ ឬអាចប្រគល់ជូនដោយផ្ទាល់នៅក្នុងពេលសវនាការក៏បាន។

ភស្តុតាងក្នុងរឿងព្រហ្មទណ្ឌមានដូចជា ៖

- ភស្តុតាងជាវត្ថុ
- ភស្តុតាងជាឯកសារ
- ភស្តុតាងជាមនុស្ស
- ភស្តុតាងជាវេជ្ជសាស្ត្រ ឬវិទ្យាសាស្ត្រ។
-

➢ **គោលការណ៍នៃការវាយតម្លៃភស្តុតាង**

ជាទូទៅតុលាការថ្លឹងថ្លែងដោយឥស្សរចិត្ត អំពីភស្តុតាងដែលភាគីបានប្រគល់ជូនខ្លួនពិនិត្យ ដោយផ្អែកលើគោលការណ៍ជំនឿស្មោះត្រង់ពិតប្រាកដរបស់ខ្លួន។ នៅក្នុងសំអាងហេតុនៃសេចក្តីសម្រេចតុលាការលើកសំអាង តែអំពីភស្តុតាងដែល គេបានប្រគល់ជូនក្នុងសវនាការ ឬភស្តុតាងដែលមានក្នុងសំណុំរឿងប៉ុណ្ណោះ។ វត្ថុ ឬឯកសារដែលអាចមានតម្លៃជាភស្តុតាង លុះត្រាតែបានមកដោយមធ្យោបាយស្របច្បាប់។ ជាក់ស្តែងចម្លើយសារភាពដែលបានពីការបង្ខិតបង្ខំ ឬដោយមធ្យោបាយទុច្ចរិត ឬសម្លេងឆ្លងឆ្លើយដែលគេលួចថតបាន ពីការសន្ទនារវាងជនជាប់ចោទ ជាមួយមេធាវី គ្មានតម្លៃជាភស្តុតាងទេ។ ក្នុងពេលសវនាការចៅក្រមអាចបង្គាប់ឲ្យជនណាម្នាក់បង្ហាញវត្ថុតាង ឬភស្តុតាងបាន។

➢ **ការធ្វើសេចក្តីសន្និដ្ឋាន និងសំណូមពរ**

ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី អាចដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់ខ្លួននៅមុន និងក្នុងពេលសវនាការបាន រហូតដល់បិទកិច្ចពិភាក្សាដេញដោល។

នៅពេលបញ្ចប់ការពិភាក្សាដេញដោល និងពិនិត្យភស្តុតាងរួច ប្រធានសវនាការអនុញ្ញាតឲ្យភាគីសន្និដ្ឋានផ្ទាល់មាត់ និងធ្វើការកត់សម្គាល់ខ្លីៗ (សំណូមពរ) តាមលំដាប់លំដោយ ដូចតទៅ៖

- ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី និងជនជាប់ចោទកត់សម្គាល់ខ្លីៗ
- មេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណី ធ្វើសេចក្តីសន្និដ្ឋានការពារ
- ព្រះរាជអាជ្ញា ធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ
- មេធាវីរបស់អ្នកទទួលខុសត្រូវរដ្ឋប្បវេណី និងមេធាវីរបស់ជនជាប់ចោទ សន្និដ្ឋានការពារ
- ដើមបណ្តឹង និងព្រះរាជអាជ្ញាអាចឆ្លើយតបទៅវិញបាន ប៉ុន្តែករណីនេះ ជនជាប់ចោទ និងមេធាវីរបស់ជនជាប់ចោទ ត្រូវតែនិយាយក្រោយគេបង្អស់(តបទៅព្រះរាជអាជ្ញាវិញ)។

➢ **ការបញ្ចប់កិច្ចពិភាក្សាដេញដោល**

ក្រោយពីសន្និដ្ឋាន និងសំណូមពររួច ការស្នើសុំអ្វីលែងបានទៀតហើយ តុលាការប្រកាសបញ្ចប់សវនាការសួរដេញដោល និងសម្រេចថាត្រូវប្រកាសសាលក្រមភ្លាម ឬលើកពេលប្រកាសសាលក្រម។ បើប្រកាសសាលក្រមភ្លាម តុលាការឲ្យភាគីទាំងអស់រង់ចាំ ហើយតុលាការថយទៅបន្ទប់ពិភាក្សា។ បន្ទាប់មកតុលាការចូលមកវិញប្រកាសសាលក្រមតែម្តង។ ប្រសិនបើតុលាការសម្រេចលើកពេលសវនាការ តុលាការប្រកាសកាលបរិច្ឆេទប្រកាសសាលក្រមដោយមិនធ្វើការកោះហៅជាថ្មីទេ ចាត់ទុកការជូនដំណឹងក្នុងពេលសវនាការនេះជាការកោះហៅដោយផ្ទាល់មាត់តែម្តង។ ដោយឡែកជនជាប់ឃុំ ព្រះរាជអាជ្ញាចាត់ចែងឲ្យប្រធានពន្ធនាគារនាំខ្លួនមកសវនាការ។

ប្រសិនបើមានភាពចាំបាច់តុលាការអាចចុះទៅដល់ទីកន្លែងតែម្តងនៃដែនដីជាតិបាន។ ក្នុងករណីដែលយល់ឃើញថារឿងក្តីមួយ មិនទាន់អាចប្រកាសសាលក្រមបានទេ និងទាមទារឲ្យមានការស្រាវជ្រាវបន្ថែមនោះ តុលាការអាចស្រាវជ្រាវបន្ថែមដោយខ្លួនឯង ឬចាត់តាំងសមាជិកខ្លួនណាម្នាក់ ឬបង្វិលរឿងឲ្យចៅក្រមផ្សេងទៀតស្រាវជ្រាវ ចៅក្រមដែលអនុវត្តការស្រាវជ្រាវនេះអនុវត្តក្នុងលក្ខខណ្ឌដូចនីតិវិធីស៊ើបសួរដែរ។

**១.៤. ការប្រកាសសាលក្រម**

ដោយអនុលោមតាមច្បាប់រៀបចំអង្គការតុលាការ។ សាលក្រមដែលសម្រេចដោយ ក្រុមប្រឹក្សាជំនុំជម្រះ ឬហៅថាអង្គជំនុំជម្រះ ដែលមានសមាសភាពចាប់ពី៣រូបឡើងទៅចំពោះបទឧក្រិដ្ឋ ព្រមទាំងបទមជ្ឈិម

និងលហុដែលជាប់ទាក់ទង។ កាលណាការពិភាក្សាដេញដោលបានបញ្ចប់ តុលាការថយទៅពិភាក្សាសម្រេច។ ការពិភាក្សាធ្វើឡើងជាការសម្ងាត់មានតែសមាជិកក្រុមប្រឹក្សាជំនុំជម្រះតែប៉ុណ្ណោះដែលចូលរួមពិភាក្សា។ ព្រះរាជអាជ្ញា និងក្រឡាបញ្ជីមិនអាចចូលរួមការពិភាក្សាបានទេ។ ការសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះ ធ្វើឡើងដោយមតិភាគច្រើន។ នៅក្នុងករណីសាលក្រមសម្រេចដោយចៅក្រមជំនុំជម្រះទោល ចៅក្រមសម្រេចដោយឥស្សរចិត្តដោយផ្អែកលើភស្តុតាង។ ករណីនេះហៅថា ការថយទៅពិចារណា។

ក្រោយពីពិភាក្សា ឬសម្រេចដោយឥស្សរចិត្តរួចតុលាកា នឹងប្រកាសពីពិរុទ្ធភាព ព្រមទាំងការសម្រេចអំពីផលប្រយោជន៍នៃផ្នែករដ្ឋប្បវេណី និងការសម្រេចអំពីវត្ថុដែលបានចាប់យក។

### ១.៤.១. ការប្រកាសពិរុទ្ធភាព

ក្នុងការប្រកាសពីពិរុទ្ធភាពនេះតុលាការត្រូវពិនិត្យមើលថា ៖

- អំពើនោះជាបទឧក្រិដ្ឋ បទមជ្ឈិម ឬលហុ។
- ជនជាប់ចោទបានប្រព្រឹត្តអំពើដែលចោទប្រកាន់មកកាន់ខ្លួនដែល ឬទេ។

ប្រសិនបើតុលាការពិនិត្យទៅយល់ឃើញថា មានពិរុទ្ធភាពលើជនជាប់ចោទ តុលាការត្រូវប្រកាសផ្តន្ទាទោសតាមច្បាប់បញ្ញត្តិ។

ប្រសិនបើតុលាការពិនិត្យទៅយល់ឃើញថាអំពើនោះមិនមែនជាបទល្មើស ឬជនជាប់ចោទគ្មានកំហុស តុលាការត្រូវប្រកាសជនជាប់រួចខ្លួនពីបទចោទ។

➢ **ការប្រកាសពិរុទ្ធភាពតែមិនប្រកាសទោស**

ជនជាប់ចោទខ្លះអាចឲ្យតុលាការប្រកាសពីពិរុទ្ធភាពបានតែមិនអាចប្រកាសទោសបាននោះទេ។ ទោះជាមានអំពើនោះបង្កើតជាបទល្មើស និងមានភស្តុតាងគគ្រប់គ្រាន់បញ្ជាក់ថា ជនជាប់ចោទជាអ្នកប្រព្រឹត្តក៏ដោយ ក៏តុលាការមិនអាចប្រកាសទោសចំពោះជននោះបានដែរ។ ដោយហេតុថា ច្បាប់មិនឲ្យទទួលខុសត្រូវ។

➢ **ការបង្គាប់ឲ្យចាប់ខ្លួន ឬឃុំខ្លួនជាអាទិ៍ក្នុងដំណាក់កាលជំនុំជម្រះ**

ប្រសិនបើតុលាការប្រកាសផ្តន្ទាទោសដាក់ពន្ធនាគារ ១ឆ្នាំ យ៉ាងតិច ដោយគ្មានការព្យួរទេ តុលាការតាមសេចក្តីសម្រេចពិសេស និងដោយមានសំអាងហេតុ អាចចេញនៅក្នុងពេលសវនាការ ៖

- ដីកាបង្គាប់ឱ្យឃុំខ្លួនជនជាប់ចោទដែលមានវត្តមាន
- ដីកាបង្គាប់ឱ្យចាប់ខ្លួនជនជាប់ចោទអវត្តមាន ។
- ដីកាបង្គាប់ឱ្យឃុំខ្លួន និងដីកាបង្គាប់ឱ្យចាប់ខ្លួន មានអានុភាពអនុវត្តភ្លាមៗ ។

ដីកាទាំងនោះមានចុះនិទ្ទេសដូចតទៅ ៖

- អត្តសញ្ញាណរបស់ពិរុទ្ធជន
- ប្រភេទនៃទណ្ឌកម្ម និងអត្ថបទច្បាប់ដែលជាមូលដ្ឋាននៃការផ្តន្ទាទោសនេះ
- ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកា ។

ដីកានេះត្រូវតែមានចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមនេះ និងបោះត្រាផងដែរ។ ពិរុទ្ធជនដែលត្រូវបានចាប់ខ្លួនដោយអនុវត្តតាមដីកាបង្គាប់ឱ្យចាប់ខ្លួននោះ ត្រូវតែបានគេនាំទៅបង្ហាញខ្លួនក្នុងរយៈពេលយ៉ាងខ្លីបំផុត នៅមុខព្រះរាជអាជ្ញានាទីកន្លែងចាប់ខ្លួន ដែលឱ្យដំណឹងដល់សាមីខ្លួនអំពីដីកានេះ និងធ្វើការឃុំខ្លួន។ កាលណាសាលក្រមត្រូវបានសម្រេចដោយកំបាំងមុខនោះ ពិរុទ្ធជនដែលសម្រេចចិត្តថា ប្តឹងទាស់ត្រូវតែចូលបង្ហាញខ្លួននៅក្នុងរយៈពេលយ៉ាងខ្លីបំផុត នៅមុខតុលាការដែលបានប្រកាសសាលក្រម។

### ១.៤.២. ការសម្រេចអំពីផលប្រយោជន៍ផ្នែករដ្ឋប្បវេណី

នៅក្នុងសាលក្រមតែមួយជាមួយរឿងក្តីព្រហ្មទណ្ឌតុលាការអាចសម្រេចអំពីផលប្រយោជន៍ផ្នែករដ្ឋប្បវេណីបាន។ តុលាការវិនិច្ឆ័យអំពីភាពអាចទទួលបាននៃការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហើយសម្រេចអំពីពាក្យបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណីទៅលើ ជនជាប់ចោទ និងលើអ្នកទទួលខុសត្រូវរដ្ឋប្បវេណី។

កាលណាតុលាការមិនទាន់អាចសម្រេចបានលើផលប្រយោជន៍ផ្នែករដ្ឋប្បវេណីទេ តុលាការអាចបង្អង់ទៅសវនាការលើកពេលក្រោយ និងអាចឲ្យប្រាក់បណ្តោះអាសន្ន។

បុគ្គលដែលត្រូវបានផ្តន្ទាទោសក្នុងបទល្មើសតែមួយជាមួយគ្នានោះ ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដោយសាមគ្គីភាព។

### ១.៤.៣ ការសម្រេចអំពីវត្ថុចាប់យក

នៅក្នុងសាលក្រមព្រហ្មទណ្ឌ តុលាការមានសមត្ថកិច្ចសម្រេចអំពីវត្ថុដែលចាប់យកនៅគ្រប់ដំណាក់នីតិវិធីទាំងអស់ ។ការសម្រេចអាចជាការប្រគល់សងឲ្យម្ចាស់ដើមវិញ ឬត្រូវរឹបអូស។

ប្រសិនបើតុលាការមិនបានសម្រេចអំពីវត្ថុចាប់យកនេះ នៅពេលសាលក្រមចូលជាស្ថាពរ បុគ្គលដែលជាម្ចាស់នៃវត្ថុ អាចដាក់ពាក្យសុំទៅព្រះរាជអាជ្ញាឲ្យប្រគល់វត្ថុនោះមកខ្លួនវិញបាន។ ការសម្រេចអំពីពាក្យសុំប្រគល់វត្ថុចាប់យកក្នុងករណីនេះ ជាសមត្ថកិច្ចរបស់ព្រះរាជអាជ្ញា។

## ផ្នែកទី២ អំពីសាលក្រម

ជានិច្ចកាលសាលក្រមត្រូវបានប្រកាសជាសាធារណៈ ទោះបីជាតុលាការបានសម្រេចតាមរយៈសេចក្តីសម្រេចពិសេសដែល មិនបើកផ្លូវតវ៉ាថារឿងក្តីប្រព្រឹត្តទៅជាអសាធារណៈដើម្បីថែរក្សាសណ្តាប់ធ្នាប់

សាធារណៈ ឬទំនៀមទំលាប់ក៏ដោយ ។[56] សាលក្រមប្រកាសនៅថ្ងៃដែលមានការពិភាក្សាដេញដោល ឬនៅពេលសវនាការក្រោយ ដែលកាលបរិច្ឆេទត្រូវបានប្រាប់ដល់ភាគីដែលមានវត្តមាន ។[57]

នៅពេលសវនាការ ក្រឡាបញ្ជីសរសេរកំណត់សវនាការ ដែលមានគោលដៅ បើកឱកាសដល់សាលាឧទ្ធរណ៍ធ្វើការពិនិត្យនិយភាពនៃនីតិវិធី និងបានយល់ពីការពិភាក្សាដេញដោល ។ កំណត់សវនាការទាំងនេះត្រូវតែជាសេចក្តីចម្លងដែលត្រឹមត្រូវតាមសំណួរដែលសួរ និងចម្លើយរបស់ជនជាប់ចោទដើមបណ្តឹងរដ្ឋប្បវេណីអ្នកទទួលខុសត្រូវខាងផ្នែករដ្ឋប្បវេណី សាក្សី និងអ្នកជំនាញ ។

កំណត់ហេតុសវនាការត្រូវមានចុះហត្ថលេខាដោយក្រឡាបញ្ជីសវនាការ និងចុះទិន្នាការក្រោយពីផ្ទៀតផ្ទាត់ដោយប្រធានសវនាការក្នុងចិរវេលា ១០ ថ្ងៃ បន្ទាប់ពីប្រកាសសាលក្រម ។ គ្រប់ការខ្វះខាតក្នុងកាន់កាប់កំណត់សវនាការអាចត្រូវផ្តន្ទាទោសខាងវិន័យ ។[58]

តុលាការសម្រេចតែលើអង្គសេចក្តីដែលប្តឹងមកខ្លួន និងដែលមានចែងក្នុងពាក្យបណ្តឹងប៉ុណ្ណោះ។ ម្យ៉ាងទៀត គាត់អាចសម្រេចតែលើពិរុទ្ធភាពរបស់បុគ្គលដែលបញ្ជូនមកឲ្យគាត់ក្នុងឋានៈជាជនជាប់ចោទ ។ បើសាក្សីត្រូវបានសង្ស័យថាជាអ្នកប្រព្រឹត្ត ឬអ្នកសមគំនិត និងអំពើដែលប្តឹងមកចៅក្រម សាក្សីនោះ អាចនឹងត្រូវវិនិច្ឆ័យទោសបានបបន្ទាប់ពីត្រូវបានចោទប្រកាន់ក្នុងឋានៈជាជនជាប់ចោទ ។

តុលាការប្រកាសសាលក្រមដែលមានកំណត់ពីពិរុទ្ធភាព និងប្រកាសទោសដែលបានកំណត់ ដោយច្បាប់។ បើតុលាការយល់ឃើញថាអំពើមិនមែនជាបទល្មើស ឬជនជាប់ចោទមិនមានពិរុទ្ធភាព តុលាការប្រកាសសាលក្រមឲ្យរួចទោស ។ ក្នុងករណីដែលមានទោសជាប់ពន្ធនាគារ តុលាការអាចចេញ ដីកាបង្គាប់ឲ្យឃុំខ្លួន បើសិនជនជាប់ចោទមានវត្តមាននៅសវនាការ ឬដីកាបង្គាប់ឲ្យចាប់ខ្លួនបើសិនជនជាប់ចោទអវត្តមាន ។[59]

ក្នុងសាលក្រមព្រហ្មទណ្ឌ តុលាការក៏សម្រេចផងនូវផលប្រយោជន៍រដ្ឋប្បវេណី បើសិនបើរឿងក្តីព្រហ្មទណ្ឌបានជនរងគ្រោះបានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងទាមទារសំណងខាងខូចខាតលើព្យសនកម្មដែលកើតមានឡើងដែលសាលក្រមនេះមានអនុភាពចំពោះជនជាប់ចោទ ឬអ្នកទទួលខុសត្រូវសំណងរដ្ឋប្បវេណី ។[60]

---

[56] មាត្រា ៣១៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[57] មាត្រា ៣៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[58] មាត្រា ៣៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[59] មាត្រា ៣៥០ និងមាត្រា ៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[60] មាត្រា ៣៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

### ២.១.ប្រភេទនៃសាលក្រម

សាលក្រមត្រូវបានគេចាត់នូវប្រភេទនៃសាលក្រមដូចខាងដូចជា សាលក្រមចំពោះមុខ សាលក្រមដែលត្រូវចាត់ទុកចំពោះមុខ សាលក្រមកំបាំងមុខ សាលក្រមដែលចេញចំពោះដើមបណ្តឹងរដ្ឋប្បវេណីនិងសាលក្រមដែលចេញចំពោះអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ។

#### ២.១.១.សាលក្រមចំពោះមុខ

សាលក្រមចំពោះមុខ គឺជាសាលក្រមដែលជនជាប់ចោទចូលបង្ហាញខ្លួននៅពេលសវនាការ ។ អនុភាពនៃសាលក្រមចំពោះនេះ មិនត្រូវឲ្យដំណឹងដល់ជនជាប់ចោទនោះទេ ។ សាលក្រមចំពោះមុខនេះ អាចប្តឹងឧទ្ធរណ៍បាន។ សាលក្រមក៏ជាសាលក្រមចំពោះមុខផងដែរ ទោះបីជាជនជាប់ចោទត្រូវបានចាកចេញពីបន្ទប់សវនាការក៏ដោយ។ ក៏ត្រូវជាសាលក្រមចំពោះមុខផងដែរ ប្រសិនបើជនជាប់ចោទត្រូវបានសួរចម្លើយនៅក្នុងលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៣០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។[61]

#### ២.១.២. សាលក្រមដែលត្រូវចាត់ទុកចំពោះមុខ

សាលក្រមដែលត្រូវចាត់ទុកថាចំពោះមុខ និងត្រូវចាត់ទុកថាជាសាលក្រមចំពោះ ប្រសិនបើជនជាប់ចោទមិនចូលបង្ហាញខ្លួននៅពេលសវនាការទេ ប៉ុន្តែសាមីខ្លួនបានដឹងអំពីដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬបានដឹងពីការកោះហៅហើយនោះ សាលក្រមនឹងត្រូវចាត់ថាជាសាលក្រមចំពោះមុខ ។ សាលក្រមដែលចាត់ទុកថាចំពោះមុខត្រូវជូនដំណឹងដល់ជនជាប់ចោទ ហើយសាលក្រមនេះអាចប្តឹងឧទ្ធរណ៍បាន ។[62]

#### ២.១.៣. សាលក្រមកំបាំងមុខ

សាលក្រមកំបាំងមុខ ប្រសិនបើជនជាប់ចោទមិនបានចូលបង្ហាញខ្លួននៅពេលសវនាការ ហើយនិងប្រសិនបើគ្មានភស្តុតាងបង្ហាញឲ្យឃើញថាជនជាប់ចោទនឹងពីដីកាបញ្ជូនទៅជំនុំជម្រះ ឬបានដឹងអំពី ដីកាកោះហៅទេនោះ សាលក្រម ត្រូវប្រកាសដោយកំបាំងមុខជនជាប់ចោទ ។ សាលក្រមកំបាំងមុខនេះ ត្រូវឲ្យដំណឹងដល់ជនជាប់ចោទ ហើយជនជាប់ចោទមានសិទ្ធិក្នុងការធ្វើបណ្តឹងទាស់នឹងសាលក្រម ឬ បណ្តឹងឧទ្ធរណ៍បាន ។[63]

[61] មាត្រា ៣៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[62] មាត្រា ៣៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[63] មាត្រា ៣៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

### ២.១.៤.សាលក្រមដែលចេញចំពោះដើមបណ្ដឹងរដ្ឋប្បវេណី

សាលក្រមដែលចេញចំពោះដើមបណ្ដឹងរដ្ឋប្បវេណី ប្រសិនបើដើមបណ្ដឹងរដ្ឋប្បវេណី បានចូលបង្ហាញខ្លួននៅពេលសវនាការ ឬមានអ្នកតំណាងដោយត្រឹមត្រូវនោះ សាលក្រមត្រូវតែជាសាលក្រមចំពោះមុខដើមបណ្ដឹងរដ្ឋប្បវេណីនោះ ។ សាលក្រមចំពោះមុខដើមបណ្ដឹងរដ្ឋប្បវេណី មិនត្រូវជូនដំណឹងដល់សាមីខ្លួនទេ សាលក្រមនេះអាចប្ដឹងឧទ្ធរណ៍បាន ។ ប្រសិនដើមបណ្ដឹងរដ្ឋប្បវេណី មិនចូលបង្ហាញខ្លួននៅពេលសវនាការទេ និងគ្មានអ្នកតំណាងត្រឹមត្រូវ សាលក្រមត្រូវប្រកាសដោយកំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណី ។ សាលក្រមដែលកំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណីនេះ ត្រូវជូនដំណឹងដល់ដើមបណ្ដឹងរដ្ឋប្បវេណីដែលសាលក្រមនេះអាចប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍បាន ។[64]

### ២.១.៥. សាលក្រមដែលចេញចំពោះអ្នកទទួលខុសត្រូវរដ្ឋប្បវេណី

សាលក្រមដែលចេញចំពោះអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ប្រសិនបើបុគ្គលដែលកោះហៅក្នុងឋានៈជាអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ចូលបង្ហាញខ្លួននៅពេលសវនាការ ឬក៏មានអ្នកតំណាងដោយត្រឹមត្រូវ សាលក្រមនេះជាសាលក្រមចំពោះមុខអ្នកទទួលខុសត្រូវសំណងរដ្ឋប្បវេណី ។ សាលក្រមចំពោះមុខនេះ មិនត្រូវឲ្យដំណឹងដល់អ្នកទទួលខុសត្រូវរដ្ឋប្បវេណីទេ ។ សាលក្រមនេះអាចត្រូវប្ដឹងឧទ្ធរណ៍បាន ។ ប្រសិនបើបុគ្គលដែលបានកោះហៅក្នុងឋានៈជាអ្នកទទួលខុសត្រូវរដ្ឋប្បវេណី មិនចូលបង្ហាញខ្លួននៅពេលសវនាការ និងគ្មានអ្នកតំណាងដោយត្រឹមត្រូវទេនោះ សាលក្រមត្រូវសម្រេច ដោយកំបាំងមុខអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ។ សាលក្រមដែលកំបាំងមុខអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ត្រូវជូនដំណឹងដល់អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ដែលមានសិទ្ធិក្នុងការប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍បាន ។[65]

### ២.២.និទ្ទេសដែលត្រូវចុះជាភាតព្វកិច្ចក្នុងសាលក្រម

សាលក្រមត្រូវចុះហត្ថលេខាដោយប្រធាន និងក្រឡាបញ្ជី។

សាលក្រមត្រូវមានចុះសេចក្ដីដូចតទៅ:

- កាលបរិច្ឆេទនៃសវនាការ
- កាលបរិច្ឆេទនៃការប្រកាសសាលក្រម

[64] មាត្រា ៣៦៣ នៃក្រម នីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[65] មាត្រា ៣៦៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

- ឈ្មោះ និងឋានៈរបស់ចៅក្រមដែលជំនុំជម្រះ
- ឈ្មោះ និងឋានៈតំណាងអយ្យការ
- ឈ្មោះ និងឋានៈរបស់ក្រឡាបញ្ជី
- ឈ្មោះ ទីលំនៅ កាលបរិច្ឆេទ និងទីកន្លែងកំណើត មុខរបររបស់ជនជាប់ចោទរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី
- ឈ្មោះរបស់មេធាវី។

ក្រោយពីបានចុះហត្ថលេខាដោយប្រធាននិងក្រឡាបញ្ជីរួចសាលក្រមដើមត្រូវតម្កល់ទុកនៅការិយាល័យក្រឡាបញ្ជី យ៉ាងយូរបំផុត ៨ (ប្រាំបី) ថ្ងៃ ក្រោយការប្រកាសសាលក្រម ។ ការិយាល័យក្រឡាបញ្ជីត្រូវតែរក្សាទុកសាលក្រមដើមជានិច្ច។ក្រឡាបញ្ជីអាចផ្តល់ច្បាប់ចម្លងនៃសាលក្រមជាអាទិ៍ក្នុងករណីមានឧទ្ធរណ៍។

### ២.៣.ការជូនដំណឹងអំពីសាលក្រម

សាលក្រមត្រូវសម្រេចចេញនៅពេលសវនាការ ដែលធ្វើការពិភាក្សាដេញដោល ឬនៅពេលសវនាការលើកក្រោយ។ នៅក្នុងករណីខាងក្រោយនេះ ប្រធានសវនាការជូនដំណឹងដល់ភាគីទាំងឡាយដែលមានវត្តមានអំពីថ្ងៃដែលត្រូវប្រកាសសាលក្រម។

## ផ្នែកទី៣ បណ្តឹងតវ៉ា

បណ្តឹងតវ៉ា គឺតម្រូវឲ្យមានការពិនិត្យសារជាថ្មីនូវសំណុំរឿង ដោយតុលាការផ្សេងដែលបានចេញសេចក្តីសម្រេចដែលត្រូវបានគេជំទាស់ (តុលាការទី២នេះ ជាគោលការណ៍ គឺជាតុលាការដែលមានកម្រិតឋានានុក្រមខ្ពស់ជាង បើប្រៀបធៀបនឹងតុលាការដែលចេញសេចក្តីសម្រេច) ។ ហើយបណ្តឹងតវ៉ានេះ ក៏ តម្រូវឲ្យពិនិត្យសារជាថ្មីលើសំណុំរឿង ដោយតុលាការដែលបានចេញសេចក្តីសម្រេចដែលត្រូវបានគេ ជំទាស់នោះ ។

ហេតុនេះហើយផ្លូវតវ៉ាអាចចែកជា ២ ប្រភេទៈ ផ្លូវតវ៉ាសាមញ្ញ និងផ្លូវតវ៉ាវិសាមញ្ញ។

### ៣.១ បណ្តឹងតវ៉ាសាមញ្ញ

ផ្លូវតវ៉ាសាមញ្ញទាំងនេះ ត្រូវបានកំណត់ដោយផ្អែកទៅលើប្រភេទនៃសាលក្រមដែលបានចេញ។ បណ្តឹងតវ៉ាសាមញ្ញរួមមាន បណ្តឹងទាស់ និងបណ្តឹងឧទ្ធរណ៍ ។

### ៣.១.១. បណ្តឹងទាស់

បណ្តឹងទាស់ អាចធ្វើប្រឆាំងនឹងសាលក្រមកំបាំងមុខ មានន័យថា នៅពេលដែលជនជាប់ចោទ មិនបានបង្ហាញខ្លួននៅពេលសវនាការ មិនបានបង្ហាញថាខ្លួនដឹងពីការកោះហៅ សាលក្រម ឬសាលដីកា បើកផ្លូវបណ្តឹងទាស់ ។

បណ្តឹងទាស់ត្រូវធ្វើឡើងក្នុងថេរវេលា ១៥ ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលដំណឹងពីសាលក្រម ឬសាលដីកាកំបាំងមុខ ។

បណ្តឹងទាស់ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ នៅការិយាល័យក្រឡាបញ្ជីនៃតុលាការដែល ប្រកាសសាលក្រម ឬនៅចំពោះមុខព្រះរាជអាជ្ញា អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ឬនៅចំពោះ ប្រធានពន្ធនាគារ ឬនៅមណ្ឌលឃុំខ្លួន តែត្រូវបញ្ជូនបណ្តឹងទាស់នោះភ្លាមទៅក្រឡាបញ្ជីនៃតុលាការដែល បានប្រកាសសាលក្រម។ ពិរុទ្ធជនអាចត្រូវតំណាងដោយមេធាវី ចំពោះពិរុទ្ធជនជាអនីតិជនអាចត្រូវតំណាងដោយឪពុកម្តាយ ឬអ្នកអាណាព្យាបាល។

កាលណាបណ្តឹងទាស់ត្រូវធ្វើប្រឆាំងទៅលើសាលក្រមទាំងមូល សាលក្រមនោះ ត្រូវទុកជាអសារបង់ និងព្យួរការអនុវត្តរបស់សេចក្តីសម្រេចនោះ ។ ប៉ុន្តែដីកាបង្គាប់ឲ្យចាប់ខ្លួននៅតែមានអនុភាព ។ កាលណាបណ្តឹងទាស់ធ្វើប្រឆាំងទៅលើសេចក្តីសម្រេចផ្នែករដ្ឋប្បវេណីមានតែ សេចក្តីសម្រេចផ្នែកនេះប៉ុណ្ណោះដែលត្រូវទុកជាអសារបង់។ ការអនុវត្តសេចក្តីសម្រេចរដ្ឋប្បវេណីនេះត្រូវព្យួរ ។ ក្នុងករណីអ្នកប្តឹងទាស់មិនបានបង្ហាញខ្លួននៅសវនាការ ឯកសារឥតបានការ សាលក្រមនេះអាចប្តឹងឧទ្ធរណ៍បាន ។ តុលាការប្រកាសបណ្តឹងទាស់ទុកជាដើមបណ្តឹងរដ្ឋប្បវេណីក៏អាចប្តឹងទាស់នឹងសាលក្រម ដែលសម្រេចដោយកំបាំងមុខខ្លួនបានដែរ ។ បណ្តឹងទាស់នេះ ត្រូវកំណត់ទៅលើសេចក្តីសម្រេចផ្នែករដ្ឋប្បវេណីនៃសាលក្រមតែប៉ុណ្ណោះ ។

### ៣.១.២. បណ្តឹងឧទ្ធរណ៍

បណ្តឹងឧទ្ធរណ៍ គឺជាផ្លូវតវ៉ាឲ្យកែប្រែសេចក្តីសម្រេចរបស់សាលាដំបូង ទៅសាលាឧទ្ធរណ៍ ។

បុគ្គលដែលអាចធ្វើបណ្តឹងឧទ្ធរណ៍បាន៖

- ព្រះរាជអាជ្ញានៃតុលាការជាន់ដំបូង និងអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍
- ពិរុទ្ធជន
- ដើមបណ្តឹងរដ្ឋប្បវេណី ចំពោះផលប្រយោជន៍ផ្នែករដ្ឋប្បវេណី
- អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ចំពោះផលប្រយោជន៍ផ្នែករដ្ឋប្បវេណី ។

បណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា ពិរុទ្ធជន ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ត្រូវធ្វើនៅការិយាល័យក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម ។

ពិរុទ្ធជនអាចត្រូវតំណាងដោយមេធាវីតែមេធាវីត្រូវមានលិខិតប្រគល់សិទ្ធឲ្យធ្វើបណ្តឹងឧទ្ធរណ៍ ។ ចំពោះពិរុទ្ធជនជាអនីតិជន អាចតំណាងដោយឪពុកម្តាយ ឬអ្នកអាណាព្យាបាល ក្នុងករណីនេះអ្នកតំណាងមិនចាំបាច់មានលិខិតប្រគល់សិទ្ធិទេ ។ ពិរុទ្ធជនដែលជាប់ឃុំខ្លួនអាចសំដែងឆន្ទៈរបស់ខ្លួនក្នុងការបណ្តឹងឧទ្ធរណ៍នៅចំពោះមុខប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ។ ពិរុទ្ធជនបំពេញពាក្យបណ្តឹងឧទ្ធរណ៍ ដែលត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខា ឬត្រូវផ្តិតម្រាមដៃ ។ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួនត្រូវចុះបណ្តឹងឧទ្ធរណ៍លើបញ្ជីពិសេស ពិរុទ្ធជនត្រូវចុះហត្ថលេខា ឬផ្តិតម្រាមដៃលើរឹមនៃបញ្ជី រួចប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ត្រូវបញ្ជូនពាក្យបណ្តឹងឧទ្ធរណ៍នៅក្នុងរយៈពេលដ៏ខ្លីបំផុតទៅក្រឡាបញ្ជីនៃតុលាការដែលត្រូវចុះនិទ្ទេសអំពីពាក្យបណ្តឹងឧទ្ធរណ៍នេះ នៅលើបញ្ជីបណ្តឹងឧទ្ធរណ៍នៃតុលាការ ។

ចំណែកឯដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី អាចតំណាងដោយសហព័ទ្ធ ឬញាតិលោហិតផ្ទាល់ អ្នកតំណាងត្រូវមានលិខិតប្រគល់សិទ្ធិឲ្យធ្វើបណ្តឹងឧទ្ធរណ៍ ។

បណ្តឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញាត្រូវធ្វើតាមពាក្យបណ្តឹងនៅការិយាល័យក្រឡាបញ្ជីសាលាឧទ្ធរណ៍។

រយៈពេលក្នុងការធ្វើបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញានៃតុលាការជាន់ដំបូង មានរយៈពេល ១ (មួយ) ខែ និងចំពោះអគ្គព្រះរាជអាជ្ញា ត្រូវតែធ្វើក្នុងរយៈពេល ៣ (បី) ខែ គិតចាប់ពីថ្ងៃប្រកាសសាលក្រម។

ចំណែកពិរុទ្ធជន ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ត្រូវតែធ្វើក្នុងរយៈពេល ១ (មួយ) ខែ កាលណាសាលក្រមចំពោះមុខគិតចាប់ពីថ្ងៃប្រកាសលាក្រម ។ កាលណាសាលក្រមចាត់ទុកចំពោះមុខរយៈពេលក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ គិតចាប់ពីថ្ងៃទទួលបានដំណឹងសាលក្រម ។

ក្នុងករណីភាគីណាមួយបានប្តឹងឧទ្ធរណ៍ក្នុងរយៈពេលខាងលើភាគីដ៏ទៃទៀតមានរយៈពេលបន្ថែម ៧ (ប្រាំពីរ) ថ្ងៃ ដើម្បីធ្វើបណ្តឹងឧទ្ធរណ៍ឧប្បត្តិហេតុ ។ រយៈពេលបន្ថែមនេះគិតចាប់ពីការផុតរយៈពេលធម្មតា ។

ក្នុងរឿងឃុំខ្លួនការធ្វើបណ្តឹងឧទ្ធរណ៍ត្រូវធ្វើដោយព្រះរាជអាជ្ញាក្នុងរយៈពេល ៤៨ (សែសិបប្រាំបី) ម៉ោង និងដោយពិរុទ្ធជនក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ ។ រយៈពេលនេះផ្តើមគិតពីថ្ងៃដែលតុលាការសម្រេចពីការឃុំខ្លួន ។

កាលណាតុលាការចេញសាលក្រមចាត់របៀបបណ្តឹងឧទ្ធរណ៍អាចត្រូវទទួលភ្លាមប្រសិនបើ សាលក្រមនេះបញ្ចប់នីតិវិធី។ក្នុងករណីផ្ទុយពីនេះសាលក្រមចាត់របៀបនឹងអាចត្រូវដាក់ជូនសាលាឧទ្ធរណ៍ពិនិត្យបានលុះត្រាតែធ្វើព្រមគ្នាជាមួយសាលក្រមលើអង្គសេចក្តី ។

បណ្ដឹងឧទ្ធរណ៍ គឺមិនត្រូវបានលុបចោលនីតិវិធីមុនទេ វាគ្រាន់តែតវាលើនីតិវិធីនេះ ដើម្បីឲ្យជំនុំជម្រះម្តងទៀតនូវចំណុចអង្គហេតុ និងអង្គច្បាប់ ដែលតុលាការថ្នាក់ទីមួយបានសម្រេចរួចទៅហើយ ។ សាលាឧទ្ធរណ៍ទទួលបានសិទ្ធិពិនិត្យសារជាថ្មីនូវមធ្យោបាយដែលបានបន្ថែមពីលើពាក្យសុំដែលបានផ្ញើរួចមកហើយនៅមុខតុលាការជាន់ដំបូងប៉ុន្តែមិនអនុញ្ញាតឲ្យសាលាឧទ្ធរណ៍ទទួលពាក្យសុំថ្មី ដែលតុលាការជាន់ដំបូងមិនបានទទួលទោះបីជាបណ្តឹងអាជ្ញា (ការផ្តន្ទាទោសចំពោះបទល្មើសថ្មីដែល លើកឡើងពេលពិភាក្សាដេញដោយក្នុងសវនាការសាលាឧទ្ធរណ៍ ឬការលើកឡើងដោយបុគ្គលផ្សេងទៀតក្រៅពីបុគ្គលដែលបានផ្តន្ទាទោសនៅសាលាដំបូង) ឬជាដើមបណ្តឹងរដ្ឋប្បវេណី ( ការទទួលយកការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីថ្មី) ។ ក្នុងករណីបណ្តឹងឧទ្ធរណ៍លើសាលក្រមចាត់ទុកថាចំពោះមុខបុគ្គលពាក់ព័ន្ធគាត់អាចលើមធ្យោបាយខាងលើនេះចំពោះមុខសាលាឧទ្ធរណ៍បាន ។

